ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2013, 15:34
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី១៩២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ*(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក ឃើត រេយ៍ន័រ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វ៉ែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី សូ សុជាតិ (TCW-673) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី សូ សុជាតិ** (TCW-673)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........................................................ទំព័រ ២
សួរដោយលោក ឃីត រេយ៍ន័រ ផ្ដើមពី................................................................ទំព័រ ៣០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី សូ សុជាតិ នៅពេលព្រឹក ហើយនិងពេលរសៀលអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-648។

ក្រឡាបញ្ជីសវនាការលោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលនៅរួមកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបលោកប្រធាន នៅក្នុងសវនាការនៅថ្ងៃនេះគឺគ្រប់ភាគីទាំងអស់មាននៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកជនជាប់ចោទលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ តាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

សហមេធាវីនាំមុខជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលោក ពេជ អង្គ បានជូនដំណឹងមកថាលោកអវត្តមានពីសវនាការមួយព្រឹក ដោយសារមានមូលហេតុធុរៈផ្ទាល់ខ្លួន។

ដូចដែលលោកប្រធានបានជម្រាបសវនាការអម្បាញ់មិញ គឺសវនាការនៅព្រឹកនេះនឹងបន្តស្ដាប់សក្ខីកម្មរបស់សាក្សី សូ សុជាតិ និងពេលរសៀលស្ដាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-648។ សាក្សី TCW-648 បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងនៃ អ.វ.ត.ក កាលពីព្រឹកមិញនេះ និងបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿងនេះទេ។ ហើយសាក្សីបន្ទាប់នេះក៏នឹងមានមេធាវីប្រឹក្សាយោបល់លោក ម៉ម រិទ្ធា។

[០៩:០៦:២០]

សាក្សីថ្ងៃនេះក៏មានសាក្សី -- សវនាការថ្ងៃនេះក៏មានសាក្សីបម្រុងមួយរូបផងដែរ ដែលជា

សាក្សីទើបនឹងចូលថ្មី ស្របតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E256/3 និងឯកសារ E288។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក អានសាន។

ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

--

**ប្រធានអង្គជំនុំ៖**

សូមផ្អាកបន្តិចលោកតំណាងសហព្រះរាជអាជ្ញា! លោកចៅក្រម ឡាវែន៍ ទំនងជាគាត់មានសំណួរមួយចំនួនចង់សួរចំពោះសាក្សីរូបនេះដែរ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:០៧:២៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ជម្រាបសួរលោកស្រី សូ សុជាតិ។ ខ្ញុំមានសំណួរច្រើនដើម្បីសួរទៅកាន់លោកស្រីនៅពេលព្រឹកនេះ ដើម្បីបំពេញបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រីកាលពីម្សិលមិញ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជាដំបូងខ្ញុំមានសំណួរពាក់ព័ន្ធទៅនឹងអត្រានុកូលដ្ឋាននៃគ្រួសាររបស់លោកស្រី។ នៅពេលដែលស្នើសុំដោះលែងប្តីរបស់លោកស្រីនោះ មេធាវីរបស់គាត់បានប្រគល់ជូនតុលាការនូវឯកសារមួយចំនួន។ នៅក្នុងចំណោមឯកសារទាំងនោះ គឺមានសេចក្តីចម្លងសៀវភៅគ្រួសារ គឺឯកសារ E215/8។ ក៏ប៉ុន្តែសៀវភៅគ្រួសារនេះត្រូវបានធ្វើឡើងដោយដាក់ឈ្មោះ ស៊ីឡាង គឺនៅទំព័រទី៣ នៃឯកសារនេះ គឺលោក ខៀវ សំផន មានឈ្មោះហៅក្រៅថា ស៊ីឡាង។ តើឈ្មោះនេះត្រឹមត្រូវដែរឬទេ? ហើយតើគាត់ឈ្មោះថា ស៊ីឡាង នេះតាំងពីពេលណាមក?

[០៩:០៨:៥២]

**លោកស្រី សូ សុជាតិ៖**

**ឆ៖** សូមជម្រាប ស៊ីឡាង ឈ្មោះបងប្អូនគាត់ហៅនៅផ្ទះលេង ហើយយើងគិតថាដាក់អាហ្នឹង រួចទៅដាក់ឈ្មោះហ្នឹងហើយថាបន្ថែមវង់ក្រចក ហ្នឹងគាត់ឈ្មោះលេងនៅផ្ទះ។

**ស៖** ដូច្នេះឈ្មោះនេះមិនមែនជាឈ្មោះផ្លូវការទេ គឺគ្រាន់តែប្រើនៅក្នុងចំណោមក្រុមគ្រួសារតែប៉ុណ្ណឹងមែនទេ? ហើយនៅក្នុងឯកសារផ្លូវការនោះគាត់ប្រើឈ្មោះ ស៊ីឡាង ហ្នឹងនៅក្នុងឯកសារផ្លូវការហ្នឹងចាប់តាំងពីពេលណាមក? ហើយហេតុអ្វីបានជាគាត់ប្រើឈ្មោះហ្នឹងនៅក្នុងឯកសារផ្លូវការ?

**ឆ៖** កាលមកនៅប៉ៃលិន យើងខ្ញុំធ្វើជាសៀវភៅគ្រួសារនេះដោយយល់ឃើញថា ប្រើឈ្មោះចាស់គាត់ដែលហៅលេងនៅផ្ទះ រួចទៅវង់ក្រចកដាក់ថា លោកខៀវ សំផន តាមក្រោយ។ អាហ្នឹងក៏បានជួបជាមួយខាងភូមិខាងអីខាងអីអ៊ីចឹងទៅដាក់បានដែរ? អ៊ីចឹងដាក់ទៅអ៊ីចឹង។ ហ្នឹងគឺមានតាំងពីមកនៅប៉ៃលិនគឺដាក់ត្រឹមហ្នឹង។ ឯលោក ខៀវ សំផន គឺឈ្មោះគាត់តាំងពីដើមមក។

[០៩:១០:៣៩]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅសំណួរផ្សេងទៀត។ នៅក្នុងសៀវភៅគ្រួសារហ្នឹងក៏មានដាក់កូនបួននាក់ កូនទី១នោះគឺកូនប្រុស។ ហើយកាលពីម្សិលមិញនោះលោកស្រីបានឆ្លើយថាកើតថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៧៤ ក៏ប៉ុន្តែនៅក្នុងឯកសារផ្លូវការនោះដាក់ថា កូនទី១ កើតនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៧៤។ ដូច្នេះតើមួយណាដែលត្រឹមត្រូវ ចម្លើយលោកស្រីម្សិលមិញ ឬក៏អ្វីដែលសរសេរនៅក្នុងសៀវភៅគ្រួសារហ្នឹងត្រឹមត្រូវ?

**ឆ៖** គឺការកើតកូនខ្ញុំវានៅឆ្ងាយដល់អ៊ីចឹងទៅអាហ្នឹងវាចេះតែដាក់ ដល់អ៊ីចឹងការសួរដល់វាមាននៅក្នុងអត្តសញ្ញាណប័ណ្ណមាននៅក្នុងហ្នឹងហើយ ហើយអានេះខ្ញុំមកធ្វើក្រោយ ដល់អ៊ីចឹងអត់បានសួរវាដាក់យ៉ាងម៉េច? អីយ៉ាងម៉េច? ដល់មកសួរក្រោយវាប្រាប់ តែតាមការពិតកូនខ្ញុំកើតនៅដើមខែ៥ -- ថ្ងៃ០៤ ខែ៥, ៧៤។ អាហ្នឹងវាចេះតែដាក់អ៊ីចឹង។ ដល់អ៊ីចឹងដាក់តាមអត្តសញ្ញាណប័ណ្ណរបស់វាវិញ។

[០៩:១២:៣០]

**ស៖** អ៊ីចឹងកាលពីម្សិលមិញនេះលោកស្រីបានឆ្លើយថានៅពេលមានអាយុបីឆ្នាំនោះគេបញ្ជូនទៅកងកុមារ។ ហើយនៅកន្លែងនោះគឺថាមានគេថែទាំជាប្រចាំ។ ដូច្នេះខ្ញុំចង់ដឹងថា អ្នកណាជាអ្នកចេញសេចក្តីសម្រេចដើម្បីបញ្ជូនកូនរបស់លោកស្រីទៅកាន់កងកុមារនោះគេមានសួរយោបល់លោកស្រីទេ? ឬក៏មានសួរយោបល់ប្តីរបស់លោកស្រីទេ? ហើយឬមួយក៏ការសម្រេចហ្នឹងគឺសម្រេចដាច់ណាត់តែម្តង

លោកស្រីមិនអាចជំទាស់តវ៉ាអីបានទេ?

**ផ៖** នៅក្នុងមន្ទីរជារួម គឺការសម្រេចអីគឺតាមប្រធានមន្ទីរដែលគ្រប់គ្រងនៅកន្លែងមន្ទីរនោះ។ ឧទាហរណ៍ក-៣, អ្នកនៅមន្ទីរ ក-៣ គេគ្រប់គ្រង។ ដល់អ៊ីចឹងគេសម្រេចអី មកសួរយើងដែរ ប៉ុន្តែការសម្រេចរួចហើយ យើងអត់មានសុំនេះគេបានទេ។ ពីព្រោះជារួមទាំងអស់គ្នាត្រូវតែយកទៅអ៊ីចឹង។ ម្ដាយត្រូវធ្វើការគេមានអ្នកមើលត្រឹមត្រូវអ៊ីចឹង។ ដូច្នេះត្រូវតែយកទៅ។

[០៩:១៤:១០]

**ស៖** ការម្សិលមិញនេះលោកស្រីបានឆ្លើយថា កូនរបស់លោកស្រីហ្នឹងមកលេងលោកស្រីម្ដងម្កាលដែរ ហើយមើលទៅដូចថា កូនហ្នឹងដូចថាមើលទៅវេទនាដែរ ហើយមិនចង់ចាកចេញពីលោកស្រីទេ។ អ៊ីចឹងតើអ្នកណាជាអ្នកបង្ខំឲ្យកូនហ្នឹងត្រឡប់ទៅកាន់កងកុមារវិញ នៅពេលដែលកូនមកលេងម្ដងៗនោះ?

**ផ៖** ពេលឲ្យកូនមកលេងម្ដងៗបើយើងសុំកំណត់ថា១អាទិត្យ គឺត្រូវតែយកកូនហ្នឹងទៅវិញ ១អាទិត្យ ពីព្រោះអីការងារវាងាយស្រួលឲ្យម្ដាយធ្វើការងារ។ បើអ្នកដែលសម្រេច-- ថាយើងខ្ញុំអ្នកទៅសុំគេ តែក៏យកទៅវិញដោយឲ្យត្រូវពេលវេលាអ៊ីចឹង។

**ស៖** តើគេបង្ខំតែម្ដងថា ឲ្យត្រូវតែកូនហ្នឹងទៅវិញ ឬក៏យ៉ាងម៉េច? ហើយអ្នកណាជាអ្នកដែលបង្ខំពេលដែលកូនហ្នឹងមកហើយត្រូវតែយកទៅកន្លែងកងហ្នឹងវិញនោះ?

**ផ៖** គ្មានអ្នកណាបង្ខំទេ ព្រោះយើងខ្ញុំសូមគេមក១អាទិត្យ។ កូន ធម្មតាម្ដាយហើយនិងកូនធម្មតាវាមិនចង់ទៅទេ កូនអ្នកណាក៏ដោយ ប៉ុន្តែដល់ថ្ងៃហើយ ថា "កូនត្រូវតែទៅវិញ ពីព្រោះអីនៅនេះអត់មានអ្នកណាមើលទេ ម៉ែធ្វើការ។ ដូច្នេះកូនត្រូវតែទៅ"។ ដូចខ្ញុំអីត្រូវនិយាយជាមួយកូនអ៊ីចឹង ព្រោះសុំមក១អាទិត្យ ត្រូវតែជូនកូនទៅវិញ១អាទិត្យ។

[០៩:១៦:១៨]

**ស៖** តើនៅពេលណាមួយនោះប្ដីលោកស្រីមានសម្ដែងការមិនពេញចិត្តចំពោះការបង្ខំដល់កូនរបស់លោកស្រីដែលមានអាយុត្រឹមតែ៣ឆ្នាំ ឲ្យទៅអ៊ីចឹង គាត់មានរអ៊ូរទាំតវ៉ា ឬក៏គាត់មានប្រាប់លោកស្រីថា ដាច់ខាតត្រូវតែគោរពតាមបញ្ជារបស់អង្គការ?

**ផ៖** ប្ដីខ្ញុំមានរអ៊ូរទាំច្រើនដែរជាមួយខ្ញុំ ប៉ុន្តែវិន័យនៅក្នុងកន្លែងអ៊ីចឹងហើយ គឺថាយើងត្រូវតែធ្វើជារួមទាំងអស់គ្នាអ៊ីចឹងហើយ។ ដូច្នេះយើងមិនដឹងគិតយ៉ាងម៉េច ត្រូវតែទៅ។

**ស៖** តើគាត់មានត្អូញត្អែរ ឬក៏រអ៊ូរទាំចំពោះអ្នកដែលដឹកនាំមន្ទីរក-១, ក-៣ ដែរឬទេ? ហើយអ្នកដែលដឹកនាំ ក-១, ក-៣ ហ្នឹងជាអ្នកណាដែរ?

**ឆ៖** គាត់អត់ដែលរអ៊ូរទាំដាក់គេទេ គាត់និយាយតែជាមួយខ្ញុំទេ។

**ស៖** នៅពេលជម្លៀសទីក្រុងភ្នំពេញ តើកូនរបស់លោកស្រីហ្នឹងនៅឯណា? គឺពេលរំដោះភ្នំពេញឆ្នាំ១៩៧៩ នោះ?

**ឆ៖** រំដោះភ្នំពេញ ៧៩។ សូមទោសលោកប្រធាន ចង់ថារំដោះភ្នំពេញ ៧៩ ពេលដែល --សូមទោសៗ ម្តង--

[០៩:១៨:១៤]

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត សាក្សីស្តាប់មិនយល់ទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកស្រី សូ សុជាតិ កាលពីម្សិលមិញលោកស្រីបានឆ្លើយថា បានសម្រាលកូនទី៣ គឺមុនពេលវៀតណាមវៃចូលបន្តិច គឺខែមករា ឆ្នាំ១៩៧៩។ ដូច្នេះខ្ញុំចង់សួរលោកថា តើកូនប្រុសរបស់លោកស្រីហ្នឹងនៅឯណា? នៅពេលដែលវៀតណាមវៃចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩នោះ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស កូនប្រុសខ្ញុំនៅកន្លែងមណ្ឌលកុមារនៅឡើយទេ។

**ស៖** ដូច្នេះទាំងលោកស្រីផ្ទាល់ និងប្តីរបស់លោកស្រីហ្នឹង គឺថាអត់បានមើលកូនហ្នឹងទេអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

[០៩:១៩:៣៨]

**ស៖** ខ្ញុំអត់បានឮចម្លើយរបស់លោកស្រីជាភាសាបារាំងទេ។ ខ្ញុំមិនដឹងថា តើប្រហែលជាមានបញ្ហាបកប្រែ ឬក៏យ៉ាងណា? ដូច្នេះសូមឲ្យលោកស្រីផ្តល់ចម្លើយអម្បាញ់មិញនេះម្តងទៀត។

**ឆ៖** ពេលវៀតណាមវៃចូលកម្ពុជា ពេលនោះកូនខ្ញុំនៅមណ្ឌល តែដល់ពេលចេញ រៀបចំត្រូវទៅយកវាមកចេញមកជាមួយខ្ញុំ ជុំគ្នា។ ក្នុងរវាងថ្ងៃ ល្ងាចថ្ងៃ០៦ ពេលល្ងាចហ្នឹង ទៅយកហើយចេញមកបណ្តោយ។

**ស៖** បន្ទាប់ពីកូនទី១ហ្នឹងមក គឺមានកូនមួយទៀត គឺកូនស្រី ដែលកើតថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៦។ នេះនៅក្នុងសៀវភៅគ្រួសាររបស់លោកស្រី។ តើលោកស្រីអាចបញ្ជាក់ថ្ងៃខែឆ្នាំកំណើតរបស់កូនទី២នេះទេ គឺថ្ងៃទី១៨ កញ្ញា ១៩៧៦ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមទោស ១៣ ទេ លោកប្រធាន -- អ៎! ចាស ១៣ ថ្ងៃ១៣ ទេ។ ច្រឡំថ្ងៃ១៨ហើយ។

**ស៖** ដូច្នេះ គឺថាកូនទី២ហ្នឹង ១៣ កញ្ញា ១៩៧៦។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន។

[០៩:២១:៣៣]

**ស៖** កាលពីម្សិលមិញលោកស្រីបានពន្យល់ថា កូនស្រីរបស់លោកស្រីបាននិយាយថា ប្រាប់លោកស្រី ហើយដោយសារកូនហ្នឹង បានជាលោកស្រីហ្នឹងដឹងអំពីការងាររបស់ប្ដីលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ លើកលែងតែខ្ញុំមានការភាន់ច្រឡំ លោកស្រីបានឆ្លើយថា ប្ដីរបស់លោកស្រីនាំកូនស្រីហ្នឹងទៅតាម ហើយគាត់បានទៅមើលឃ្លាំង – ដែលទៅជាមួយកូនស្រីហ្នឹង – ដែលមានសម្ភារៈ មានចំណីអាហារដែលគេស្តុកនៅក្នុងឃ្លាំង"។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស មិនមែនទេ គឺកន្លែងដែលគាត់ធ្វើការនៅ ក-៣។ អត់មានទៅឃ្លាំងទេ។ គាត់គ្រាន់តែថា ឲ្យគេរៀបចំនៅឯកន្លែងឃ្លាំងទុកឯណោះ។ ឯនៅកន្លែង ក-៣ អត់មានទេ គ្រាន់តែនាំកូនស្រីទៅកន្លែងហ្នឹងទេ អត់មានសម្ភារៈឃ្លាំងទេ នៅកន្លែងហ្នឹង។

**ស៖** តើកូនស្រីរបស់លោកស្រីនោះ បានប្រាប់លោកស្រីថាម៉េច? គឺថាបើគិតទៅ គឺមានអាយុដែលត្រឹមតែ២៨ខែទេ ហើយអ៊ីចឹង កូនតូចប៉ុណ្ណឹង អាចពន្យល់ប្រាប់លោកស្រីពីការងាររបស់ប្ដីលោកស្រីយ៉ាងម៉េចបាន បើសូម្បីតែលោកស្រីហ្នឹង បើអត់ដឹងផង។ កូនក្មេងតូចប៉ុណ្ណឹង និយាយយ៉ាងម៉េចទៅនិយាយរៀបរាប់វែងអន្លាយទេ ឬក៏គ្រាន់តែប្រាប់មួយមាត់ថា ប្ដីលោកស្រីធ្វើអីអ៊ីចឹង?

[០៩:២៣:៣៦]

**ឆ៖** អានេះ វាមិនមែនប្រាប់ទេ។ អង្កាល់ហ្នឹង កូនខ្ញុំប្រហែលជា១ឆ្នាំជាង។ ខែប៉ុន្មានខ្ញុំអត់ដឹងទេ ប៉ុន្តែ១ឆ្នាំជាងហើយ វាចេះនិយាយតិចៗ ហើយវាអត់ប្រាប់ទេ វាលេងតែវាទេ។ ការនិយាយនេះ គឺគ្រាន់តែថា ឧទាហរណ៍ ណូៗ ម៉ាន់ៗ ហើយវាយកឈើ ឬស្មៅមក វាដាក់ ណូៗ ម៉ាន់ៗ។ ហើយខ្ញុំចេះតែឆ្លល់ស្អី ណូៗ ម៉ាន់ៗ ហ្នឹង។ អាហ្នឹង គ្រាន់តែវាសំដៅអ៊ីចឹងទេ វាអត់មានប្រាប់ទេ។

**ស៖** ខ្ញុំចង់ដឹងឲ្យច្បាស់ថា លោកស្រីដឹងថាប្ដីលោកស្រីធ្វើការអ្វីនៅក្នុងរបបកម្ពុជាប្រជាធិប-

តេយ្យហ្នឹង ដោយសារតែកូនស្រីហ្នឹង។ ខ្ញុំចង់ដឹងថាអ៊ីចឹងមែនទេ ចម្លើយលោកស្រីហ្នឹង កាលពីម្សិលមិញហ្នឹង ថាគឺដោយសារតែកូនស្រីហ្នឹងប្រាប់ ទើបលោកស្រីដឹងថាប្ដីលោកស្រីធ្វើអីនៅសម័យនោះ?

**ឆះ** ខ្ញុំឮកូនស្រីវាលេងអ៊ីចឹង។ ខ្ញុំក៏សួរថា "ពុក ម៉េចបានជាមីអូនវាចេះតែថា ណូៗ អ៊ីចឹង? ពេលហ្នឹងបានប្ដីខ្ញុំគាត់ប្រាប់ គាត់ថា "អ្ហឺ! ឲ្យបងប្អូនរៀបអីវ៉ាន់ ឲ្យទៅខាងមូលដ្ឋាន ឲ្យគេដឹកទៅ"។ គាត់អ្នកប្រាប់។ តែកូនខ្ញុំអត់ទេ វាចេះតែលេងអ៊ីចឹងទៅ។ ខ្ញុំសួរ សួរហ្នឹងសួរគាត់ទេ មិនមែនសួរកូនខ្ញុំទេ សួរគាត់ សួរប្ដីខ្ញុំ។ ហើយប្ដីខ្ញុំគាត់និយាយប្រាប់អ៊ីចឹង។

[០៩:២៥:៣៧]

**សះ** ដូច្នេះហ្នឹង គាត់ប្រាប់លោកស្រីថាម៉េចឲ្យច្បាស់ហ្នឹង នៅពេលដែលថាពេលលោកស្រីឮកូនប្រាប់អី ណូ ម៉ាន់ អីអ៊ីចឹង?

**ឆះ** ដល់ពេលខ្លះ គាត់រវល់នេះដែរ គាត់ប្រញាប់។ ឧទាហរណ៍ថាទៅរៀបអីវ៉ាន់ អ៊ីចឹងថាត្រូវរកឲ្យគេរៀបអីវ៉ាន់ គាត់ក៏ប្រាប់ខ្ញុំថា ថ្ងៃនេះរវល់ណាស់ អត់បានយកកូនទៅទេ គឺត្រូវរៀបចំសម្ភារៈមួយចំនួនយកទៅឲ្យខាងមូលដ្ឋាន។ ហើយជាហូរហែមក គាត់ក៏ប្រាប់ខ្ញុំតែរៀបអីវ៉ាន់ នៅប្រចាំនៅកន្លែងគេមាន -- កន្លែងគេរៀបផ្សេងទៀត នៅកន្លែងហ្នឹងដូចអត់ឃើញមានអីនេះផង ឃើញតែនិយាយតាម។ គាត់គឺគេប្រាប់មកឲ្យរៀប គឺរៀបអ៊ីចឹង។ មិនមានសម្ភារៈនៅកន្លែងហ្នឹងទេ អត់ទេ។

**សះ** បាទ យើងនឹងត្រឡប់មកនិយាយអំពីសកម្មភាពការងាររបស់ប្ដីលោកស្រីនៅពេលក្រោយនូវអ្វីដែលលោកស្រីបានដឹងអំពីគាត់នៅពេលក្រោយ។ ហើយនៅក្នុងសៀវភៅគ្រួសារដដែលហ្នឹង គឺថាមានកូនពីរនាក់ទៀត គឺកូនស្រីកើតនៅឆ្នាំ១៩៨៤ កូនប្រុសមួយទៀត គឺ១៩៨៧។ ហើយលោកស្រីក៏បានបញ្ជាក់ថា បានសម្រាលកូនមួយទៀតដែលកើតនៅដើមឆ្នាំ១៩៧៩ ប៉ុន្តែជាអកុសល កូនហ្នឹងគឺថាបានស្លាប់ទៅ។ តើត្រឹមត្រូវដែរឬទេលោកស្រី? ខ្ញុំស្ដាប់ឮពីម្សិលមិញ លោកស្រីថា ស្លាប់នៅអាយុកូនហ្នឹងស្លាប់នៅអាយុ៧ខែ។ តើត្រឹមត្រូវដែរឬទេ?

[០៩:២៧:៣៣]

**ឆះ** ចាសត្រឹមត្រូវ។

**សះ** ចំពោះលោកស្រីផ្ទាល់ ខ្ញុំឃើញថាលោកស្រីនោះមកពីភូមិកក់ពោន។ សូមទោសផងបើខ្ញុំអានឈ្មោះនេះមិនត្រូវនោះ។ ហើយភូមិនោះនៅក្នុងស្រុករវៀង ខេត្តព្រះវិហារ។ តើនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង កន្លែងដែលថាភូមិកក់ពោន ខេត្តព្រះវិហារហ្នឹងនៅក្នុងតំបន់១០៣មែនទេ?

**ធ៖** ចាស។

**ស៖** តើលោកស្រីអាចប្រាប់បានទេថា ព្រះវិហារហ្នឹងត្រូវបានរំដោះដោយកងកម្លាំងបដិវត្តន៍ហ្នឹងនៅពេលណាដែរ?

**ធ៖** ខ្ញុំមិនចាំច្បាស់នោះទេ។ ប្រហែលជា៧០ ក្នុងអំឡុងកន្លង១ខែ ២ខែក្រោយឆ្នាំ៧០។ ថ្ងៃអីខ្ញុំនេះទេ ប៉ុនប្រហែលប៉ុណ្ណឹង។ បើតាមខ្ញុំចាំ គឺនៅក្នុងភូមិខ្ញុំ។

[០៩:២៩:១៥]

**ស៖** តើមុន ឬក៏ក្រោយពេលប្រកាសការទម្លាក់សម្តេច នរោត្តម សីហនុ?

**ធ៖** ក្រោយទម្លាក់។

**ស៖** តើលោកស្រីអាចពន្យល់បន្តិចបានទេអំពីការរំដោះនោះ ខ្ញុំចង់ដឹងថាតើប្រជាជនដែលនៅក្នុងទីរួមខេត្តរវៀងហ្នឹងត្រូវបានគេជម្លៀសចេញទេនៅពេលរំដោះបាននោះ?

**ធ៖** អត់មានទេ។

**ស៖** លោកស្រីឆ្លើយថាម៉េចអម្បាញ់មិញនេះ? ថាអត់មានការជម្លៀសចេញពីរួមស្រុករវៀងហ្នឹងទេមែនទេ?

**ធ៖** កាលហ្នឹងដូចអត់មានអ្នកណាចេញទេ?

**ស៖** តើនៅពេលណាមួយនោះមានការជម្លៀសប្រជាជនចេញរវៀងហ្នឹងទេ? ហើយបើមានតើនៅពេលណា?

**ធ៖** ពេលនោះខ្ញុំអត់ដឹងអារឿងហ្នឹង ពីព្រោះអីខ្ញុំនៅអត់យល់អីទាំងអស់ ហើយអត់ដឹងរឿងជម្លៀសអីនៅកន្លែងរវៀង អត់មានទេ។

**ស៖** តើព្រះសង្ឃនៅតែគង់នៅវត្តដដែល ឬក៏គេឲ្យព្រះសង្ឃចេញពីវត្ត?

**ធ៖** កាលខ្ញុំនៅនោះនៅមានព្រះសង្ឃនៅឡើយ អត់ទាន់ចេញទេ។

[០៩:៣១:៣៣]

**ស៖** ចុះពេលណាដែរ ដែលព្រះសង្ឃចេញពីវត្ត? តើនៅពេលលោកស្រីរៀបការនុ៎ងមានព្រះសង្ឃនៅគង់នៅវត្តនៅឡើយទេ ឬក៏ម៉េចយ៉ាងណា?

**ធ៖** ពេលខ្ញុំរៀបការចូលមកនៅក្នុងព្រៃ ខ្ញុំអត់ដែលចេញទៅភូមិអត់ដឹងរឿងទាំងអស់នេះទេ។

**ស៖** តើលោកស្រីមានបានកត់សម្គាល់ឃើញ មានការបង្កើតសហករណ៍ដែរឬទេ? គឺនៅក្នុង

ពេលដែលលោកស្រីទៅក្នុងព្រៃដើរតាមបដិវត្តន៍នោះ ពេលនុ៎ងតើមានការបង្កើតសហករណ៍ហើយឬនៅ នៅក្នុងតំបន់របស់លោកស្រីនោះ?

**ឆ៖** ដូចមិនទាន់មានបង្កើតសហករណ៍ទេ។

**ស៖** តើនៅពេលណាដែលលោកស្រីដឹងថាមានការបង្កើតសហករណ៍?

**ឆ៖** សូមទោសទាំងអស់នេះខ្ញុំអត់បានចាំ ពីព្រោះអីខ្ញុំមិនជាអ្នកនយោបាយទេ ទៅដល់ខ្ញុំគ្រាន់តែដាំបាយ។ ដូច្នេះ រឿងទាំងអស់ដែលទាក់ទិននឹងសហករណ៍ហ្នឹងអី ខ្ញុំអត់ដឹង គេបង្កើតពេលពីអង្កាល់។

[០៩:៣៣:២៤]

**ស៖** ចុះម្ហូបអាហារសម្រាប់យកទៅរៀបចំ របស់របរសម្រាប់ធ្វើជាម្ហូបអាហារនុ៎ងមកពីណា? មកពីកសិករផ្ទាល់ ឬក៏មកពីសហករណ៍?

**ឆ៖** ម្ហូបអាហារដែលយកមកធ្វើជាម្ហូបគឺ អត់ដឹងយកមកពីខាងណាទេ។ រៀងរាល់ពេលដែលគេយកមកគេអត់ដែលប្រាប់យកមកពីខាងណាទេ គ្រាន់តែយកមកហើយ ខាងយើងខ្ញុំធ្វើតែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះយើងនិយាយអំពីកន្លែងដែលរស់នៅជាមួយមេដឹកនាំនៅស្ទឹងជីនិតនោះ។ កន្លែងហ្នឹងគេហៅថាយ៉ាងម៉េច? គេហៅថា ប-១៧ ឬក៏យ៉ាងម៉េច?

**ឆ៖** នៅកន្លែងហ្នឹងខ្ញុំមិនដឹងគេហៅអីទេ ប៉ុន្តែថាមន្ទីរស្ទឹងជីនិត មិនដឹងជាឈ្មោះជាលេខជាអីខ្ញុំអត់ដឹងដែរ។

**ស៖** តើមានកន្លែងណាដែលមានឈ្មោះថា ប-១៧ ដែលមិនមែនជាមន្ទីរស្ទឹងជីនិតហ្នឹងទេ?

**ឆ៖** ចាស មាន។

[០៩:៣៥:១៩]

**ស៖** ហើយ ប-១៧ នេះស្ថិតនៅឯណាដែរ?

**ឆ៖** ប-១៧ ស្ថិតនៅ -- កាលនោះគេហៅថាភូមិសំរោង ស្រុកស្ទឹងត្រង់ ឃុំខ្ញុំអត់ស្គាល់ទេ ប៉ុន្តែដឹងថាស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

**ស៖** នៅមន្ទីរស្ទឹងជីនិត ឬក៏ប-១៧ ឬក៏ ប-២០ ឬក៏នៅកន្លែងផ្សេងនោះតើគេហូបអាហារនោះរួមគ្នាដែរទេ?

**ឆ៖** ចាស ហូបអាហាររួមគ្នា។

**ស៖** តើនៅក្នុងកន្លែងទាំងអស់នោះគេមានធ្វើរបៀបមួយដែលគេហៅថាសមូហភាវូបនីយកម្ម ដែរឬទេ?

[០៩:៣៦:៤៥]

**ឆ៖** ដូចអត់មាន។

**ស៖** នៅពេលដែលលោកស្រីបានជួបលោក ខៀវ សំផន នោះលោកស្រីប្រាប់ពីម្សិលមិញថា លោកស្រីដឹងថាគាត់គ្រាន់តែជាបញ្ញាជន តើលោកស្រីធ្លាប់ឮគេនិយាយពីឯកសារមួយដែលនិយាយថា សេចក្ដីប្រកាសរបស់បញ្ញាជនស្នេហាជាតិ។ ឯកសារនេះគឺស៊ីញេដោយបញ្ញាជន៩១នាក់ដែលភៀសខ្លួន ទៅនៅតំបន់រំដោះ។ លោកស្រីធ្លាប់ឮសេចក្ដីថ្លែងការណ៍បែបនេះទេ?

**ឆ៖** នាងខ្ញុំអត់ដែលឮផង។

**ស៖** តើលោកស្រីធ្លាប់បានពិភាក្សាជាមួយនឹងប្ដីរបស់លោកស្រីអំពីតួនាទីរបស់គាត់ ឬក៏តួនាទី របស់មេដឹកនាំផ្សេងទៀត ហើយនិងមាននិយាយគ្នាអំពីថាតើបដិវត្តន៍ហ្នឹងជាអ្វីទេ?

**ឆ៖** ប្ដីខ្ញុំអត់ដែលនិយាយអំពីរឿងអ្នកដឹកនាំបដិវត្តន៍ឬមួយក៏អីទេ គ្រាន់តែនិយាយជាផ្ទាល់ខ្លួន។

**ស៖** អ៊ីចឹងមានន័យថា បដិវត្តន៍ហ្នឹងមិនពាក់ព័ន្ធនឹងលោកស្រីទេ។ អ៊ីចឹងបានន័យថាចំពោះ លោកស្រី និងប្ដីលោកស្រីហ្នឹងបដិវត្តន៍ហ្នឹងដូចអត់មានផលប្រយោជន៍អីទេ។ អ៊ីចឹងមែនទេ?

**ឆ៖** សូមទោសលោកប្រធាន អំមិញចង់សួរយ៉ាងម៉េច ខ្ញុំដូចអត់យល់។

**ស៖** លោកស្រីបានចូលព្រៃដើម្បីតស៊ូបដិវត្តន៍។ លោកស្រីបានទទួលការបណ្ដុះបណ្ដាលដែល មានឈ្មោះ យឹម ជាអ្នកបង្រៀន។ ដូច្នេះខ្ញុំគិតថាលោកស្រីមានការប្ដេជ្ញាចិត្តបដិវត្តន៍មិនមែនថាទៅ នោះដោយចៃដន្យទេ គឺថាមានការប្ដេជ្ញាចិត្តហើយ។ ដូច្នេះតើលោកស្រីមាននិយាយអំពីការប្ដេជ្ញាចិត្ត បដិវត្តន៍របស់លោកស្រីទេ ឬមួយក៏អត់មានអ្នកណាគេនិយាយចាប់អារម្មណ៍ពីបញ្ហាទាំងអស់នេះទេ?

[០៩:៤០:០០]

**ឆ៖** គេនិយាយពីរឿងបដិវត្តន៍នេះដែរ ហើយប្ដីខ្ញុំក៏និយាយពីរឿងបដិវត្តន៍ហ្នឹងដែរ។ ប៉ុន្តែសំដៅ សំខាន់ គឺថាយើងមកចូលរួមធ្វើបដិវត្តន៍ដើម្បី កាលនុំង គឺវៃចក្រពត្តិឈ្លានពាន ហើយដើម្បីរំដោះ ប្រទេស។ ក្រៅពីនោះមិនទាន់មានអីផ្សេងទេ។

**ស៖** តើនេះគឺជាវិន័យឬក៏យ៉ាងម៉េច ដែលថាមិននិយាយអ៊ីចឹងនោះ? លោកស្រីស្គាល់ទេថាអ្វី ជាវិន័យ? គឺថាត្រូវតែគោរពតាមអង្គការអ៊ីចឹងមែនទេ?

**ឆ៖** អ្វីដែលខ្ញុំ នាងខ្ញុំដឹង ខ្ញុំសូមជម្រាបប៉ុណ្ណឹង ពីព្រោះអីរយៈកាលមួយៗដូចជាមាន អាហ្នឹងមានប៉ុណ្ណឹងកាលពីខ្ញុំចូលដំបូង។ និយាយតែពីរឿងចក្រពត្តិ និយាយតែពីរឿងធ្វើយ៉ាងណាតស៊ូដើម្បីឈ្នះត្រូវតែលះបង់ ហ្នឹងមានប៉ុណ្ណឹងបើតាមខ្ញុំចាំ។ ដូច្នេះខ្ញុំចូលមកក៏ជឿទុកចិត្តដោយមានរដ្ឋប្រហារ ដោយមានចក្រពត្តិបរទេសឈ្លានពាន បានខ្ញុំចូលមករួមដើម្បីដណ្ដើមឯករាជ្យ យកសន្តិភាពមកវិញ។ ហ្នឹងមានប៉ុណ្ណឹង។

[០៩:៤២:០៣]

**ស៖** លោកស្រីមើលទៅដូចជាចម្លើយរបស់លោកស្រីហ្នឹងមិនពាក់ព័ន្ធទៅនឹងសំណួររបស់ខ្ញុំទេ។ ខ្ញុំសួរលោកថា សួរលោកស្រីថា ចំពោះលោកស្រីហ្នឹងវិន័យគឺជាបញ្ហាសំខាន់បំផុត ដាច់ខាតត្រូវតែគោរពតាមអង្គការ ឬក៏យើងអាចពិភាក្សាគ្នាបាន?

**ឆ៖** ជាវិន័យ គឺសំខាន់ដែរ គឺសម្រាប់បងប្អូនទាំងអស់ គឺយើងត្រូវគោរពវិន័យនៅក្នុងកន្លែងមួយ គឺឲ្យបានត្រឹមត្រូវ។ ខ្ញុំឃើញថាសំខាន់។

**ស៖** នៅសម័យនោះ តើលោកស្រីធ្លាប់ឃើញប្ដីលោកស្រីបង្ហាញអំពីការសង្ស័យ ការព្រួយបារម្ភ ឬក៏មានការចោទសួរខ្លួនឯង ឬក៏លោកស្រីឃើញថាគាត់ហ្នឹងតែងតែឯកភាពយល់ស្របតាមមេដឹកនាំផ្សេងៗទៀតនៅជាមួយគាត់នោះ គឺនៅមន្ទីរស្ទឹងជីនិត ឬក៏នៅប-១៧ ឬក៏នៅកន្លែងផ្សេងទៀតនោះ?

**ឆ៖** ពេលនោះ ខ្ញុំក៏មិនបានសង្កេតដែរ ពីព្រោះនៅកន្លែង ដឹងថាភារកិច្ចខ្លួនឯងធ្វើអី គឺព្រលឹមឡើងត្រូវតែទៅ។ ដូច្នេះអត់បានត្រួតពិនិត្យ អត់បានចាប់អារម្មណ៍អីលើរូបគាត់ទេ។ អ៊ីចឹងខ្ញុំអត់ដឹងថាយ៉ាងម៉េច អត់ដឹងថាគាត់យ៉ាងម៉េចទេ គឺអត់។

[០៩:៤៤:១៨]

**ស៖** នៅពេលណាដែលលោកស្រីដឹងថា ប្ដីរបស់លោកស្រីមានមុខងារខ្ពស់ គឺថាមានឋានៈជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាអគ្គមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជានោះ? នៅពេលណាដែលលោកស្រីដឹងអំពីឋានៈ និងតួនាទីរបស់គាត់ទាំងអស់នេះ?

**ឆ៖** ចាស ខ្ញុំមិនដែលដឹងអារឿងឋានៈរបស់គាត់ជានេះទេ ពីព្រោះគាត់មិនដែលនិយាយប្រាប់ខ្ញុំហើយម្យ៉ាងទៀតអ្នកនៅកន្លែងហ្នឹង គឺថាគ្រាន់តែគេដាក់ងារជាបញ្ញាជន ហើយគេក៏មិនទុកជាអ្នកធំ។ អ្នកមានមុខមាត់បុណ្យសក្តិ ជាឧបនាយកជាស្អី។ ដូចមិនៗ ដូចអត់មាន ហើយខ្ញុំអត់ដឹង។ មានឈ្មោះ

ធម្មតា តែខ្លួនគាត់ គាត់ថាគាត់អត់មាននេះទេ គាត់គ្រាន់តែ -- តែគាត់អត់មានអ្នកធំ គាត់ថាគាត់ពិតមែនតែនេះ គាត់អត់អ្នកធំទេ។ គាត់ប្រាប់ខ្ញុំអ៊ីចឹង។ ដូច្នេះ យើងត្រូវទុកខ្លួនយើងជាអ្នកធំ ប្រពន្ធអ្នកធំអីៗ ខ្ញុំក៏ចាត់ទុកខ្លួនខ្ញុំជាអ្នកធំទេ។ ហ្នឹងខ្ញុំឃើញអ៊ីចឹង។ ដូចអត់មាន។

**ស៖** លោកស្រី តើមនុស្សសាមញ្ញធម្មតាដែលបានទទួលសម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៧៣ នៅពេលដែលព្រះអង្គបានមកទស្សនកិច្ចនៅតំបន់រំដោះ។ តើលោកស្រីដឹងថា កាលណោះជាស្វាមីរបស់លោកស្រីទេ ដែលបានទទួលព្រះអង្គនោះ? ហើយដឹងថាគាត់កាន់តំណែងមុខងារធំនៅពេលនុ៎ងទេ?

[០៩:៤៦:៥៣]

**ឆ៖** កាលនោះ ក៏គេថាមិនអ្នកធំដែរ តាមខ្ញុំដឹង គឺគ្រាន់តែជារណសិរ្សទៅជួបសម្តេច។ ដូច្នេះ គេអត់និយាយថាគាត់អ្នកធំផង។

**ស៖** ខ្ញុំសួរថាតើអ្នកណាអ្នកទទួលអតីតស្តេច។ តើជា ប៉ុល ពត? ជា នួន ជា? ឬក៏ជាស្វាមីរបស់លោកស្រី?

**ឆ៖** ខ្ញុំឃើញពេលនោះ មានតាំង ប៉ុល ពត មានទាំងគាត់ដែលទៅជួប។

**ស៖** តើអ្នកណាជាដឹកនាំគេទៅទទួលសម្តេច សីហនុ ជាគឺប៉ុល ពត? ជាអ្នកផ្សេង ឬក៏ជាប្តីរបស់លោកស្រី?

**ឆ៖** ចាសពេលនោះខ្ញុំអត់បានចាប់អារម្មណ៍អារឿងអ្នកណាអ្នកនាំ ដឹកនាំទៅទទួលសម្តេចទេ។

**ស៖** លោកស្រីកាលពីម្សិលមិញ លោកស្រីបានឆ្លើយថានៅពេលធ្វើទស្សនកិច្ចនោះ អ្នកស្រីជាអ្នកបម្រើសម្តេច នរោត្តម សីហនុ។ ដូច្នេះ លោកស្រីនៅជួរទី១ហើយ អ៊ីចឹងដឹងថាមានរឿងអ្វីកើតឡើងនៅពេលនោះ? តើស្វាមីរបស់លោកស្រីហ្នឹងមិនមែនជាអ្នកទទួលបន្ទុកទទួលសម្តេច នរោត្តម សីហនុនៅពេលនោះទេឬ ជាផ្លូវការ?

**ឆ៖** ពេលនោះ ខ្ញុំជាអ្នកបម្រើខាងផ្នែកបាយទឹក បន្ទប់។ ពេលចូលកន្លែងធ្វើការ ខ្ញុំអត់មានមុខទៅទេ។

[០៩:៤៩:៤៨]

**ស៖** តើលោកស្រីធ្លាប់ឮពាក្យ "គណៈមជ្ឈិម" ទេ? "គណៈអចិន្ត្រៃយ៍សមាជរបស់រណសិរ្សរួបរួមជាតិកម្ពុជា" តើលោកស្រីធ្លាប់ឮ ឬក៏ឃើញប្តីរបស់លោកស្រីគាត់តែងសុន្ទរកថាដែរឬទេ?

**ឆ៖** នៅពេលនោះ ខ្ញុំអត់ដឹងរឿងទាំងអស់នេះទេ។ ពីព្រោះគ្រាន់តែផ្នែកមួយជាអ្នកដាំបាយ

ដូច្នេះអារឿងធំៗរបស់នយោបាយ ពីព្រោះអីខ្ញុំអត់ មិនមែនជាអ្នកនយោបាយ។ សូមទោស ខ្ញុំអត់ដឹង។

**ស៖** បាទលោកស្រីខ្ញុំចង់យល់ -- តើរឿងទាំងអស់នេះអ្នកស្រីមិនចាំអារម្មណ៍ទេ ហើយអ្នកស្រីចាត់ទុកថាវាអត់ប្រយោជន៍ក្នុងការយល់រឿងរ៉ាវទាំងអស់នេះ ឬក៏លោកស្រីធ្លាប់ចោទសំណួរមួយចំនួនទៅស្វាមីរបស់លោកស្រីដែរ?

**ឆ៖** ខ្ញុំយល់ឃើញថា ទាំងអស់នេះដោយសារតែខ្ញុំមិនចាំអារម្មណ៍រឿងមួយនេះ ពីព្រោះអីខ្ញុំរវល់នៅក្នុងផ្ទះបាយណាស់ គ្មានពេលទៅបានពិគ្រោះពិភាក្សា ឬក៏ប្ដីខ្ញុំអីប្រាប់អីអត់ អត់មានទេ។ ភារកិច្ចរៀងៗខ្លួន។

[០៩:៥១:៤១]

**ស៖** នៅពេលដែលលោកស្វាមីរបស់អ្នកស្រីចាកចេញទៅ គាត់ចេញទៅធ្វើទស្សនកិច្ចនៅប្រទេសចិននៅបរទេសជាដើម។ តើអ្នកស្រីមិនចាប់អារម្មណ៍ពិភាក្សារឿងប្រធានបទទាំងអស់នេះជាមួយគាត់ទេ គាត់ក៏មិនដែលនិយាយជាមួយគាត់ដែរ -- លោកស្រីដែរ អត់ដែលមានពិភាក្សាគ្នារឿងទាំងអស់នេះ ឬក៏យ៉ាងម៉េច?

**ឆ៖** រឿងនេះការងាររបស់គាត់ ខ្ញុំអត់ដែលមកពាក់ព័ន្ធទេ គ្រាន់តែដឹងថាគាត់ទៅចិនដើម្បីជួបសម្ដេច។ ប៉ុណ្ណឹងដឹង។

**ស៖** តែប៉ុណ្ណឹងទេ? តើគ្រាន់តែប្រាប់លោកស្រីថា គាត់ទៅជួបសម្ដេច សីហនុ ហើយគាត់មិនប្រាប់លោកស្រីថាគាត់ត្រឡប់មកវិញនៅពេលណានោះទេ គាត់បាននិយាយតែប៉ុណ្ណឹងទេ ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់និយាយតែប៉ុណ្ណឹង ហើយប្រហែលត្រឡប់មកវិញថ្ងៃណាៗ អត់ដែលនិយាយផងអត់ដឹង។

**ស៖** តើអ្នកស្រីធ្លាប់ឮគេនិយាយអំពីជនមហាក្បត់ទាំងប្រាំពីរដែរឬទេ?

**ឆ៖** ចាសអត់ដឹង។

[០៩:៥៣:៣៥]

**ស៖** កាលពីម្សិលមិញលោកស្រីបានឆ្លើយថានៅមុនថ្ងៃ១៧ មេសា ហ្នឹងតើលោកស្រីនៅក-១៧ បន្ទាប់មក ប-២០ ហើយបន្ទាប់មកទៀតក្រោយពីកូនទី១របស់លោកស្រីកើតមក តើលោកស្រីបានផ្លាស់ទីទៅនៅមាឃ។ នៅមាឃអីចឹង តើមានមន្ទីរមាឃនោះទេ បើសិនជាមានមែននោះ មាឃនោះជាមន្ទីរអីដែរលោកស្រី? គឺថាបន្ទាប់ពីកូនទី១របស់លោកស្រីបានចាំកំណើតមកហ្នឹង លោកស្រីនៅកន្លែង

ណាដែរ?

**ឆ៖** បានចាប់កំណើតមក ខ្ញុំនៅមន្ទីរម្ភៃ-- គេហៅពីស្ទឹងជីនិត មកមាន ២៤, មានខ-៣០ អាហ្នឹងគេបន្តៗមក បានមក១៧។

**ស៖** កាលពីម្សិលមិញលោកស្រីក៏បានឆ្លើយផងដែរថា ប្រហែលជា១០ ទៅ១៥ថ្ងៃមុនពេលដែលភ្នំពេញដួលរលំ ស្វាមីរបស់លោកស្រីបានចេញពីលោកស្រីដោយប្រាប់លោកស្រីថា ភ្នំពេញនឹងជិតរលំហើយ។ តើអ៊ីចឹងមែនទេ ម្សិលមិញលោកស្រីបាននិយាយបែបនេះ?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** តើគាត់មានប្រាប់លោកស្រីអំពីអ្វីដែលនឹងកើតឡើងដែរឬទេ នៅពេលដែលភ្នំពេញដួលរលំនោះ?

**ឆ៖** ចាស អត់មានប្រាប់ទេ។

[០៩:៥៥:៤៦]

**ស៖** ហើយរឿងទាំងអស់នេះលោកស្រីអត់ចាប់អារម្មណ៍ទេ ឬក៏យ៉ាងម៉េច?

**ឆ៖** នាងខ្ញុំគិតថា ការណ៍ហ្នឹង -- ព្រោះការងារវាសំខាន់ដែរ។ ដូច្នេះផ្នែកខាងនយោបាយ អ្នកដឹកនាំអាហ្នឹងយើងខ្ញុំអត់មានពាក់ព័ន្ធ ដឹងតែការងាររបស់ខ្លួនឯង។ សំខាន់មិនសំខាន់ គឺថាផ្តោតភ្ជាប់លើការងារ។

**ស៖** ម្សិលមិញលោកស្រីក៏បានឆ្លើយផងដែរ ប្រហែលជា១សប្តាហ៍មុនភ្នំពេញដួលរលំ កាលនោះលោកស្រីនៅស្ទឹងត្រែង ហើយលោក ខៀវ សំផន បានមកជួបលោកស្រី -- នៅស្ទឹងត្រង់អង្កាល់នោះហើយក៏បានគេង១យប់ជាមួយគ្នា។ តើអ៊ីចឹងមែនទេ?

**ឆ៖** អត់មែនទេ អត់មែននៅស្ទឹងត្រង់ទេ។

**ស៖** តើក្រោយពីភ្នំពេញដួលរលំនោះ លោកស្រីបានជួបគាត់ជាដំបូងនុំងនៅកន្លែងណា? នៅពេលណាដែរ? កន្លែងណាហើយពេលណា?

**ឆ៖** ពេលក្រោយ១អាទិត្យខ្ញុំជួបទៅគាត់នៅស្តុកគោល១ថ្ងៃ -- ១យប់ មិនមែន១ថ្ងៃទេ១យប់។

**ស៖** តើរយៈពេលថ្ងៃក្រោយពីភ្នំពេញដួលរលំ?

**ឆ៖** ១អាទិត្យ។

[០៩:៥៨:១៧]

**ស៖** លោកស្រីផ្ទាល់ តើលោកស្រីបានដឹងថាភ្នំពេញដួលរលំនោះតាមរបៀបណាដែរ?

**ឆ៖** ពេលនុំងដឹងថាគេវ៉ៃគ្នាផ្នែកម្ខាងៗ ហើយខាងអ្នកបដិវត្តន៍វ៉ៃទៅម្ខាងទៅ ហើយដោយខាងបដិវត្តន៍ឈ្នះអាហ្នឹងជាការដួលរលំ ខ្ញុំឃើញអ៊ីចឹង។

**ស៖** លោកស្រី តើលោកស្រីបានដឹងទេថាភ្នំពេញ ក៏ដូចជាទីក្រុងផ្សេងដែរគឺថាត្រូវបានជម្លៀស តើលោកស្រីធ្លាប់បានឃើញ បានឮប្រជាជនត្រូវបានគេបង្ខំឲ្យចាកចេញពីទីក្រុង ហើយដើរតាមផ្លូវអ៊ីចឹង?

**ឆ៖** កាលពីមុនដំបូងទើបតែរំដោះហើយ យើងខ្ញុំក៏អត់បានដឹងនេះដែរ មិនបានដឹងអារឿងជម្លៀស អត់ដឹងពីរឿងអីទេ ស្មានតែប្រជាជននៅកន្លែង។ ប៉ុន្តែកាលក្រោយមកពួកខ្ញុំ ដែលខ្ញុំមកហ្នឹងគឺស្ងាត់ឈឹង អត់មានស្អី ខ្ញុំមករ៉ាវទេះភ្លើងហ្នឹង អត់ ដូច្នេះពីមុនមកខ្ញុំក៏អត់ដឹងថាគេជម្លៀសដែរ។

**ស៖** បាទ ឥឡូវយើងត្រឡប់មកនិយាយការមកដល់របស់លោកស្រី នៅទីក្រុងភ្នំពេញនៅពេលក្រោយ។ ក៏ប៉ុន្តែជាបឋមខ្ញុំសូមឲ្យលោកស្រីនិយាយ ថាតើលោក ខៀវ សំផន ធ្លាប់បានចែករំលែក ឬក៏រៀបរាប់អីបទពិសោធន៍ដណ្តើមបានទីក្រុងភ្នំពេញជាមួយលោកស្រីដែរឬទេ? គាត់មានបានប្រាប់លោកស្រីថា តើរឿងរ៉ាវទាំងឡាយហ្នឹងកើតឡើងយ៉ាងដូចម្តេចដែរ? ហើយក៏មានបានប្រាប់លោកស្រីថាអនាគតលោកស្រីនឹងយ៉ាងម៉េចដែរនៅថ្ងៃមុខ? គាត់មានបាននិយាយអ៊ីចឹងទេ ចែករំលែកព័ត៌មានទាំងអស់ហ្នឹងទេ?

[១០:០១:០៩]

**ឆ៖** គឺគាត់មិនដែលបាននិយាយពីរឿងការ ទៅមុខយើងយ៉ាងម៉េចអីយ៉ាងម៉េច ខ្ញុំ-- គាត់ក៏មិនដែលទេ។ គ្រាន់តែថាចូលទៅៗ ហើយការងារអី ការងារហ្នឹងទៅ។ គាត់អត់ដែលនិយាយប្រាប់ខ្ញុំទេ។

**ស៖** លោកស្រី តើលោកស្រីមានបានដឹងដែរឬទេ ដឹងថាតើប្តីរបស់លោកស្រីមានគ្រួសារ មានម្តាយមានបងប្អូនប្រុសស្រី មានមិត្តភក្តិដែលរស់នៅទីក្រុងភ្នំពេញដែរឬទេ? តើគាត់ធ្លាប់និយាយពីរឿងទាំងអស់នេះ ពីពួកគាត់ទាំងអស់នោះប្រាប់លោកស្រីដែរឬទេ? ហើយគាត់មានធ្លាប់ប្រាប់លោកស្រី អំពីអ្វីដែលកើតឡើងចំពោះបងប្អូនក្រុមគ្រួសារ មិត្តភក្តិគាត់ទាំងអស់នោះដែរឬទេ?

**ឆ៖** ក្រោយមកគាត់ធ្លាប់និយាយ អំពីបងប្អូនគាត់ដែលជម្លៀសទៅ។

**ស៖** នៅពេលណា គាត់និយាយរឿងហ្នឹងប្រាប់លោកស្រីនៅពេលណា?

[១០:០២:៤៨]

**ឆ៖** ខ្ញុំមិនច្បាស់នោះទេ ប៉ុន្តែមកនៅភ្នំពេញយូរបន្តិចហើយ យូរហ្នឹងគឺច្រើនដូចថា ១ឆ្នាំជាងអីហើយ។

**ស៖** ដូច្នេះគឺថាក្នុងរយៈពេលជាងមួយឆ្នាំនុំង លោក ខៀវសំផន គាត់រស់នៅជិតលោកស្រីជាមួយលោកស្រី គឺគាត់ដឹងថាបងប្អូនគាត់ ឪពុករបស់គាត់ត្រូវបានជម្លៀសចេញពីក្រុងភ្នំពេញ ហើយកាលនោះគាត់ហាក់បីដូចជាមិនមានការប៉ះទង្គិចផ្លូវចិត្តអីទេ។ ចង់និយាយថា គាត់មិនបាននិយាយរឿងរ៉ាវទាំងអស់ហ្នឹងប្រាប់លោកស្រី គាត់មិនបាននឹងខំព្យាយាមថាតើបងប្អូនគាត់ទាំងអស់ហ្នឹងនៅឯណានៅសម័យនោះ នៅក្នុងអំឡុងជាង១ឆ្នាំហ្នឹង។ អ៊ីចឹងមែនទេ?

**ឆ៖** គាត់បាននិយាយដោយក្ដីដូចគេហៅថា ព្រួយបារម្ភដែរ។ ជាពិសេសគឺបងប្អូនគាត់ដែលជម្លៀសទៅគាត់មិននឹកស្មានថាអ៊ីចឹងដែរណ៎ា ហើយគាត់មកនិយាយប្រាប់ខ្ញុំ។ គាត់ថាមិនដឹងទៅដល់ណាមិនដឹងទៅដល់ណីទេ។ ហ្នឹងគាត់មាននិយាយតែប៉ុណ្ណឹង ហើយមិនដឹងយ៉ាងម៉េចយ៉ាងម៉ាទេ -- ប្រហែល -- គាត់មានបន្ថែមគាត់ថាប្រហែលជាមិនអីទេតាមមើល៍ ពីព្រោះគេជម្លៀសទៅគេមានកន្លែងឲ្យនៅ។ “ថាមិនអីទេតាមមើលទៅ” ថាអ៊ីចឹង។ នោះគឺគាត់មាននិយាយអ៊ីចឹង។

[១០:០៤:៤២]

**ស៖** ហើយគាត់និយាយប្រាប់លោកស្រីយ៉ាងដូច្នេះហ្នឹង ទាល់តែ១ឆ្នាំជាងក្រោយមកហើយ ទេ អ៊ីចឹងអី?

**ឆ៖** ចាស។

**ស៖** ឥឡូវខ្ញុំត្រឡប់មកនិយាយអំពីការស្នាក់នៅរបស់លោកស្រីនៅទីក្រុងភ្នំពេញវិញ។ ម្សិលមិញប្រសិនបើខ្ញុំស្ដាប់មិនច្រឡំទេ គឺថាលោកស្រីបានរៀបរាប់អំពីលក្ខខណ្ឌរស់នៅដែលលំបាកខ្លាំងមែនទែននៅភ្នំពេញនេះ គឺថាម្ហូបអាហារហ្នឹងសឹងតែគ្មានអ្វីទាល់តែសោះ។ លំនៅដ្ឋានពុំមានផាសុកភាពអ្វីទាល់តែសោះ ពុំមានគ្រឿងសង្ហារឹម។ តើអ៊ីចឹងយើងត្រូវយល់ថា នៅពេលហ្នឹងគឺថាលោកស្រីខ្វះចំណីអាហារអីជាដើមហ្នឹង អ៊ីចឹងយើងយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ពេលនោះ ការខ្វះប៉ុណ្ណឹងខ្ញុំមិនទុកជាការខ្វះទេ។

**ស៖** លោកស្រី តើលោកស្រីមានបានឃើញមនុស្សកុមារ ទារក ចាស់ជរា ដែលស្លាប់ដោយដាច់ពោះដែរឬទេ? តើលោកស្រីមានបានឃើញពួកទាំងអស់នេះដែលស្លាប់ដោយដាច់ពោះដែរឬទេ នៅជុំវិញលោកស្រីនោះ?

[១០:០៦:៣៨]

**ផ៖** សូមទោសពេលនោះ នាងខ្ញុំមិនបានចេញទៅណាឲ្យឃើញផ្ទាល់នឹងភ្នែកទេ ហើយក៏អត់ដឹងរឿងហ្នឹងសូម្បីតែបន្តិចក៏អត់មានដែរ។ នៅទីនោះ ខ្ញុំនៅស្ងាត់ឈឹង។

**ស៖** នៅព្រះវិហារ ព្រះវត្តព្រះកែវមរកត ហើយនិងនៅក-១, ក-២ អឺ ក-១, ក-៣ អឺអ៊ីចឹងហ្នឹង គឺថា គេហូបអាហាររួមគ្នាដូច នួន ជា, ដូច អៀង សារី, ដូច វន វ៉េត តើ -- អ៊ីចឹងចង់និយាយថា តើអាហារដូចគ្នាសម្រាប់មនុស្សទាំងអស់គ្នា ឬក៏យ៉ាងម៉េច?

**ផ៖** អាហារដូចគ្នាទាំងអស់។

**ស៖** អ៊ីចឹង គឺថាម្ហូបអាហារហ្នឹង តើមិនគួរជាទីពេញចិត្តទេ អានេះបើតាមខ្ញុំមិន -- តាមខ្ញុំយល់ម្សិលមិញហ្នឹងគឺអ៊ីចឹង។ តើលោកស្រីចង់និយាយអ៊ីចឹងឬក៏យ៉ាងម៉េច? ញុំាមិនឆ្ងាញ់ទេ។ តើលោកស្រីមានបានសង្កេតឃើញថា នួន ជា, អៀង សារី, វន វ៉េត អីហ្នឹងសុទ្ធតែថាអង្គាល់នោះធ្លាក់ខ្លួនស្គមស្គាំងដោយសារអាហារមិនគ្រប់គ្រាន់ ឬក៏យ៉ាងម៉េច?

**ផ៖** អង្គាល់ហ្នឹងអាហារជារួមមិនជាខ្វះម្ហូបអីប៉ុន្មានទេ គ្រាន់តែថាចេញពីសង្គ្រាមមកយើងអត់មានអីហូបហ្នឹង អត់អីក៏អត់ មានអីគឺហូបហ្នឹង។ ចាស មានតែប៉ុណ្ណឹងទេ។

[១០:០៩:០៣]

**ស៖** តើប្តីរបស់លោកស្រីហ្នឹងធ្លាប់បាននិយាយថា -- គាត់ធ្លាប់បានចូលរួមនេះទេ ពិធីជប់លៀងម្ហូបឆ្ងាញ់ទេ? គាត់ធ្លាប់បានចូលកម្មវិធីជប់លៀងហ្នឹង ហើយលោកស្រីធ្លាប់ដឹងទេនៅកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺមានពិធីជប់លៀងអីដែរ ហើយគាត់ធ្លាប់ចូលរួមទេកម្មវិធីជប់លៀងមានម្ហូបអាហារឆ្ងាញ់ៗទេ?

**ផ៖** ពេលហ្នឹងប្តីខ្ញុំដូចអត់មានទេ អត់មានម្ហូបអីឆ្ងាញ់ៗជប់លៀងទេ។ ដូចអត់ដែលឮសួរគាត់និយាយផង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំចង់សូមឲ្យមន្ត្រីតុលាការជួយបញ្ចាំងរូបថតមួយចំនួនលោកប្រធាន។ គឺឯកសារ E190.1.178, E190.1.82, E190.1.122។

បាទ អ៊ីចឹង ខ្ញុំសូមបញ្ចាំងរូបថតទាំងអស់នេះជាបន្តបន្ទាប់។ សូមអនុញ្ញាតលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបង្ហាញឯកសារនៅលើកញ្ចក់ទូរទស្សន៍។

[១០:១២:០៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ខ្ញុំសូមត្រឡប់មកកន្លែងហ្នឹងពេលក្រោយទៅ ព្រោះឥឡូវហ្នឹង មានបញ្ហាបច្ចេកទេស។ ឥឡូវនេះខ្ញុំមានសំណួរផ្សេងមួយទៀត។ លោកស្រីបាននិយាយយ៉ាងវែងអំពីការលំបាករបស់លោកស្រីនៅក្នុងការស្នាក់នៅក-១ និង ក-៣។ ខ្ញុំចង់ដឹងថា លោកស្រីធ្លាប់ -- តើលោកស្រីធ្លាប់ទៅផ្ទះអតីតផ្ទះរបស់ប្ដីលោកស្រីដែរឬទេ? គ្រួសាររបស់ប្ដីលោកស្រីដែរឬទេ? ផ្ទះដែលប្ដីរបស់លោកស្រីនៅភ្នំពេញ ហើយពេលដែលគាត់ចាកចេញពីភ្នំពេញនោះ អង្កាល់ណោះ គាត់មានផ្ទះនៅភ្នំពេញ។ តើលោកស្រីធ្លាប់បានទៅមើលផ្ទះនុំងទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ខ្ញុំអត់ដែរទៅទេ។

**ស៖** លោកស្រីពុំមានសោ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំអត់ដឹងផ្ទះគាត់នៅកន្លែង--

**ស៖** អ៊ីចឹងលោកស្រីមិនដែលធ្លាប់ទៅផ្ទះហ្នឹងទេ អ៊ីចឹងទេ?

**ឆ៖** ចាស អត់ទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកប្រធាន ខ្ញុំសូមជូនឯកសារមួយទៅលោកស្រី គឺឯកសារ E3/385។ គឺជាកំណត់ហេតុស្ដាប់ចម្លើយគាត់ -- អ៎! ចម្លើយសាក្សីមួយដែលយើងនឹងស្ដាប់គាត់នៅថ្ងៃមុខ។ អ៊ីចឹងខ្ញុំមិនអាចផ្ដល់ឈ្មោះសាក្សីនេះបានទេ។ ហើយមេធាវីលោកស្រី សូ សុជាតិ ហ្នឹង នឹងពន្យល់ប្រាប់ថាឈ្មោះសាក្សីដែលផ្ដល់ចម្លើយនេះ គាត់ឈ្មោះអី។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតជូនឯកសារនេះទៅលោកស្រី សូ សុជាតិ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីលោកចៅក្រម យកជូនសាក្សីពិនិត្យ។ ហើយមេធាវីប្រឹក្សាសាក្សីសូមមើលឈ្មោះដែលមានការពាក់ព័ន្ធនឹងសំណួរនេះ ហើយប្រាប់គាត់។ គ្រាន់តែឆ្លើយថាស្គាល់ ឬមិនស្គាល់បានហើយ មិនចាំបាច់បញ្ចេញឈ្មោះនោះទេ។

[១០:១៥:៤២]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកស្រី ខ្ញុំមិនសុំឲ្យលោកស្រីអានកំណត់ហេតុហ្នឹងទាំងស្រុងទេ។ ខ្ញុំគ្រាន់តែសួរថាតើលោកស្រីស្គាល់បុគ្គលរូបហ្នឹងដែរឬទេ ហើយលោកស្រីធ្លាប់ឮគេនិយាយពីគាត់ទេ ហើយលោកស្រីដឹងថាគាត់ជាអ្នកណាទេ?

**ឆ៖** ខ្ញុំមានស្គាល់ឈ្មោះ ឈឿង។ តែ ឡេង ឈឿង ខ្ញុំអត់ស្គាល់ទេ ពីព្រោះត្រកូលគាត់ខ្ញុំអត់ស្គាល់។ ខ្ញុំធ្លាប់ស្គាល់ ឈឿង ជាអ្នកបើកឡានឲ្យគាត់។

**ស៖** បាទ ខ្ញុំព្យាយាមគ្រាន់តែថាចៀសវាងមិនបញ្ចេញឈ្មោះសាក្សីនេះ ឥឡូវវាហួសពេលទៅហើយ។ អ៊ីចឹងគឺជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក ឡេង ឈឿង ហ្នឹងឯង ហើយគឺថាគាត់ហ្នឹងធ្លាប់ជាអ្នកបើកឡានប្តីរបស់លោកស្រី។ តើលោកស្រីស្គាល់បុគ្គលរូបហ្នឹងទេ ឈ្មោះ ឈឿង?

**ឆ៖** ស្គាល់។

[១០:១៦:៥៥]

**ស៖** ហើយលោក ឈឿង នេះគាត់និយាយដូចតទៅនេះ៖ "ខ្ញុំជូន ខៀវ សំផន ទៅផ្ទះម្តាយគាត់នៅម៉ុំបឹងកេងកង។ ផ្ទះគាត់មិនមែនជាកន្លែងសម្រាប់ធ្វើការទេ គឺឃើញតែមានសាឡុង ហើយនិងកៅអីសម្រាប់ទទួលភ្ញៀវ ហើយនិងអគ្រឹងសម្រាប់គាត់សម្រាក មិនមានលេខាផ្ទាល់ និងអ្នកកាន់ទូរលេខទេ--ទូរស័ព្ទទេ សូមទោស។ ប៉ុន្តែនៅក្នុងផ្ទះមានទូរស័ព្ទខ្សែមួយសម្រាប់គាត់ប្រើ។ ពេលដែលគាត់ចេញទៅធ្វើការនៅខាងក្រៅ គាត់ចាក់សោផ្ទះ។ គឺសោនោះនៅហ្នឹងគាត់ ហើយនិងប្រពន្ធគាត់ឈ្មោះ រិន ដែលគាត់សោហ្នឹង។ អ៊ីចឹងតើនេះអ្វីដែលខ្ញុំអាននេះធ្វើឲ្យអ្នកស្រីនឹកឃើញរឿងកាលហ្នឹងទេ?

**ឆ៖** អាហ្នឹង -- ចាសពេលហ្នឹងគឺនៅ ក-៣។ ប្រហែលជាឆ្នាំចិតសិបប៉ុន្មានទេ នៅក-៣។ ផ្ទះហ្នឹងនៅ ក-៣ ដែលគេរៀបចំឲ្យក្រោយ។ ផ្ទះដែលលោក ឈឿង និយាយហ្នឹងគឺនៅ ក-៣។

**ស៖** អ៊ីចឹងហេតុអ្វីក៏លោកស្រីនិយាយអម្បាញ់ថាលោកស្រីមិនដែលធ្លាប់ទៅលេងផ្ទះម្តាយក្មេកលោកស្រីទេ?

[១០:១៨:៥២]

**ផ៖** ផ្ទះម្ដាយក្មេក នាងខ្ញុំធ្លាប់ទៅលេងជាមួយគាត់ តែផ្ទះហ្នឹងគឺជាផ្ទះគ្រាន់តែនៅមិនមែនជាផ្ទះ មិនមែនជាផ្ទះរបស់គាត់ទេ ផ្ទះគេរៀបចំឱ្យនៅ។ ក្រោយពេលបានប៉ុន្មានខែមកហ្នឹងបានគេយកគាត់មក ហ្នឹងខ្ញុំបានទៅលេង។ សូមទោសអំមិញលោកបានសួរខ្ញុំថា ផ្ទះរបស់របស់លោក ខៀវ សំផន ដែលធ្លាប់នៅភ្នំពេញ។ អាហ្នឹងខ្ញុំអត់ដែលសោះ អត់ដឹង។ តែដែលលោក ឈឿង និយាយនេះគឺឃើញផ្ទះដែលគាត់ធ្លាប់នាំទៅនេះ ផ្ទះដែលនៅក្រោយពេលដែលភ្នំពេញរំដោះ។

**ស៖** តើអ្នកស្រីធ្លាប់បានជួបម្ដាយក្មេកអ្នកស្រីទេ?

**ផ៖** ចាស ខ្ញុំបានជួប។

**ស៖** តើនៅពេលជម្លៀសទីក្រុងភ្នំពេញនោះគាត់ពួន តើគេរកឃើញគាត់ ប្ដីរបស់លោកស្រីនោះបានជួបម្ដាយគាត់ឡើងវិញតាមរបៀបណា?

**ផ៖** កាលនោះតាមខ្ញុំដឹង ម្ដាយគាត់ចេញទៅរកគាត់នៅវត្ត នៅវត្តលោក ហើយដល់ចេញពីវត្តលោក ហ្នឹងទៅតាមភូមិអ្នកដែលស្គាល់ៗចេះតែសួរគេ ទៅបានទៅជួបគាត់នៅព្រៃ។

**ស៖** អ៊ីចឹងបើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាម្ដាយក្មេករបស់លោកស្រីហ្នឹងចាកចេញពីទីក្រុងភ្នំពេញតាំងពីមុនពេលដែលភ្នំពេញត្រូវបានគេជម្លៀសទៀត អ៊ីចឹងមែនទេ? គាត់បានចាកចេញពីភ្នំពេញមុនថ្ងៃ១៧ មេសា ហ្នឹងទៀត ឬក៏ក្រោយថ្ងៃ១៧ មេសា?

**ផ៖** ចេញតាំងពីមុន។

[១០:២២:០៤]

**ស៖** ដូច្នេះគាត់បានរកកូនគាត់ឃើញ។ ហើយគាត់រកកូនគាត់ឃើញនៅក-១៧, ប-២០ នៅស្ទឹងជីនិតនៅកន្លែងណា?

**ផ៖** នៅ ១៧ ពេលដែលខ្ញុំសម្រាលហើយ គាត់ក៏មកដែរ។

**ស៖** តើគាត់ដឹងថាត្រូវទៅរកប្ដីរបស់លោកស្រីហ្នឹងតាមរបៀបណា? តើលោក ខៀវ សំផន បានសុំឱ្យម្ដាយខ្លួននោះទៅជួបខ្លួន ឬក៏យ៉ាងម៉េច?

**ផ៖** បើតាមគាត់ធ្លាប់និយាយប្រាប់ខ្ញុំ គឺគាត់ចេញមកដោយគាត់នៅកន្លែងនៅភ្នំពេញមិនបាន ព្រោះអីគាត់ខ្លាច ដែលកូនចេញមកហើយគាត់ខ្លាចដែរ ដូច្នេះគាត់ទៅនៅវត្ត។ បានគាត់ចេញពីវត្តមក គាត់ចេញទៅភូមិ។ ចេញពីភូមិហ្នឹងគឺស្គាល់គេស្គាល់ឯងអ៊ីចឹងទៅ ចេះតែជិះរទេះជិះអីទៅជាមួយគេ។

ទៅភូមិហើយចេះតែសួរគេត១ទៅ ហើយពេលនោះតាមមើលមានអ្នកដែលដូចជា នៅតាមភូមិតាមឃុំ ដែលរំដោះហើយខ្លះគេស្គាល់, តាមឮគាត់និយាយ, ដល់អ៊ីចឹងគេចេះតែនាំគាត់មក។ តែខាងគាត់ដូចអត់ដឹងទេ គាត់ប្រាប់ខ្ញុំគាត់ថាគាត់អត់ដឹងដែរហ្នឹង។ ស្រាប់តែទៅឃើញ។ គាត់ថាអត់ដឹងសោះ អត់ដឹងម្ដាយគាត់ទៅសោះ។

[១០:២៤:១៨]

**ស៖** ហើយម្ដាយក្មេករបស់លោកស្រីហ្នឹង គាត់មានបានព្យាយាមចង់ដឹងថា កូនផ្សេង១ទៀតរបស់គាត់នៅកន្លែងណាទេ គឺថាក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលទីក្រុងភ្នំពេញហើយ? តើលោកស្រីដឹងថាបងប្អូនរបស់គាត់ទាំងអស់ គឺថាបងប្អូនថ្លៃរបស់លោកស្រីទាំងអស់ហ្នឹងក្លាយជាអីហើយសព្វថ្ងៃនេះ?

**ឆ៖** ក្រោយរំដោះហើយគាត់ព្យាយាមដែរ គាត់ខំសួររក ក៏ប៉ុន្តែពេលហ្នឹងយើងខ្ញុំក៏មិនដឹងថានេះដែរ ព្រោះខ្ញុំធ្លាប់និយាយជាមួយគាត់ដែរ, ខ្ញុំថា“ហ៊ឺ! មិនដឹងយ៉ាងម៉េចទេ ម៉ែមិននៅអីណាអីណី ហើយខ្ញុំក៏អត់ដឹង”។ គាត់ក៏ធ្លាប់និយាយដែរ។

**ស៖** បាទ ឥឡូវយើងដូរប្រធានបទ ព្រោះថាបើនិយាយបន្តទៀតក៏ដូចជាមិនទៅវែងឆ្ងាយអីដែរ។ លោកស្រីបាននិយាយថា លោកស្រីមិនដែលមានឱកាសចាកចេញពីទីក្រុងភ្នំពេញទេ តើអ៊ីចឹងមែនទេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងលោកស្រីនៅភ្នំពេញជាប់រហូត ឬក៏លោកស្រីធ្លាប់មានឱកាសធ្វើការផ្លាស់ទីធ្វើដំណើរទៅណាទៅណីនៅក្នុងប្រទេសដែរ?

**ឆ៖** នាងខ្ញុំអត់ដែលមានបានចេញទៅណាទេ ក្រៅពីនៅផ្ទះ។ មានម្ដងម្កាលចេញតែជិត១ ប៉ុន្តែយើងខ្ញុំអត់ចាំទេ។ ជិត១ដូចទៅលេងម្ដាយ ដូចទៅក-១ ។

[១០:២៦:៤៥]

**ស៖** ពេលដែលលោកស្រីនិយាយថា ទៅលេងម្ដាយនេះ តើលោកស្រីចង់សំដៅទៅម្ដាយក្មេក ឬក៏ម្ដាយបង្កើត?

**ឆ៖** ចាស ខ្ញុំទៅលេងម្ដាយក្មេក។

**ស៖** តើលោកស្រីធ្លាប់ជូនស្វាមីរបស់លោកស្រីនៅពេលដែលគាត់ទស្សនកិច្ចជនបទជាមួយសម្ដេច សីហនុ ហើយនិងមហេសីរបស់ព្រះអង្គ? តើលោកស្រីធ្លាប់ធ្វើ ជូនគាត់ទៅធ្វើទស្សនកិច្ចទេ?

**ឆ៖** ចាស អត់ដែលទេ។

**ស៖** បាទ កំណត់ហេតុស្តាប់ចម្លើយរបស់ គឹម វុន ឯកសារ E3/380 ERNជាភាសាបារាំងគឺ 00485434, ជាភាសាអង់គ្លេសគឺ 00365646។ បាទ សាក្សីនេះនិយាយដូចតទៅនេះ៖

"នៅពេលដែលសម្តេច សីហនុ និងសម្តេច ប៉ែន នុត ចុះទៅតាមសហករណ៍ ខ្ញុំឃើញ ខៀវ សំផន និងប្រពន្ធរបស់ ខៀវ សំផន ចុះតាមរហូត។ ខ្ញុំដឹងរឿងនេះដោយសារ ខ្ញុំចង់ទៅយកព័ត៌មាននៅតាមសហករណ៍ ហើយខ្ញុំបានឃើញពួកគាត់ដោយផ្ទាល់ភ្នែក"។ អ៊ីចឹងតើសាក្សីនេះគាត់ច្រឡំ ឬក៏យ៉ាងម៉េចលោកស្រី?

**ឆ៖** ចាស សូមទោស ខ្ញុំអត់ដែលសូម្បីតែម្តង ក៏ខ្ញុំមិនដែលចេញទៅជាមួយសម្តេច លោកអគ្គមហេសី ឬលោកតា ប៉ែន នុត។ សូម្បីតែម្តង សូម្បីតែឃើញមុខក៏មិនដែល អត់សោះតែម្តង។ មិនដឹងជាសាក្សីគេឃើញអ្នកណា ខ្ញុំអត់សោះ ហ្នឹងសូមជម្រាបដោយស្មោះ។

[១០:២៩:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ អរគុណសាក្សី។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក

ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ឥឡូវនេះ ខ្ញុំសូមស្នើសុំបង្ហាញរូបថតទាំងបួនដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ហើយសូមឲ្យចាប់ផ្ដើមដោយរូបថត E190.1.143។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកស្រីនៅក្នុងរូបថតនេះ តើលោកស្រីស្គាល់អ្នកណាខ្លះទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស ក្នុងរូបថតនេះ ខ្ញុំស្គាល់លោក ខៀវ សំផន និង អៀង សារី។

**ស៖** ក្នុងនេះ គឺថាមានការចូលរួមក្នុងពិធីលៀងសាយភោជ ហើយយើងឃើញមើលទៅ លោក អៀង សារី និងអ្នកចូលរួមនោះ ដូចជាមានសុខភាពល្អ។ ដូច្នេះ ខ្ញុំដឹងថាលោក អៀង សារី នេះ គឺជាមនុស្សទី២ បើយើងរាប់ពីឆ្វេងទៅ នៅក្នុងរូបថតនេះ។ បាទ នៅក្នុងនេះគឺថាលោក អៀង សារី គឺថាជាមនុស្សទី២ បើយើងរាប់ពីស្ដាំទៅ តើអ៊ីចឹងមែនទេ? -- បើរាប់ពីឆ្វេង សូមទោស។

[១០:៥៥:១៥]

**ឆ៖** ចាស មែន។

**ស៖** ហើយប្ដីលោកស្រី បើយើងមើលទៅ ឃើញថានៅកណ្ដាលគេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាសមែន។

**ស៖** ឥឡូវនេះចូលទៅរូបថតមួយទៀត គឺ E190.1.178។ ដូច្នេះសូមរក្សារូបថតនៅអេក្រង់ឲ្យនៅជាប់។ លោកស្រី តើលោកស្រីស្គាល់អ្នកណាខ្លះនៅក្នុងរូបថតនេះ?

**ឆ៖** លោក ខៀវ សំផន។ ហើយម្នាក់ទៀតប្រហែល -- អត់សូវច្បាស់ ប្រហែលលោក នួន ជា មិនដឹងមែនអត់ទេ។

**ស៖** ដូច្នេះក្នុងរូបនេះគឺថា នួន ជា នៅខាងស្ដាំផុត ហើយនៅកណ្ដាលនោះយើងឃើញប្ដីរបស់លោកស្រីនោះ កំពុងតែអង្គុយនៅលើសាឡុង។ រូបថតមួយទៀតគឺ E190.1.82។ បាទសំណួរដដែល តើលោកស្រីស្គាល់អ្នកខ្លះនៅក្នុងរូបថតនេះ?

[១០:៥៨:១០]

**ឆ៖** លោក អៀង សារី ហើយនិងលោក ខៀវ សំផន។

**ស៖** ឯកសារមួយទៀតនោះ គឺលេខ E190.1.122។ បាទអ៊ីចឹង លោកស្រីស្គាល់អ្នកខ្លះនៅក្នុងរូបថតនេះ?

**ឆ៖** លោក ខៀវ សំផន, លោក អៀង សារី។

**ស៖** លោក ខៀវ សំផន គឺថានៅខាងឆ្វេងដៃ ហើយលោក អៀង សារី នៅកណ្ដាល។ អម្បាញ់មិញនេះលោកស្រីឆ្លើយថាលោក ខៀវ សំផន មិនដែលនិយាយថា គាត់បានចូលរួមនៅក្នុងពិធីលៀងសោយភោជ ឬក៏ហូបចុកអីឆ្ងាញ់នោះទេ។ ឥឡូវនេះ តើលោកស្រីនៅតែរក្សាចម្លើយនេះដដែលឬ?

**ឆ៖** ចាស ខ្ញុំនៅរក្សា ព្រោះខ្ញុំអត់ដឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីបរិយាកាសនៅ ក-១ និងក-៣។ ខ្ញុំចង់និយាយអំពីបរិយាកាសការងារ និងទំនាក់ទំនងរវាងលោក ខៀវ សំផន, លោក នួន ជា, ប៉ុល ពត ឬ អៀងសារី ឬក៏មេដឹកនាំផ្សេងទៀតដែលនៅក-១, ក-៣។ តើបរិយាកាសនៅទីនោះជាបរិយាកាសរីករាយ លោកស្រីឃើញមនុស្សមានការខឹងសម្បាគ្នាឬទេ ឬក៏មានការមិនឯកភាព ឬមួយក៏ប្ដីលោកស្រីបានបញ្ជាក់ថាមានការភ័យខ្លាច។ តើយ៉ាងម៉េចដែរបរិយាកាសនោះ ជាបរិយាកាសធូរស្រាល ឬក៏មានការភ័យខ្លាច?

[១០:៥៩:៥១]

**ឆ៖** ចាស នាងខ្ញុំឃើញបរិយាកាសធម្មតា អត់មានអ្នកណាភ័យខ្លាច។

**ស៖** ខ្ញុំចង់អានន្ទូវសម្រង់នៃសៀវភៅដែលសរសេរដោយប្ដីរបស់លោកស្រី។ ឯកសារនេះគឺលេខ E3/18។ ឯកសារនេះមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"។ សម្រង់គឺនៅ ERN ជាភាសាបារាំង 00595436 ទៅដល់ 37, ERNជាភាសាអង់គ្លេស 00103754 ទៅដល់ 55។ ខ្ញុំសូមអភ័យទោសផងខ្ញុំអត់មានERN ជាភាសាខ្មែរទេ។

លោក ខៀវ សំផន គាត់បានរៀបរាប់អំពីកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលគាត់បានចូលរួម។ គាត់រៀបរាប់ថា វាដូចគ្នាទៅនឹងកិច្ចប្រជុំរវាងសមមិត្ត ឬក៏កិច្ចប្រជុំក្នុងគ្រួសារអ៊ីចឹង។ ខ្ញុំសូមដកស្រង់ "ការប្រជុំម្ដងៗជាញឹកញយការប្រជុំច្រើនតែរាលកៃ ទៅជាសើចលេងទៅលើរឿងអ្វីមួយអស់រយៈពេលយ៉ាងយូរ"។ នៅពេលដែលលោក ខៀវ សំផន គាត់ត្រឡប់មកពីធ្វើការវិញតើគាត់មានប្រាប់លោកអំពីរឿងការនិយាយលេងសើចគ្នាដែលគាត់បានស្ដាប់ឮទេ?

[១១:០២:៤៩]

**ឆ៖** ខ្ញុំមិនចាំអស់ ប៉ុន្តែមានពេលខ្លះដែរ ដូចជាពេល -- និយាយទៅមានខ្លះគាត់និយាយពីរឿងអ្នកលក់ឪឡឹក អ្នកធ្វើអីទេខ្ញុំមិនចាំ។ ដូច្នេះនិយាយទៅរឿងសើច -- គាត់មកនិយាយប្រាប់ខ្ញុំដែរអារឿងអ៊ីចឹង។ ឧទាហរណ៍ថានិយាយលេងពីរឿងអ្នកនេះកំប្លែងអី និយាយរឿងលក់ឪឡឹកលក់អ៊ីចឹង។ ទិញឪឡឹកមួយទៅលក់បានប៉ុននេះថាខ្លួនឯងចំណេញអាហ្នឹងអីមាន។ ប៉ុន្តែថាឲ្យមានអីធំដុំលើសហ្នឹងអត់មានទេ ប៉ុន្តែមានរឿងរ៉ាវអីច្រើនទៀតខ្ញុំមិនចាំទេ មានភាសាលេងច្រើនដែរ។ អាហ្នឹងគាត់មកនិយាយប្រាប់ដើម្បីសើចលេង។

**ស៖** សូមអរគុណ។ គាត់បន្តរៀបរាប់ទៀតថា "ដោយម្នាក់ៗដាក់ជំនឿឥតព្រំដែនលើ ប៉ុល ពត គេក៏ច្រើនតែទទួលមតិវិភាគ និងការលើកស្នើវិធានការរបស់ ប៉ុល ពត ដោយមិនសូវបានជជែកវែកញែកអ្វីជ្រៅជ្រះហ្មត់ចត់ទេ។ ជំនឿនេះក៏ហាក់ដូចជាមិនរង្គោះរង្គើទេ។ ក្រោយមានការចាប់ចងគណៈមជ្ឈិមណាមួយ ឬក្រោយមកទៀតមានការចាប់ចងសមាជិកគណៈអចិន្ត្រៃយ៍ក៏ដោយ។ ការបាត់មុខអ្នកទាំងអស់នោះម្ដងមួយៗហាក់ដូចជាបានត្រូវសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀតដែលគេដឹងរឿង ចាត់ទុកថាជាករណីដាច់ពីគ្នាហើយជាវិធានការត្រឹមត្រូវ"។

តើប្ដីរបស់លោកស្រីមានធ្លាប់ប្រាប់លោកស្រីអំពីការគិតពិចារណារបស់គាត់នៅពេលដែលមានអ្នកណាម្នាក់ដែលនៅជុំវិញខ្លួនលោកស្រីបាត់ខ្លួនដែរឬទេ?

[១១:០៤:៥០]

**ឆ៖** ចាស ដែលគាត់ធ្លាប់និយាយគឺមានតែលោក -- អាហ្នឹងក្រោយមកទេ -- លោក ហ៊ូ នឹម, ហ៊ូ យន់ ដែលគាត់ធ្លាប់និយាយថា ជាមិត្តជិតស្និទ្ធរបស់គាត់ អាហ្នឹងគួរ មិនគួរណាបាត់ស្អីៗ។ អាហ្នឹងគាត់មាននិយាយ។ ហើយក្រៅពីនោះ ខ្ញុំអត់ៗមានដែលនិយាយទេ។

**ស៖** ចុះហេតុអ្វី? ចុះចំពោះលោកស្រី តើពាក្យថា "បាត់ខ្លួន" នេះ តើមានន័យយ៉ាងម៉េចដែរបាត់ខ្លួន?

**ឆ៖** ពេលនោះ នាងខ្ញុំមិនៗចាប់អារម្មណ៍អារឿងបាត់ខ្លួនអីនេះទេ ពីព្រោះគេមានកន្លែងរៀងៗខ្លួន អត់មានបាត់ចាប់អារម្មណ៍ថាគេនេះ អីអត់។ អត់ដឹងថា អ្នកហ្នឹងទៅណាមកណាទេ ដឹងតែទៅធ្វើការកន្លែងគេ។

**ស៖** តើលោកស្រីមានចាប់អារម្មណ៍ចង់ដឹងថា មិត្តភក្តិរបស់គាត់ប្ដីលោកស្រីគាត់មានហេតុ-ការណ៍អ្វីកើតឡើងចំពោះពួកគេទេ ឬក៏ចាប់អារម្មណ៍ដឹងតែពីសមាជិកគ្រួសារសាច់ថ្លៃនោះ?

[១១:០៦:២៥]

**ឆ៖** ក្រោយមកគាត់បានចាប់អារម្មណ៍ ហើយនឹកឡើងវិញ គាត់ថាចុះហេតុអីបានជាពួកហ្នឹងអ៊ីចឹង។ ហ្នឹងគាត់មានចម្ងល់នៅជាមួយខ្ញុំដែរ។ ហេតុអីបានពួកហ្នឹងអ៊ីចឹង។ អាហ្នឹងគាត់មានតែចម្ងល់តែប៉ុណ្ណឹង គាត់ក៏អត់មានអីតទៀតដែរ។

**សៈ** ឥឡូវនេះ យើងនិយាយអំពីគ្រួសារផ្ទាល់របស់លោកស្រីម្តង។ លោកស្រីបានបញ្ជាក់ថាលោកស្រីមកពីតំបន់មួយដែលយើងហៅថា តំបន់១០៣ កាលពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកស្រីដឹងអំពីការបោសសម្អាតនៅក្នុងតំបន់១០៣ដែរឬទេ? តើលោកស្រីដឹងអំពីការចាប់ខ្លួនសមាជិកគ្រួសាររបស់លោកស្រីមួយចំនួនដែរឬទេ? តើលោកស្រីបានដឹងអំពីការធ្វើបាបអ្នកទាំងអស់នុ៎ងដែរឬទេ? ប្រសិនបើលោកស្រីដឹង តើលោកស្រីដឹងតាមរបៀបណា?

**ឆ៖** កាលនោះចំពោះនៅ១០៣ នាងខ្ញុំអត់មានដឹងស្អីបន្តិចសោះ អត់។ សូម្បីតែក្រុមគ្រួសារបងប្អូនរបស់នាងខ្ញុំដែលត្រូវគេចាប់ក៏អត់ដឹងអស់រយៈពេល១ឆ្នាំ។

**សៈ** តើនៅពេលណា? ហើយលោកស្រីដឹង ដឹងដោយរបៀបណា?

[១១:០៨:៤៦]

**ឆ៖** មានថ្ងៃមួយខាង -- គេដោះលែងមកវិញ ប្រហែលជាឆ្នាំ៧៨ ចុងហើយជិតវៀតណាមចូលមកហើយ គេដោះលែងមកវិញហើយ ពេលនោះមានបងប្អូនម្នាក់ដែលបងគាត់ត្រូវជាប់ដែរ មកដែរ ហើយគាត់នៅ -- អង្កាល់នុ៎ងគាត់នៅក-១។ ហើយគាត់ដឹងអ៊ីចឹង ហើយគាត់ផ្តាំមកខ្ញុំ, គាត់ថា “នែ៎មានបងមិត្តឯងនៅដែលគេចាប់ណ៎! មកនៅតាខ្មៅ” ខ្ញុំថា “អ្ហ៎! ពីណា?” គាត់ថា “មានបងប្រុស ប្អូនប្រុសបងជីដូនមួយ”។ ពេលនោះហើយដែលខ្ញុំដឹង។

**សៈ** លោកស្រី ខ្ញុំសូមអានសម្រង់ចេញពីសៀវភៅប្តីរបស់លោកស្រី គឺលេខ E3/18 គឺសៀវ-ភៅដែលហ្នឹង គឺថា “ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗ និងគោលជំហរជាបន្តបន្ទាប់របស់ខ្ញុំ”។ ERN ជាភាសាបារាំង 00595513, ERN ជាភាសាអង់គ្លេស 00103793។ នៅក្នុងសៀវភៅនេះ ប្តីរបស់លោកស្រីបានសរសេរថា -- គឺលោកស្រីហ្នឹងមកយំ ដែលហើយមករៀបរាប់ប្រាប់អំពីសភាពសាហាវឃោរឃៅដែលប្រព្រឹត្តចំពោះបងប្អូនរបស់លោកស្រី ហើយនិងសាច់ញាតិរបស់លោកស្រី។ តើពិតជាអ៊ីចឹងមែនទេ គឺថាលោកស្រីយំ ហើយរៀបរាប់ប្រាប់គាត់ថាមានគេធ្វើបាប ប្រព្រឹត្តសាហាវឃោរឃៅចំពោះក្រុមគ្រួសាររបស់លោកស្រីនោះ?

[១១:១០:៥៥]

**ផ៖** ចាស ពិតមែន។

**ស៖** ខ្ញុំពិតថាប្រហែលជាមានបញ្ហាទៀតហើយ ព្រោះថាខ្ញុំអត់ទទួលបានចម្លើយលោកស្រីជាភាសាបារាំងទេ។ ខ្ញុំឃើញថាលោកស្រីពិតជាឆ្លើយថា មែនហើយ ក៏ប៉ុន្តែខ្ញុំអត់ទទួលបានការបកប្រែទេ។ អ៊ីចឹងសូមឲ្យលោកស្រីឆ្លើយម្តងទៀត។

**ផ៖** ចាស ពិតមែន។

**ស៖** បើតាមលោកស្រីនោះ តើរឿងនេះកើតឡើងមុនពេលដោះលែងសមាជិកគ្រួសារលោកស្រីឬក៏ក្រោយ?

**ផ៖** រឿងនេះគឺក្រោយពេលគេដោះលែងបងប្អូនខ្ញុំ ហើយរួមជាមួយនឹងឪពុកម្តាយខ្ញុំ។ ឪពុកម្តាយខ្ញុំក៏គេចាប់ទៅដែរ។

**ស៖** ដូច្នេះលោកស្រីដឹងថា សមាជិក ក្រុមគ្រួសាររបស់លោកស្រី សាច់ញាតិរបស់លោកស្រីត្រូវបានគេចាប់ខ្លួន ហើយលោកស្រីក៏ដឹងថាគេដោះលែងទៀត។ ដូច្នេះតើលោកស្រីគិតថា លោក ខៀវ សំផន អន្តរាគមន៍ជួយទេបានជាមានការដោះលែងក្រុមគ្រួសារលោកស្រីនោះ?

[១១:១២:៥៥]

**ផ៖** នៅពេលនោះមិនមានប្តីខ្ញុំអន្តរាគមន៍ទេ គឺខាងក្រសួងការបរទេសដែលគេទៅធ្វើការនៅសៀមរាបគេឃើញមានអ្នកដែលស្គមស្គាំមកបោសសំរាម បោសអីនៅតាមផ្លូវ ហើយគេចេះតែឆ្ងល់ម្តងជាពីរដង។ អាហ្នឹងតាមការដឹងយល់ខាងក្រោយពេលក្រោយមកហើយនេះទេ ជាពិសេសគឺពេលដែលវៀតណាមចូលនេះ ហ្នឹងបងប្អូនតែងតែមកជុំគ្នា និយាយគ្នា។ គឺអ្នកទាំងអស់គ្នាឃើញជាញឹកញាប់អ៊ីចឹងហើយបានគេក៏រាយការណ៍មកឲ្យ ប៉ុល ពត ជាពិសេសខាងក្រសួងការបរទេស ហើយ ប៉ុល ពតក៏ឲ្យគេតាមដាន ហ្នឹងតាមព្យួរគេនិយាយ។ តាមដានហើយ បានសម្រេចឲ្យដោះលែង។ ហើយដោះលែងៗទាំងអស់មិនមែនតែក្រុមគ្រួសារសាច់ញាតិរបស់ខ្ញុំទេ គឺគ្នាប្រហែលខ្ញុំទៅឃើញនៅកន្លែងតាខ្មៅ -- កាលហ្នឹងខ្ញុំលួចទៅ។ ហើយសូម្បីតែប្តីខ្ញុំក៏អត់ដឹងដែរ ខ្ញុំទៅជាមួយអ្នកបើកឡាន គេដឹកអីវ៉ាន់ទៅ។

ហើយឃើញគ្នាច្រើន ស្គមស្គាំ។ កន្លែងហ្នឹងគេទៅឲ្យបាយ ឲ្យអីហូប បំប៉ន គេថាបំប៉ន។ ខ្ញុំសួរបងប្អូនខ្ញុំទៅគេថាបំប៉ន។ គេយកមកឲ្យហូបបាយវិញ ចំនួនប្រហែលជារាប់រយនាក់ដែរជាមួយបងប្អូនខ្ញុំ។

[១១:១៤:៤៧]

**ស៖** តើប្តីរបស់លោកស្រីបានទទួលព័ត៌មានអំពីសមាជិកក្រសួងការបរទេស ដែលថាគាត់មិនបានចែករំលែកព័ត៌មានជាមួយលោកស្រី ពាក់ព័ន្ធទៅនឹងការធ្វើបាបមនុស្សនៅតំបន់សៀមរាបដែរឬទេ?

**ឆ៖** ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំក៏សួរគាត់ យំហើយសួរគាត់ "ហេតុអីបានអ៊ីចឹង ហើយពុកឯងអត់ដឹងទេ?" គាត់ថា "សូម្បីតែពួ មិនពួផង អត់ដឹងទេ ខ្ញុំអត់ដឹងទេ។ អារឿងអ៊ីចឹងៗ គេមិនដែលប្រាប់ខ្ញុំទេ សូម្បីតែពួកម៉ាក អាអ្នកដែលជិតស្និទ្ធនេះ គេធ្វើអី ក៏ខ្ញុំអត់ដឹងដែរ"។ អាហ្នឹងគាត់និយាយអ៊ីចឹង "ហើយគេទៅណាក៏ខ្ញុំមិនដឹងទៀត ហើយខ្ញុំអត់ដឹងសោះ"។ ហើយគាត់សួរថា "ពីអ្នកណាអ្នកចាប់? មានដឹងទេ?" ហ្នឹងគាត់សួរខ្ញុំវិញ។

**ស៖** ដូច្នេះ ដើម្បីទទួលព័ត៌មានពាក់ព័ន្ធនឹងការឡើងនៅប្រទេសកម្ពុជា ឧទាហរណ៍ដូចជាការធ្វើបាបមនុស្សអ៊ីចឹង គឺថាលោកស្រីទេជាអ្នកនិយាយនោះ មិនមែន ប៉ុល ពត ឬ នួន ជា ឬក៏អ្នកទំនាក់ទំនងផ្សេងទៀតជាអ្នកនិយាយ។ អ៊ីចឹងទេ?

**ឆ៖** សូមទោសលោកប្រធានម្តងទៀត ស្តាប់អត់បាន។ សូមទោសៗ ម្តងទៀត ខ្ញុំស្តាប់អត់បាន។

[១១:១៦:៤៦]

**ស៖** ខ្ញុំចង់ដឹងថា-- បើតាមការស្តាប់ចម្លើយរបស់លោកស្រីហ្នឹងទៅហ្នឹង គឺថាដើម្បីទទួលបានព័ត៌មានអីមួយអំពីការកើតឡើងនៅប្រទេសកម្ពុជានោះ។ ឧទាហរណ៍ដូចជាការធ្វើបាបមនុស្សជាដើមហ្នឹង គឺប្តីរបស់លោកស្រីហ្នឹងមកសួរលោកស្រីទៅវិញនេះ ដែលជាគ្រាន់ជាអ្នកចុងភៅនេះ គាត់មកសួរលោកស្រីដើម្បីទទួលព័ត៌មាន គាត់មិនទទួលព័ត៌មានពីផ្នែកផ្សេង ពីខ្សែបណ្តាយផ្សេងទេ គឺថាមិនមែនមកពីអ្នកដែលគាត់ទំនាក់ទំនងជាមួយរៀលថ្ងៃ ដូចជា នួន ជា, ប៉ុល ពត អីទេ។ គឺគាត់មិនបានទទួលទូលេខអីទេ អត់មានទទួលព័ត៌មានអីសោះ គឺថាពេលដែលចង់ដឹងព័ត៌មាន មកសួរលោកស្រីទៅវិញ។ អ៊ីចឹងមែនទេ?

**ឆ៖** ព្រោះពេលហ្នឹងខ្ញុំប្រាប់គាត់ៗ ហើយគាត់ក៏អត់ដឹងរឿង។ មិនដឹងជាខាងបណ្តាញអីផ្សេងគេដឹង ឬមួយក៏គាត់សួរអី ខ្ញុំអត់ដឹងដែរអាហ្នឹង។ ប៉ុន្តែពេលហ្នឹង ដែលខ្ញុំប្រាប់គាត់ហើយ គាត់សួរខ្ញុំអ៊ីចឹង។ គាត់សួរខ្ញុំអ៊ីចឹង ហើយខ្ញុំក្តាប់បានដែលគេនិយាយ ដែលខ្ញុំទៅជួបបងប្អូនខ្ញុំ ខ្ញុំក៏និយាយប្រាប់តាមហ្នឹង។

[១១:១៨:២៥]

**ស៖** សម្រាប់ជាកំណត់ត្រាប្រតិចារឹកសវនាការនោះ នៅក្នុងឯសការ យើងមានឯកសារមួយដែលជាកំណត់ហេតុស្តាប់ចម្លើយសាក្សី មាស វឿន។ ឯកសារ E3/424 ដែលនិយាយអំពីរបាយ-ការណ៍ដែលផ្ញើជូនលោក ខៀវ សំផន តាមទូលេខ។ យើងក៏មានកំណត់ហេតុ E3/420 ដែលជាកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយទៀតដែលឈ្មោះថា ព្រំ ស៊ូ ដែលគាត់បានមកផ្តល់សក្ខីកម្មរួចមកហើយ។

ដូច្នេះ លោកស្រីមិនដែលឮគេនិយាយអំពីទូលេខដែលគេផ្ញើជូនលោក ខៀវ សំផន ទេ មែនទេ? តើលោកស្រីមានស្តាប់ឮការចាប់ខ្លួនមនុស្សម្នាក់ឈ្មោះ ជូ ជេត ទេ។ ធ្លាប់ឮពីការចាប់ខ្លួនគាត់ទេ? ហើយចុះ កុយ ធួន? ប៉ង់? ឌឿន? ទីវ អុល? លោកស្រីធ្លាប់ឮគេនិយាយអំពការចាប់ខ្លួនបុគ្គលទាំងអស់នេះទេ នៅពេលដែលលោកស្រីនៅ ក-១ ឬក៏នៅ ក-៣ នោះ?

**ឆ៖** រឿងទាំងអស់នេះ នាងខ្ញុំអត់ដែរឮទេ។

[១១:២០:០៥]

**ស៖** តើលោកស្រីធ្លាប់ឮគេនិយាយថាមានខ្មាំង ខ្មាំងខាងក្នុង ឬក៏ខាងក្រៅជួរ ខ្មាំងស៊ីរូងផ្ទៃក្នុង គឺថាលោកស្រីធ្លាប់ឮទេថាមានខ្មាំង ហើយត្រូវតែបោសសម្អាតឲ្យអស់នោះ?

**ឆ៖** នៅក្នុងមន្ទីរមានតែគេនិយាយ គឺថាប្រុងប្រយ័ត្ន ព្រោះកុំឲ្យបែកការណ៍ មានខ្មាំងចង់បំផ្លាញយើង ដូច្នេះយើងត្រូវប្រុងប្រយ័ត្ន។ ឯខាងក្នុង ខាងក្រៅ អាហ្នឹងគេមិនសូវ គេអត់ងាយនិយាយប្រាប់ខ្ញុំទេ។ សូម្បីតែផ្ទះបាយក៏គេឲ្យប្រុងប្រយ័ត្ន។ ចាស ខ្ញុំមានប៉ុណ្ណឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។ បាទជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅ តំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១១:២១:៣២]

**លោក ឃីត រេយ៉ន៍រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោក លោកស្រីមេធាវីការពារក្តី ហើយនិងភាគីទាំងអស់។ ជម្រាបសួរលោកស្រី សូ សុជាតិ ផងដែរ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** នៅក្នុង១៥នាទីចុងក្រោយនេះ លោកស្រីបានផ្តល់ភស្តុតាងដូចតទៅនេះថា លោកស្រីមានការសន្ទនាដោយផ្ទាល់ជាមួយប្តីរបស់លោកស្រី អំពីមនុស្សពីរនាក់ គឺហ៊ូ យន់ ហើយនិង ហ៊ូ នឹម។ ដែលថាប្តីរបស់លោកស្រីប្រាប់លោកស្រីថា អ្នកទាំងពីរនាក់នេះបានបាត់ខ្លួន ហើយថាពួកគេមិនគប្បីត្រូវបាត់ខ្លួនទេ។ ខ្ញុំសួរលោកស្រីថា តើការសន្ទនាជាមួយប្តីលោកស្រីនោះនៅក្នុងថ្ងៃខែឆ្នាំណាដែរទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស នាងខ្ញុំមិនចាំថ្ងៃ មិនចាំខែទេ ប៉ុន្តែក្រោយមកហើយទេ។ មានឮការកាប់សម្លាប់ចាប់ចងអីច្រើនអីចឹងទៅ គាត់ហើយនិងខ្ញុំនិយាយរឿងហ្នឹង។ អាហ្នឹងយូរមកហើយ ក្រោយវៀតណាមចូលមកភ្នំពេញហើយទេ។ ពីមុនមកមិនបានដឹង ហើយបាននិយាយអីរឿងហ្នឹងទេ។

[១១:២៤:១៣]

**ស៖** ប្តីរបស់លោកស្រីបានប្រាប់លោកស្រី នៅក្នុងបរិបទអំពីការចាប់ខ្លួនមនុស្សច្រើន ហើយនិងការសម្លាប់មនុស្សចំនួនច្រើន ហើយថាគាត់បានដឹងថា ហ៊ូ យន់ ហើយនិងហ៊ូ នឹម ត្រូវបានគេចាប់ខ្លួន ហើយក៏បាត់ខ្លួន។ តើសេចក្តីនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមបញ្ជាក់ ពេលដែលគាត់និយាយជាមួយខ្ញុំ គឺពេលក្រោយ។ ដូច្នេះ អ្នកចាប់ខ្លួនជាច្រើនពីមុនមក គឺដឹងពេលក្រោយ ហើយគាត់ក៏និយាយពេលក្រោយដែរ។ ខ្ញុំសូមបញ្ជាក់។

**ស៖** សូមអរគុណដែលលោកស្រីបានបំភ្លឺ។ នៅពេលដែលគាត់ប្រាប់លោកស្រីក្រោយមកនោះ តើគាត់បាននិយាយថាអ្នកណាជាអ្នកបញ្ជាឲ្យគេចាប់ខ្លួន ហ៊ូ នឹម និងហ៊ូ យន់ ដែរឬទេ?

**ឆ៖** គាត់ក៏មិនដែលប្រាប់ខ្ញុំថាអ្នកណាអ្នកបញ្ជានេះដែរ គាត់អត់ដែលនិយាយផង។

**ស៖** ប៉ុន្តែលោកស្រីច្បាស់ថាគាត់ប្រាប់លោកស្រីដោយផ្ទាល់មុខថា អ្នកទាំងពីរនោះមិនគប្បីត្រូវគេចាប់ខ្លួនទេ។ តើអីចឹងដែរឬទេ?

[១១:២៥:៥៨]

**ឆ៖** ចាស អីចឹង។

**ស៖** ហេតុអីបានជាមិនសមគេចាប់ខ្លួនគាត់។ តើគេមានបញ្ហាអ្វីឬទេ?

**ឆ៖** តាមខ្ញុំឮគាត់តែងតែនិយាយគាត់ថា គឺមនុស្សខំមកកំសត់កម្រទាំងអស់គ្នាហើយដល់មក

អ៊ីចឹងមកបាត់អ៊ីចឹង គាត់ក៏មិនយល់ដែរ គេមានស្អី គេមានធ្វើស្អី។ មានតែប៉ុណ្ណឹងទេក្នុងការនិយាយ។ ខ្ញុំក៏មិនដឹង គាត់ប្រាប់ខ្ញុំតែប៉ុណ្ណឹង។

**ស៖** នៅក្នុងឆ្នាំ១៩៧៥ គឺថាត្រូវបានគេចាប់ខ្លួន ម្នាក់ទៀតនៅឆ្នាំ១៩៧៧។ ពួកគាត់ទាំងពីរសុទ្ធតែជាបញ្ញាជន។ តើ ហ៊ូ នឹម និងហ៊ូ យន់ សុទ្ធតែជាបញ្ញាជនដែរឬទេ?

**ឆ៖** ចាស គាត់ជាបញ្ញាជន។

**ស៖** តើគាត់ទាំងពីរនាក់ហ្នឹងជាមនុស្សដែលជិតស្និទ្ធជាមួយនឹងប្ដីរបស់លោកស្រីដែរឬទេ?

**ឆ៖** ចាស កាលពីឆ្នាំមុន៧៥ ធ្លាប់ឃើញជិតស្និទ្ធ។

[១១:២៧:៥៧]

**ស៖** ហើយក្រោយពីឆ្នាំ១៩៧៥ តើលោក ខៀវ សំផន បានជួបពួកគាត់ទាំងពីរហ្នឹង ឬក៏ជួបភ្លាមមុនជម្លៀស ឬក៏ភ្លាមៗក្រោយជម្លៀសទីក្រុងភ្នំពេញ? តើលោកស្រីអាចបំភ្លឺតុលាការនិងខ្ញុំបានដែរឬទេ?

**ឆ៖** ក្រោយរំដោះភ្នំពេញគាត់អត់ដែលជួបអ្នកទាំងពីរទេ។ ហើយខ្ញុំ--

**ស៖** តាមការយល់ដឹង និងតាមសក្ខីកម្មដែលលោកស្រីបានឆ្លើយ ថាតើលោក ខៀវ សំផន បានជួប ហ៊ូ យន់ និងហ៊ូ នឹម ចុងក្រោយហ្នឹងនៅពេលណាមុនពេលដែលមានការជម្លៀស?

**ឆ៖** តាំងពីនេះមក ខ្ញុំអត់ដែលឃើញគាត់ជួប ហើយក៏មិនដឹងជួបកន្លែងណា ខ្ញុំអត់ដឹង។ ហើយពេលណាក៏អត់ដឹង។

**ស៖** តាមតែអ្វីដែលលោកស្រីបានដឹង តើលោកស្រីអាចពិពណ៌នាអំពី ហ៊ូ នឹម និង ហ៊ូ យន់ ថាជាមនុស្សស្និទ្ធស្នាលនឹងគ្នាមិត្តភក្ដិទេ ដោយហេតុថាពួកគាត់បានចូលរួមក្នុងចលនាដូចជាប្រវត្តិសាស្ត្រជាមួយគ្នា។ តើលោកស្រីអាចនិយាយអ្វីបន្ថែមបានទេ?

[១១:២៩:៤២]

**ឆ៖** រឿងនេះខ្ញុំមិនអាចនិយាយបានទេ ពីព្រោះជាក់ស្ដែងខ្ញុំអត់មានជាអ្នកនយោបាយ អត់មានជាអ្នកអីគិតគូរពីរឿងអ៊ីចឹងៗទេ ខ្ញុំគិតតែផ្នែកផ្ទះបាយ។ ដូច្នេះអត់ដឹងថាគាត់កម្រិត ការជិតស្និទ្ធរវាងយ៉ាងម៉េចៗ ខ្ញុំអត់ដឹង។

**ស៖** នៅពេលដែលលោកស្រីបានជជែកជាមួយស្វាមីអំពី ហ៊ូ នឹម និង ហ៊ូ យន់ ចុងក្រោយនោះ តើគាត់បាននិយាយប្រាប់លោកស្រីអំពីប្រហែលជាប្រាំបួននាក់ ក្នុងចំណោមសមាជិករបស់រណសិរ្សរួម

រួមជាតិ ឬក៏រាជរដ្ឋាភិបាលរួបរួមជាតិនោះ គឺថាមានមួយចំនួននោះ គឺត្រូវបានគេចាប់នឹងសម្លាប់បាទ?

**ផ៖** ដូចជាអ្នកផ្សេងទៀតមិនមានអីនិយាយទេ ពីព្រោះអី អង្កាល់នុំងក៏ធ្លាប់ឃើញលោក ហ៊ូ នឹម, ហ៊ូ យន់ អ៊ីចឹងបានគាត់និយាយរឿងហ្នឹង។ ឯអ្នកផ្សេងខ្ញុំអត់ស្គាល់។ ហ្នឹងគាត់អត់ដែលនិយាយអីជាមួយខ្ញុំទេ។ ឬមួយក៏គាត់ដឹង ឬមួយក៏គាត់មិនដឹង ប៉ុន្តែពេលហ្នឹង គឺអត់ដឹងទាំងអស់គ្នា។ ក្រោយមកដឹង ក៏មិនដឹងជារឿងហេតុអីអ៊ីចឹង។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១១:៣១:២៧]

**ស៖** នៅពេលដែលប្ដីលោកស្រីជជែកជាមួយលោកស្រីអំពីការចាប់ខ្លួន ហ៊ូ នឹម, ហ៊ូ យន់ និងការបាត់ខ្លួនរបស់ពួកគាត់ទាំងពីរហ្នឹង តើប្ដីលោកស្រីមានប្រាប់លោកស្រីថា ពួកគាត់ទាំងពីរនាក់ហ្នឹងពាក់ព័ន្ធជាមួយភ្នាក់ងារខ្មាំង ឬក៏អ្វីដែរនោះទេ?

**ផ៖** គាត់មិននិយាយរឿងពាក់ព័ន្ធទេ។ គាត់និយាយអីទាំងអស់ គ្រាន់តែថា ហេតុអីបានអ៊ីចឹង។ មានតែប៉ុណ្ណឹង។

**ស៖** ចាប់តាំងពីឆ្នាំ៧៩មក តើលោកស្រីធ្លាប់ជជែកជាមួយប្ដី ដែលថាលោកស្រីសួរប្ដីលោកស្រីថា “បងតើមានហេតុផលអីដែលប្រជាជនស្លាប់ច្រើននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរទេ?” លោកស្រីធ្លាប់ដែលសួរប្ដីលោកស្រីបែបនេះដែរឬទេ?

**ផ៖** ចាស ខ្ញុំធ្លាប់។

**ស៖** តើគាត់ធ្លាប់ឆ្លើយដូចរបៀបបែបអ៊ីចេះ ខ្ញុំលើកឧទាហរណ៍: ប្រជាជនត្រូវបានគេចោទប្រកាន់ ហើយចាប់ខ្លួនដោយសារតែពួកគេជាភ្នាក់ងាររបស់វៀតណាម ឬក៏ សេ.អ៊ី.អា ឬក៏មានចម្លើយប្រហាក់ប្រហែលហ្នឹង។ តើគាត់ធ្លាប់ឆ្លើយបែបហ្នឹងដែរឬទេ?

[១១:៣៣:០៩]

**ផ៖** គាត់និយាយជាមួយខ្ញុំជាទូទៅ គឺថាគេធ្វើបាបបងប្អូនដែលជម្លៀសទៅ គឺថាបង្អត់បាយអាហ្នឹងគាត់ឆ្ងល់ណាស់ គាត់ៗគឺថាគាត់មានចិត្តមួយវារន្ធត់ ខ្លាចផ្សាដែរ ទាំងខ្ញុំទាំងគាត់។ ដល់ក្រោយមកមានឮអ៊ីចឹង ហើយរឿង សេ.អ៊ី.អា រឿងអីដែលហ្នឹង អាហ្នឹងវាមិនៗទាក់ទិនដល់ប្រជាជនទេ បើតាមគាត់និយាយជាមួយខ្ញុំ។ គាត់មិនមាននិយាយអារឿង សេ.អ៊ី.អា និយាយអីទេ។ គាត់ថា ប្រជាជនស្លូតត្រង់ទៅមាន សេ.អ៊ី.អា អីណា ហើយសម្លាប់បង្អត់បាយខ្លាំងម្ល៉េះ។ ហ្នឹងគាត់ធ្លាប់និយាយអ៊ីចឹង។

**ស៖** នៅក្នុងឆ្នាំ៨១ ប្ដីលោកស្រីបានសម្ភាសជាមួយបុរសម្នាក់ឈ្មោះ ស៊ីវ ហេងឌ័រ។ ហើយ

ឯកសារមានលេខ E3/203។ ហើយអ្វីដែលខ្ញុំចង់និយាយយោង គឺឯកសារដែលមានលេខ ERN ជាភាសាអង់គ្លេសគឺមានលេខ 00424016, ភាសាបារាំងមានលេខ 00434236 ដល់ 37, ភាសាខ្មែរមានលេខ 00385413 ដល់ 14។ ហើយលោក ស្ទីវ ហេដឌ័រ បានសួរសំណួរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖

"អ្វីដែលខ្ញុំចង់សួរ គឺថានៅពេលដែលថាមានគេចោទប្រកាន់មនុស្សថា ជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ភ្នាក់ងារយួននោះ ខ្ញុំសួរលោកថាតើពួកគេទាំងនោះត្រូវបានគេចោទប្រកាន់ថាជាភ្នាក់ងារយួនដែរឬទេ ដើម្បីសម្លាប់ពួកគេ ដើម្បីសម្លាប់អ្នកស្នេហាជាតិពិតប្រាកដ។ តើបញ្ហានេះធ្លាប់កើតនៅក្នុងថ្នាក់លើដែរឬទេ?" ចម្លើយ៖ "បាទ គឺមានសមមិត្តនៅខាងបស្ចិមមនុស្សចាស់ម្នាក់ គាត់ត្រូវបានគេចោទប្រកាន់ថាជាភ្នាក់ងារយួន"។ ពួកគាត់ត្រូវតែទទួលខុសត្រូវចំពោះបញ្ហានេះ។ គេចោទប្រកាន់គាត់ ក៏ប៉ុន្តែពួកគេមិនអាចចោទប្រកាន់បានជោគជ័យដោយសារតែយើងធ្វើការស៊ើបអង្កេតដោយទាន់ពេលវេលា"។ ខ្ញុំសូមបញ្ចប់ការដកស្រង់របស់ខ្ញុំ។

[១១:៣៦:១២]

តើលោកស្រីដឹងដែរឬទេ ថាហេតុអ្វីនៅពេលដែលស្វាមីលោកស្រីនិយាយជាមួយលោក ស្ទីវ ហេឌ័រ នៅក្នុងឆ្នាំ៨១ គាត់បាននិយាយយោងអំពីការដែលគាត់ដឹងពីការចាប់ខ្លួន និងការបាត់ខ្លួនរបស់ -- ប៉ុន្តែហេតុអ្វីក៏ប្តីលោកស្រីនិយាយថាមិនដឹងអំពីការបាត់ខ្លួនរបស់ ហ៊ូ នឹម និង ហ៊ូ យន់ ទៅវិញ?

**ឆ៖** អាហ្នឹងធម្មតាការនិយាយជាមួយខ្ញុំ គឺខ្ញុំសួរគាត់ប៉ុនណា គាត់និយាយប៉ុណ្ណឹង។ ដូច្នេះអារឿងរ៉ាវទាំងឡាយណាដែលមិននេះ ពីព្រោះខ្ញុំមិនមែនជាអ្នកវិភាគនយោបាយ ខ្ញុំគ្រាន់តែមេផ្ទះដាំបាយ ដូច្នេះមិនងាយនាងខ្ញុំទៅដឹងគ្រប់រឿងទេ នេះខ្ញុំសូមជម្រាបអ៊ីចឹង។ ឯការគាត់និយាយជាមួយអ្នកណាៗ អាហ្នឹងខ្ញុំក៏អត់ដឹងនិងជ្រាបដែរ។

**ស៖** តើប្តីរបស់លោកស្រីធ្លាប់ប្រាប់លោកស្រីអំពីលិខិតដែលគេផ្ញើជូនគាត់ សំបុត្រដែលគេផ្ញើជូនគាត់ពី ហ៊ូ នឹម ដែលលិខិតនោះនិយាយថា "គាត់ – ហ៊ូ នឹមហ្នឹងត្រូវបានគេចាប់ខ្លួននៅថ្ងៃ១០ មេសា ឆ្នាំ៧៧" ហើយឯកសារនោះគឺមានលេខ E3/1550។ ដូច្នេះខ្ញុំសូមសួរសំណួរឡើងវិញ។ តើប្តីលោកស្រីធ្លាប់ប្រាប់លោកស្រីអំពីលិខិតមួយដែល ហ៊ូ នឹម ផ្ញើជូនគាត់ដោយលិខិតហ្នឹងតវ៉ាលើកឡើងថា "គាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃ១០ មេសា ឆ្នាំ៧៧"។ តើលោកស្រីដែលឮទេ?

[១១:៣៨:២៥]

**ឆ៖** ចាស អត់ដែលឮទេ។

**ស៖** ហេតុអ្វីបានជា ហ៊ូ នឹម ត្រូវបានគេចាប់ខ្លួន ហើយបែរជាសរសេរលិខិតមកប្ដីលោកស្រីទៅវិញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីការពារក្ដីលោក ខៀវ សំផន!

**លោក អាកឡូវ វែកគែន៖**

បាទ យើងមិនឮសំណួរជាភាសាបារាំងទេលោកប្រធានអម្បាញ់មិញនេះ។

**ប្រធានអង្គជំនុំ៖**

បញ្ហាម្ដងហើយម្ដងទៀត លោកមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងខាងបកប្រែភាសាមើល៍ តើវាមានបញ្ហាយ៉ាងម៉េចបានជាមានបញ្ហាបកប្រែភាសាបារាំងនេះម្ដងហើយម្ដងទៀត មិនចេះចប់មិនចេះហើយសោះ? សូមលោកសម្របសម្រួលធ្វើយ៉ាងណាឲ្យការងារហ្នឹងប្រព្រឹត្តទៅដោយរលូន ហើយនិងមានប្រសិទ្ធភាពខ្ពស់អំពីការបកប្រែភាសានេះ។ បើមានបញ្ហាអីលើកយកមកដោះស្រាយឲ្យបានសមស្រប ហើយនិងទាន់ពេលវេលា។

[១១:៣៩:៣៩]

**លោក យឹត ឃេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមលើកឡើងដើម្បីជាប្រយោជន៍កាលពីម្សិលមិញ អ្នកបកប្រែបារាំងប្រាប់ខ្ញុំថា ខ្ញុំមិនបានទុកចន្លោះឲ្យបានគ្រប់គ្រាន់។ ដូច្នេះខ្ញុំគិតថាប្រហែលជាបញ្ហាខាងខ្ញុំ។ ដូច្នេះឥឡូវនេះខ្ញុំនឹងធ្វើការផ្អាក ឬក៏ធ្វើការពន្យារបន្តិចនៅពេលដែលចោទសួរម្ដងៗ។ ដូច្នេះខ្ញុំនឹងចោទសួរសំណួរឡើយវិញ។

**សួរដោយលោក យឹត ឃេយ៍ន័រ៖**

**ស៖** លោកស្រី សុជាតិ សូមលោកស្រីជួយមកដល់ខាងយើងខ្ញុំ ដើម្បីប្រាប់ថាហេតុអ្វីលោក ហ៊ូ នឹម បន្ទាប់ពីគេចាប់ខ្លួនគាត់ភ្លាមៗនោះ គឺនៅថ្ងៃ១០ មេសា ឆ្នាំ៧៧។ អាចធ្វើលិខិតមកប្ដីរបស់លោកស្រី ដើម្បីតវ៉ាអំពីការចាប់ខ្លួនរបស់គាត់។ ហេតុអ្វី?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។ ខ្ញុំសូមជំទាស់ចំពោះសំណួរដែល

លើកឡើងដោយតំណាងសហព្រះរាជអាជ្ញានាពេលនេះ ពីព្រោះថាលោកស្រី សុជាតិ មិនអាចដឹងពីមូលហេតុថា ហេតុអ្វីបានលោក ហ៊ូ នឹម សរសេរសំបុត្រមកលោក ខៀវ សំផន ទេ។ ហើយាការបកស្រាយទាំងឡាយដែលអ្នកស្រី សុជាតិ នឹងលើកក្នុងនាមជាសាក្សីនៅពេលនេះ វានឹងបង្ហាញពីការសន្និដ្ឋានជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ មិនអាចជួយដល់តុលាការក្នុងការស្វែងរកការពិតបានឡើយ។ ដូច្នេះ សូមតុលាការជំទាស់ កុំឲ្យលោកសហព្រះរាជអាជ្ញាសួរទៅលើសាក្សីចំពោះសំណួរនេះ។ បាទ សូមអរគុណ។

[១១:៤១:៤១]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ដោយសារតែមានការទំនាក់ទំនងដែលលោកស្រី សុជាតិ មានទំនាក់ទំនង។ ហើយលោកស្រីបាននិយាយអំពីទំនាក់ទំនងរវាង ហ៊ូ នឹម, ហ៊ូ យន់ និង ខៀវ សំផន មុនឆ្នាំ៧៥នោះ គឺថាតាមគាត់ផ្ទាល់នោះ តាមលោកស្រី សុជាតិ ផ្ទាល់ ដូច្នេះខ្ញុំសូមលើកឡើងថា ខ្ញុំមិនបានស្នើសុំឲ្យធ្វើការសន្មត ឬក៏ទាយស្មាននោះទេ។ ហើយភស្តុតាងគឺបានបញ្ជាក់ បានបង្ហាញបែបនេះរួចទៅហើយ។

[១១:៤២:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៣:២៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីការពារក្តី លោក ខៀវ សំផន ដែលសួរឡើងដោយសហព្រះរាជអាជ្ញា គឺមានមូលហេតុសមស្រប។ សំណួរនេះ គឺនាំឲ្យសាក្សីរូបនេះនឹងផ្តល់ចម្លើយជាសេចក្តីសន្និដ្ឋាន ឬក៏បញ្ចេញនូវមតិយោបល់ផ្ទាល់ ដែលមិនសមស្របនឹងការប្រើប្រាស់សំណួរប្រភេទនេះនៅក្នុងដំណើរការនេះទេ។ ដូច្នេះ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។ សំណួរចុងក្រោយនេះ គឺអង្គជំនុំជម្រះមិនចាំបាច់ស្តាប់ទេ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី សុជាតិ ឯកសារដែលមានលេខ E3/231 គឺជាកំណត់ហេតុប្រជុំរបស់គណ:

អចិន្ត្រៃយ៍នៅថ្ងៃ០៨ មីនា ឆ្នាំ៧៦ ដែលកំណត់ហេតុហ្នឹង គេនិយាយអំពីការចូលរួមនៅក្នុងកិច្ចប្រជុំនោះ ដែលរួមទាំងបញ្ចូលទាំងស្វាមីរបស់លោកស្រី គឺសមមិត្ត ហែម និងសមមិត្ត ភាស់ ដែលជា ហ៊ូ នឹម នោះឯង។ តើប្តីលោកស្រីនៅពេលណាមួយនោះ ធ្លាប់ប្រាប់លោកស្រីថា គាត់ចូលរួមនៅក្នុងកិច្ចប្រជុំដ៏សំខាន់មួយ ក្រោយឆ្នាំ៧៥ គឺចូលរួមប្រជុំជាមួយ ហ៊ូ នឹម ដែរឬទេ? តើគាត់ធ្លាប់ប្រាប់ទេ?

[១១:៤៥:១៨]

**ឆ៖** ចាស ខ្ញុំសូមជម្រាប គឺនាងខ្ញុំមកនេះ គឺមិនមែនជាអ្នកនយោបាយ ឬក៏អ្នកនេះទេ។ ខ្ញុំជាអ្នកដាំបាយ។ ដូច្នេះអ្វីដែលខ្ញុំចង់មកនេះ គឺថាចង់និយាយ គឺនិយាយពីរឿងតែខ្ញុំឃើញ ខ្ញុំឮផ្ទាល់ ព្រោះអីរឿងទាំងអស់ដែលលោកសួរ គឺខ្ញុំអត់មានលទ្ធភាពដឹងរឿងទេ គឺទាំងអស់នេះគឺរឿងនយោបាយរបស់ខាងលើខ្ញុំអត់ដឹងទេ។

**ស៖** ៥ថ្ងៃក្រោយការចាប់ខ្លួន ហ៊ូ នឹម គឺនៅថ្ងៃ១៥ មេសា ឆ្នាំ៧៧ ប្តីរបស់លោកស្រីបានថ្លែងសុន្ទរកថាខួបលើកទី២ ដែលសុន្ទរកថាហ្នឹងត្រូវបានផ្សព្វផ្សាយដោយវិទ្យុមាតុភូមិកម្ពុជា។ ឯកសារមានលេខ E3/201។ ហើយមានការដកស្រង់នៅទំព័រភាសាអង់គ្លេសគឺមានលេខ 00419513,ខ្មែរមានលេខ 00292804 ដល់ 05, ភាសាបារាំងមានលេខ 0012166 គឺនៅពេលនោះ គឺប្តីលោកស្រីបានថ្លែងដូចតទៅនេះ ខ្ញុំសូមដកស្រង់៖

"យើងត្រូវតែបោសសម្អាតខ្មាំង តាមសមត្ថភាពរបស់យើងក្នុងនាមជាម្ចាស់ស្ថានការណ៍ បន្ទាប់ពីគោរពតាមមាគ៌ារបស់គោលនយោបាយជាតិ គោលនយោបាយអន្តរជាតិ និងគោលនយោបាយយោធារបស់អង្គការបដិវត្តន៍យើង។ អ្វីៗទាំងអស់ត្រូវធ្វើឡើងដោយស្អាតបាត ហើយនិងបានពេញលេញ។ យើងមិនត្រូវភ្លេចភ្លាំង មិនត្រូវប្រហែស ហើយមិនត្រូវភ្លេចនោះឡើយ។ គឺយើងមិនត្រូវភ្លេចដោយសារជោគជ័យពីពេលកន្លងមកហើយ។ ប៉ុន្តែយើងត្រូវតែពង្រឹងខ្លួនយើង ហើយធ្វើឲ្យយើងដឹងខ្លួន ហើយរក្សានូវស្មារតីបដិវត្តន៍ និងការប្រុងប្រយ័ត្នបដិវត្តន៍ ដើម្បីប្រយុទ្ធនឹងទប់ស្កាត់រាល់ការវាយប្រហាររបស់ខ្មាំងនៅគ្រប់ពេលវេលាទាំងអស់"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

តើលោកស្រីធ្លាប់ស្តាប់ការផ្សាយសុន្ទរកថារបស់ប្តីលោកស្រីនេះដែរឬទេ?

[១១:៤៨:៤៣]

**ឆ៖** ចាស ខ្ញុំដូចជាមិនបានស្តាប់ដែរ ពេលនោះដូចជាមិនបានស្តាប់ទេ។

**ស៖** តើគាត់ទៅផ្សព្វផ្សាយការថ្លែងសុន្ទរកថារបស់គាត់នៅកន្លែងណាដែរ ក្រោយថ្ងៃ១៧ មេសា

៧៥នោះ?

**ផ៖** ចាស ខ្ញុំអត់ដឹង អត់ដឹងដែរ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើគាត់ធ្លាប់ប្រាប់លោកស្រីថា គាត់ធ្លាប់ទៅក្រសួងឃោសនាការដែលជាកន្លែងផ្សព្វផ្សាយព័ត៌មានដែលប្រើប្រាស់ដោយរបបមុនដែរឬទេ តើគាត់ធ្លាប់ប្រាប់លោកស្រីបែបនេះទេ?

**ផ៖** ចាស អត់ដែលឮគាត់ថាទៅផង។

**ស៖** សុន្ទរកថានេះគឺនិយាយអំពីការប្រុងប្រយ័ត្នបដិវត្តន៍ ហើយលោកស្រីបានប្រើប្រាស់ពាក្យនេះរួចទៅហើយនៅក្នុងសក្ខីកម្មរបស់លោកស្រី គឺការប្រុងប្រយ័ត្នបដិវត្តន៍។ តើអ៊ីចឹងមែនទេ?

**ផ៖** ចាស ប្រុងប្រយ័ត្នអ៊ីចឹងមែន។

[១១:៥០:២៦]

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ៧៥ ដល់ ៧៩ តើលោកស្រីធ្លាប់ជជែកជាមួយប្ដីអំពីការនិយាយណាមួយដែលថាលោកស្រីនិយាយអំពីការប្រុងប្រយ័ត្នបដិវត្តន៍ដែរឬទេ? តើលោកស្រីធ្លាប់ជជែកជាមួយប្ដីអំពីការប្រុងប្រយ័ត្នបដិវត្តន៍ដែរឬទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ផ៖** ចាស ខ្ញុំសូមជម្រាប គឺខ្ញុំនិងប្ដីខ្ញុំ ទី១គឺមានការងាររៀងខ្លួនមិនសូវបានជជែកវែកញែកអីប៉ុន្មានទេ រវល់ ជាពិសេសគឺខ្ញុំផ្នែកផ្ទះបាយរៀបចំទុកដាក់នៅមានផ្ទាល់ខ្លួនជាគក់ខោអាវល្មមហើយវាគ្មានពេល ហើយកូនទៀត នេះខ្ញុំសូមជម្រាប។ ដូច្នេះឯការជជែកវែកញែក ហើយម្យ៉ាងខ្ញុំជាស្រីផ្ទះបាយ បើគិតតាមប្រពៃណីពីមុនមក ក៏រឿងរ៉ាវទាំងអស់ដែលហៅថាប្ដីយើងមានដឹង គឺស្រីគឺមិនអាចទៅដឹងគ្រប់រឿងដែរ នេះតាមខ្ញុំធ្លាប់ដឹង។ គឺមនុស្សស្រីធម្មតាគឺនៅតែត្រឹមផ្ទះបាយគឺផ្ទះបាយហើយ។ ដូច្នេះគឺនៅពេលចុះពី៧៥ អ៎!ពី៧៥-៧៩ ពេលនោះមានវិន័យក្នុងការចេញចូលដើរហើរ ប្រុងប្រយ័ត្ន រក្សាការសម្ងាត់។ ដូច្នេះការជជែកវែក ហើយម្យ៉ាងវាររវល់ផង រវល់រៀងៗខ្លួន។ ពេលណាគាត់នេះគាត់ជួយមើលកូនទៅ។ ដូច្នេះខ្ញុំអធ្យាស្រ័យ គឺខ្ញុំមិនបានហៅថាជជែកវែកញែកអីឲ្យបាន--

[១១:៥៣:០០]

**ស៖** សូមអភ័យទោសដែលខ្ញុំត្រូវកាត់លោកស្រី។ ប៉ុន្តែលោកស្រីបានពិភាក្សាជាមួយគាត់អំពីបញ្ហាការប្រុងប្រយ័ត្នបដិវត្តន៍។ តើអ៊ីចឹងមែនទេ អំមិញលោកស្រីនិយាយអ៊ីចឹង?

**ផ៖** ការប្រុងប្រយ័ត្នបដិវត្តន៍ គឺខ្ញុំមិនដែលនិយាយជាមួយគាត់ទេ។ ខ្ញុំគឺនៅក្នុងកន្លែងៗគឺជា

វិន័យរបស់កន្លែង។ មានការប្រុងប្រយ័ត្នបដិវត្តន៍ ប្រុងប្រយ័ត្នទាំងស្មារតីសម្ភារៈ ប្រុងប្រយ័ត្នធ្វើម៉េច ទាំងអស់។ គឺការប្រុងប្រយ័ត្នហ្នឹងជារួមគឺហៅថាជាគំនិតរួមរបស់នៅក្នុងកន្លែង។ គឺគេត្រូវឲ្យតែប្រុងប្រយ័ត្នអ៊ីចឹងតែម្តង។ ហើយខ្ញុំនិយាយជាមួយគាត់--

**ស៖** សូមអរគុណលោកស្រី សូមអរគុណ។ តើលោកស្រីកំពុងតែផ្លាស់ប្តូរចម្លើយរបស់លោកស្រីនៅពេលលោកស្រីផ្តល់សក្ខីកម្មគឺថាបន្ទាប់ពីលោកស្រីគិតថា លោកស្រីនិយាយខុសទេ លោកស្រីប្តូរចម្លើយ។ អ៊ីចឹងមែនទេឥឡូវហ្នឹង?

**ឆ៖** ចាស សូមទោសកន្លែងណាខុសសូមលោកមេត្តាម្តងទៀត នេះខ្ញុំឆ្លើយខុស ព្រោះខ្ញុំវាដូចជា -- កន្លែងណាដែលខ្ញុំឆ្លើយខុសត្រង់ណាសូមមេត្តាសូមទោស។

[១១:៥៤:៤៣]

**ស៖** ឥឡូវនេះយើងចាប់ផ្តើមគិតម្តងមួយៗទៅលើអ្វីដែលលោកស្រីបានប្រាប់តុលាការ។ ខ្ញុំសួរសំណួរសាមញ្ញមួយ។ លោកស្រីបានទទួលស្គាល់ថាលោកស្រីបានប្រើប្រាស់ពាក្យប្រុងប្រយ័ត្នបដិវត្តន៍នៅក្នុងសក្ខីកម្មរបស់លោកស្រី។ ហើយបន្ទាប់មកទៀត ខ្ញុំសួរលោកស្រីថា លោកស្រីធ្លាប់ពិភាក្សាជាមួយ ខៀវ សំផន ដែរឬទេអំពីពាក្យនេះ? លោកស្រីនិយាយថា យើងកម្រនិយាយអំពីបញ្ហានេះណាស់។ ហើយបន្ទាប់មកខ្ញុំសួរលោកស្រី ថាលោកស្រីពិតជាធ្លាប់និយាយមែនអត់? តើលោកស្រីពិតជាធ្លាប់និយាយមែនអត់? លោកស្រីឆ្លើយថា "អូ្ហ! អត់ទេ ខ្ញុំអត់មាននិយាយអំពីពាក្យប្រុងប្រយ័ត្នបដិវត្តន៍ទេ"។ ដូច្នេះ គឺវាបង្ហាញថាក្នុងរយៈពេលត្រឹមតែ៣នាទីសោះ លោកស្រីប្តូរចម្លើយលោកស្រីបាត់ទៅហើយ។ ម្តងអ៊ីចេះ ម្តងអ៊ីចុះ។

[១១:៥៥:៤៦]

**ឆ៖** សូមទោស។ ខ្ញុំសូមបញ្ជាក់ពីបញ្ហាចម្លើយ គឺលោកបានសួរពីបញ្ហាចម្លើយថា មានការប្រុងប្រយ័ត្នបដិវត្តន៍។ ខ្ញុំអត់មានថា ខ្ញុំមិនមែនអត់និយាយទេ គឺការប្រុងប្រយ័ត្នបដិវត្តន៍ហ្នឹង គឺខ្ញុំនិយាយៗដោយនៅក្នុងកន្លែងគឺគេឲ្យយើងប្រុងប្រយ័ត្នបដិវត្តន៍។ ចាសខ្ញុំសូមបញ្ជាក់។ មិនមែនថាខ្ញុំអត់និយាយទេ ខ្ញុំនិយាយ ប៉ុន្តែខ្ញុំនិយាយជារួមជាទូទៅ។ ឯចំពោះជាមួយប្តីខ្ញុំនិយាយដែរ ប៉ុន្តែនិយាយជារួមជាទូទៅ គឺគេប្រុងប្រយ័ត្នបដិវត្តន៍នៅក្នុងកន្លែងអ៊ីចឹងតែម្តង។ ចាស នេះខ្ញុំសូមបញ្ជាក់។

**ស៖** ឯកសារដែលចៅក្រម ឡាវ៉ែន់ ដែលទើបនឹងលើកយកមកនិយាយ គឺជាអ្វីដែលគេហៅថាជាសៀវភៅគ្រួសារនោះ គឺនិយាយអំពីការចុះឈ្មោះមនុស្ស គឺឯកសារមានលេខ គឺឯកសារ E275.8 ។

តើខ្ញុំនិយាយត្រឹមត្រូវដែរទេ? ឯកសារហ្នឹង គឺជាឯកសារដែលត្រូវបំពេញនៅពេលដែលលោកស្រី និងសមាជិកគ្រួសារដទៃទៀតផ្លាស់ប្តូរទីលំនៅ ឬមួយក៏តើវាមានហេតុផលអ្វីដែលលោកស្រីត្រូវធ្វើសៀវភៅគ្រួសារហ្នឹង?

[១១:៥៧:១៥]

**ឆ៖** សូមទោស សៀវភៅគ្រួសារផ្លាស់ទីលំនៅ ខ្ញុំអត់យល់។

**ស៖** តើសៀវភៅគ្រួសារហ្នឹង ត្រូវគេចុះហ្នឹងនៅពេលដែលលោកស្រីដូរផ្ទះ ឬមួយក៏យ៉ាងម៉េច?

**ឆ៖** ចាស។ មុនដំបូងមកនៅប៉ៃលិន នៅផ្ទះនៅបឋិននៀវ ដល់ពេលបន្ទាប់មកខ្ញុំនៅកូនខ្លុងមានការដូរ។

**ស៖** ប្រសិនបើខ្ញុំយល់ពីនីតិវិធីមិនខុសទេ គឺថានៅពេលដែលគ្រួសារមួយផ្លាស់ប្តូរទីលំនៅ ឯកសារត្រូវតែប្រគល់ទៅឲ្យខាងឃុំសង្កាត់ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** តើខ្ញុំនិយាយត្រឹមត្រូវទេ ដែលថាមនុស្សទាំងអស់ដែលមានអាយុលើស ១៨ឆ្នាំ ត្រូវតែផ្តល់ឯកសារជាភស្តុតាងទៅខាងចុះបញ្ជីឃុំសង្កាត់នោះ តើត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ នៅពេលដែលមនុស្សណាម្នាក់ប្រគល់ឯកសារទៅដល់ខាងចុះបញ្ជី គឺថាចាំបាច់ត្រូវតែមានសាក្សីនៅក្នុងបន្ទប់នុំង នៅពេលដែលប្រគល់ឯកសារនោះ?

**ឆ៖** នេះ ខ្ញុំអត់យល់ត្រូវមានសាក្សី។ ខ្ញុំដូចអត់ --

**ប្រធានអង្គជំនុំ៖**

បាទៗ សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទយល់ឃើញថា តំណាងសហព្រះរាជអាជ្ញាកំពុងតែសួរនាំនូវបញ្ហាដែលមិនមែនជាប្រធានបទសម្រាប់ការពិភាក្សារបស់អង្គជំនុំជម្រះនាពេលនេះ ពីព្រោះបើសិនជាតំណាងសហព្រះរាជអាជ្ញា ចង់ដឹងអំពីនីតិវិធីនៃការធ្វើសំបុត្រ ឬក៏លិខិតស្នាក់នៅ ឬក៏ប័ណ្ណគ្រួសារនេះ គួរតែកោះហៅស្មៀនឃុំ ឬក៏មេឃុំមកសាកសួរវិញ ព្រោះអ្នកស្រីដែលជាសាក្សីនេះ គាត់មិនអាច

ផ្តល់ចម្លើយត្រឹមត្រូវជូនអង្គជំនុំជម្រះនាពេលនេះទេបាទ។ សូមអរគុណ។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមពន្យល់។ គឺថាសំណួរហ្នឹងគឺហ្នឹងនិយាយអំពីកាលបរិច្ឆេទថ្ងៃខែឆ្នាំកំណើត របស់កូនប្រុសគាត់នៅ ខៀវ ឧត្តម។ ព្រោះថាការនិយាយហ្នឹងគឺវាមានការសំខាន់បំផុត អាហ្នឹង ជាបញ្ហាទី១ ដែលនិយាយ ដែលចៅក្រម ឡាវែន៍ បានសួរដោយផ្ទាល់អំពីបញ្ហានេះផងដែរ។ ហេតុដូច្នេះ ហើយសំណួរដែលពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទថ្ងៃខែឆ្នាំកំណើតរបស់ឈ្មោះ ខៀវ ឧត្តម គឺវាពាក់ព័ន្ធទៅ នឹងការជំនុំជម្រះរឿងនេះ។ ហើយកាលបរិច្ឆេទថ្ងៃខែឆ្នាំកំណើតហ្នឹងក៏វាពាក់ព័ន្ធផងដែរ ព្រោះថាវា ពាក់ព័ន្ធទៅនឹងមនុស្សទាំងអស់នៅក្នុងសវនាការនេះ។

[១២:០១:២៦]

កាលពីម្សិលមិញលោកស្រី សុជាតិ និយាយថាកូនគាត់កើតថ្ងៃទី០៤ ឧសភា ឆ្នាំ៧៥ ប៉ុន្តែឥឡូវ -- ៧៤ ប៉ុន្តែឥឡូវបែរជាមានឯកសារដែលថាគាត់កើតថ្ងៃទី០៦ ខែ៦ ឆ្នាំ៧៤ ទៅវិញ។ ដូច្នេះហើយគឺ ទាំងអស់នេះគឺវាតម្រូវឲ្យមានការវាយតម្លៃត្រឹមត្រូវ។ ហើយលោកស្រីមិនអាចបញ្ជាក់ថាវាការពិត ឬ ក៏អត់ នៅពេលដែលមានការចោទសួរអំពីបញ្ហានេះ។ ដូច្នេះខ្ញុំសូមអនុញ្ញាត។

[១២:០១:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០២:២៣]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន មិនមាន --មិនសមស្របទេ។ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សីទៅនឹងសំណួរដែល សួរឡើងដោយតំណាងសហព្រះរាជអាជ្ញាសំណួរចុងក្រោយអម្បាញ់មិញនេះ។ សូមសាក្សីឆ្លើយតប!

*(សម្រាករយៈពេលខ្លី)*

**ប្រធានអង្គជំនុំ៖**

លោកស្រី សុជាតិ ចាំទេសំណួរចុងក្រោយអម្បាញ់មិញនេះ?

**លោកស្រី សូ សុជាតិ៖**

ម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរចុងក្រោយម្តងទៀត!

[១២:០៣:២២]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំគិតថាលោកស្រីឆ្លើយខ្លះរួចទៅហើយ ប៉ុន្តែខ្ញុំសូមសួរឡើងវិញម្តងទៀត។ នៅពេលដែលលោកស្រីមានវត្តមាននៅចំពោះមុខអ្នកចុះបញ្ជីនៅក្នុងការិយាល័យចុះបញ្ជីរបស់ឃុំសង្កាត់នុ៎ង តើលោកស្រីចាំថាមានអ្នកដទៃទៀតមានវត្តមាននៅក្នុងបន្ទប់ជាមួយលោកស្រីហ្នឹងក្នុងនាមជាសាក្សី ដើម្បីជាសាក្សីអំពីនីតិវិធីនៃការចុះឈ្មោះនោះដែរទេ? ហើយតើមានសាក្សីហ្នឹងគាត់មានចុះហត្ថលេខានៅក្នុងលិខិតចុះបញ្ជីស្នាមហ្នឹងអីដែរឬទេ?

**ឆ៖** ការធ្វើនៅពេលនោះគឺ កាលនោះយើងធ្វើជាសង្ខេបៗ ដូចជាគ្មានសាក្សីទេ មានតែនៅសង្កាត់ ហើយនិងស្មៀន។ ដូច្នេះការធ្វើសំបុត្រហ្នឹងនៅស្រុកខ្មែរ ខ្ញុំឃើញថា -- ហើយអ្នកទាំងអស់គ្នាថា បើមឹងអត់ចាំច្បាស់ដាក់សិនទៅ ហ្នឹងអ៊ីចឹង។ ហើយខ្ញុំនឹកមកឡើងវិញទៅ ដល់ពេលធ្វើនេះហ្នឹងដាក់តាមរបស់វា គេធ្វើមុនហ្នឹង ដាក់តាមរបស់វាអ៊ីចឹង ពីព្រោះអីអ្នកទាំងអស់គ្នាថា “បើមឹងអត់ចាំច្បាស់ដាក់តាមប្រហាក់ប្រហែល ថ្ងៃខែប្រហាក់ប្រហែលហ្នឹង យើងដាក់ប៉ុណ្ណឹងទៅអត់អីទេ”។ ហ្នឹងកូនទី១គឺថាវានៅឆ្ងាយ ហើយក្រោយមកឃើញទើបតែនឹងធ្វើឆ្នាំប៉ុន្មាននេះទេ។ ដូច្នេះខ្ញុំធ្វើសំបុត្រកំណើតនេះ គឺខ្ញុំធ្វើតាមអត្តសញ្ញាណប័ណ្ណរបស់វា ដែលវាធ្វើអត្តសញ្ញាប័ណ្ណហើយ។ ឯកូនខ្ញុំកើតពិតប្រាកដ គឺកើតថ្ងៃ០៤ ខែ៥ ៧៤។ ដូច្នេះ ការធ្វើហ្នឹងក៏ពិគ្រោះជាមួយខាងសង្កាត់ ខាងឃុំដែរ។ នេះ ខ្ញុំសូមជម្រាប។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។

បាទ ឥឡូវនេះពេលសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១២:០៦:២២]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន សូមអភ័យទោស ខ្ញុំសុំអនុញ្ញាតលោកប្រធានបន្តិច ដោយសារតែនេះជាសំណួរ

ដែលចៅក្រម ឡាវែន៍ គាត់សួរអស់ពេលច្រើន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតថា ខ្ញុំសូមបន្ថែមពេលវេលាដែលចៅក្រម ឡាវែន៍ បានសួរហ្នឹង។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតថា ខ្ញុំមិនទាន់បាន -- ខ្ញុំទើបតែបញ្ចប់បានតិចតួចទេ នៅលើអ្វីដែលខ្ញុំចង់សាកសួរនោះ។ សូមលោកប្រធានអនុញ្ញាតបន្ថែមម៉ោងផង។

**ប្រធានអង្គជំនុំ៖**

បាទ អាបញ្ហានេះ គឺអង្គជំនុំជម្រះនឹងរក្សាពេលវេលាសមស្របដែលអង្គជំនុំជម្រះបានចែកឲ្យកាលដែលអង្គជំនុំជម្រះបានប្រើប្រាស់ពេលវេលានោះ ជាបញ្ហាពេលវេលាបន្ថែមផ្សេងទៀត ដែលអង្គជំនុំជម្រះត្រូវគិតគូដល់ភាគីដែលពាក់ព័ន្ធ។ ដូច្នេះ ភាគីតំណាងសហព្រះរាជអាជ្ញា រួមនឹងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាមពេលវេលាដែលអង្គជំនុំជម្រះបានចែងចែកឲ្យ។ ចំណែកឯពេលវេលាដែលចៅក្រម ឡាវែន៍ បានសួរនោះ គឺអង្គជំនុំជម្រះគិតដោយឡែក មិនគិតដកចេញពីពេលវេលាដែលអង្គជំនុំជម្រះចែកជូនភាគីឡើយ។

**លោក ឃីត វេយ៍ន៍រ៖**

សូមអរគុណលោកប្រធាន។

[១២:០៧:៤៤]

**ប្រធានអង្គជំនុំ៖**

លោកស្រី សូ សុជាតិ ឥឡូវនេះ តាមគម្រោងផែនការនៃការធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោកស្រី ថានឹងចាប់នៅព្រឹកនេះ ប៉ុន្តែឥឡូវនេះ ដោយសារមានការសួរដោយអង្គជំនុំជម្រះ ចៅក្រមនៃអង្គជំនុំជម្រះចំពោះលោកស្រី ត្រូវប្រើប្រាស់ពេលវេលាជិតមួយព្រឹកឯណោះ។ អ៊ីចឹងដូច្នេះ ពេលវេលាសម្រាប់ស្ដាប់សក្ខីកម្មរបស់លោកស្រីមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះត្រូវបន្តស្ដាប់សក្ខីកម្មរបស់លោកស្រីនៅរសៀលនេះទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកស្រីមកបន្តផ្ដល់សក្ខីកម្មនៅរសៀលនេះទៀត ដើម្បីបញ្ចប់។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬក៏អ្នកជំនាញ ឬទីកន្លែងណាមួយសមស្របនៅក្នុងបរិវេណនៃ អ.វ.ត.ក យើងនេះ នៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញឲ្យគាត់ រួមនិងមេធាវីប្រឹក្សាសាក្សីផងត្រឡប់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅវេលារសៀលនេះ នៅវេលាម៉ោងមួយនិងសាមសិបនាទី។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនៃខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅ

ខាងក្រោមសាលសវនាការនេះ និងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៩ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចដំណើរការសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសូមផ្តល់វេទិកាជូនទៅមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន មុន។ សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ជូនដំណឹងទៅដល់បុគ្គលទាំងអស់ដែលមានវត្តមាននៅទីនេះ ពីព្រោះថាយើងមានការលំបាកពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃការពិភាក្សាយើងនេះ គឺសៀវភៅគ្រួសារយើងនេះ។ នៅពេលដែលយើងពិនិត្យមើលសៀវភៅគ្រួសារថតចម្លងដែលយើងមាននោះពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទកើតរបស់ រតនា នោះ ខ្ញុំមើលទៅឃើញថានៅភាសាខ្មែរនោះ គឺនៅក្នុងច្បាប់ដើម គឺថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦។ ក៏ប៉ុន្តែតាមការបកប្រែរបស់ផ្នែកបកប្រែភាសាជាភាសាបារាំង អត់មានជាភាសាអង់គ្លេសទេ ដាក់ថាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ដូច្នេះយើងឃើញថាមានភាពខុសគ្នា។ ហើយបើយើងពិនិត្យមើលឯកសារថតចម្លងនៃសៀវភៅគ្រួសារហ្នឹងគឺថាកូពីមិនសូវច្បាស់ទេ គុណភាពអត់ល្អ។ ដូច្នេះហើយបានយើងមើលទៅថ្ងៃ១៣ហ្នឹង វាក្លាយទៅជាបកប្រែហ្នឹង បានជាទៅជា១៩ កញ្ញា ទៅវិញ។ ដូច្នេះដើម្បីឲ្យមានភាពច្បាស់លាស់នោះ ខ្ញុំសូមប្រគល់ជូននូវឯកសារថតចម្លងដែលប្រសើរជាងមុន ដែលយើងបានព្រីនចេញពីម៉ាស៊ីនព្រីននៅតុលាការយើងនេះ ដែលយើងមើលទៅវាមានគុណភាពល្អជាងមុនបន្តិច។ អ៊ីចឹងនៅពេលដែលយើងពិនិត្យមើលឯកសារនេះច្បាស់ទៅ គឺថាគឺប្រាកដណាស់ គឺថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦។ នេះជាថ្ងៃខែឆ្នាំកំណើតរបស់ រតនា។ ដូច្នេះ ខ្ញុំសូមដំណឹងនេះដល់អង្គជំនុំជម្រះ ហើយ

និងប្រគល់ជូនឯកសារថតចម្លងនេះជូនអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីការពារក្តីលោក ខៀវ សំផន យកមកចែកជូនភាគីហើយនិងជូនដល់ចៅក្រមអង្គជំនុំជម្រះផង។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ មុនពេលសម្រាកពិសារអាហារថ្ងៃត្រង់នោះ លោកស្រីបានផ្តល់ភស្តុតាងបានឆ្លើយ បាទ តាមដែលខ្ញុំយល់បើមិនខុសទេ គឺថាលោកស្រីបាននិយាយអំពីសៀវភៅគ្រួសារ។ លោកស្រីនិយាយថា មន្ត្រីអត្រានុកូលដ្ឋាននោះគឺថាបាននិយាយអំពីការស្មានកាលបរិច្ឆេទថ្ងៃកំណើតកូនប្រុសរបស់លោកស្រី។ តើអ៊ីចឹងដែរឬទេ?

[១៣:៣៧:០៦]

**ឆ៖** ការធ្វើអត្រានុកូលដ្ឋានរបស់កូនប្រុសរបស់ខ្ញុំនេះគឺខាងឃុំសង្កាត់ដល់ពេលយើងទៅធ្វើក្នុងនេះមានថ្ងៃកើតមានខែឆ្នាំតែនៅកន្លែងដែលធ្វើនេះ ឃុំសង្កាត់ ព្រោះយើងខ្ញុំក៏វាចាំមិនច្បាស់ហើយគិតហើយចាំមិនច្បាស់នេះ មិនមែនថាមិនច្បាស់ទេ នៅគិតរក ប៉ុន្តែក្នុងនេះវាមាន -- កូនខ្ញុំធ្វើអត្តសញ្ញាណប័ណ្ណមុន វាមិនមែននៅកន្លែងខ្ញុំនៅទេ អត់នៅប៉ៃលិនទេ ចូលមកដំបូង ហើយពីមុនមកអត់បានធ្វើទេ។ តែដល់ពេលវាធ្វើវាធ្វើនៅកន្លែងវានៅ ធ្វើនៅអន្លង់វែង។ ដូច្នេះវាធ្វើមុន អត់មានធ្វើនៅកន្លែងនេះទេ។ ហើយធ្វើហ្នឹងវាធ្វើទៅ វាដាក់ខ្លួនវាខុសត្រូវអីបន្តិចបន្តួចដាក់ទៅ។ ដល់ពេលខ្ញុំធ្វើសៀវភៅគ្រួសារ ខ្ញុំទៅសួរពីវា សួរថាចុះដាក់អាហ្នឹងយ៉ាងម៉េច? វាប្រាប់មកដាក់ថ្ងៃខែប៉ុន្នាន ខ្ញុំមិនសូវចាំ។ អាហ្នឹងកន្លងមកខ្ញុំមិនបានចាប់អារម្មណ៍ពីអត្រានុកូលដ្ឋានអីប៉ុន្មានទេ ពីព្រោះធម្មតានៅស្រុកខ្មែរអ្នកណាចង់ដាក់អីដាក់អ៊ីចឹង ហើយអ្នកណាចង់បន្ថយអាយុបន្ថយអីគឺដាក់តាមហ្នឹង ។ អានេះខ្ញុំសូមជម្រាប ដូចនៅតាមភូមិឃុំក៏អ៊ីចឹងដែរ។ ដូច្នេះខ្ញុំសូមជម្រាបថា អត្រានុកូលដ្ឋានដែលបានធ្វើនេះគឺកូនខ្ញុំវាដាក់ធ្វើអត្តសញ្ញាណប័ណ្ណដើម្បីធ្វើឲ្យបានឆាប់រហ័ស គឺវាធ្វើខ្លួនវានៅនោះ។ គ្រាន់តែថាសួរគ្រួសៗ ហើយនេះទៅខ្ញុំក៏ប្រាប់គ្រួសៗ

ទៅខ្ញុំគិត។

**ស៖** សូមអរគុណ។ តើយើងយល់ត្រឹមត្រូវដែរឬទេតាមចម្លើយរបស់លោកស្រីថាកូនប្រុសរបស់លោកស្រីគឺថាអាយុ ៧ឆ្នាំ គឺថា ចាប់ពីអាយុ ៨ឆ្នាំដល់ -- គឺថាបានប្រើអត្តសញ្ញាណប័ណ្ណដែលមានថ្ងៃខែឆ្នាំមិនត្រឹមត្រូវទេ។ តើអ៊ីចឹងឬទេ?

**ឆ៖** សូមទោសអាយុ ៧ឆ្នាំហើយប្រើអត្តសញ្ញាណប័ណ្ណ សូមទោស--

[១៣:៤០:០០]

**ស៖** បាទ សំណួរ គឺការចុះបញ្ជីនៅឆ្នាំ១៩៩៩ នៅពេលដែលកូនប្រុសរបស់លោកស្រីអាយុ ២៥ឆ្នាំ អ៊ីចឹងការតម្រូវឲ្យមានអត្តសញ្ញាណប័ណ្ណនោះ គឺត្រូវតម្រូវតែឲ្យអាយុ១៨បានធ្វើបាន។ តើអ៊ីចឹងគឺថា ពីដប់-- អាយុ១៨រហូតដល់អាយុ២៥ឆ្នាំនេះ មានន័យថា កូនប្រុសរបស់លោកស្រីហ្នឹងមានអត្តសញ្ញាណប័ណ្ណដែលថា មានកាលបរិច្ឆេទខុស គឺចាប់ពីគាត់អាយុ១៨ ឆ្នាំដល់២៥ឆ្នាំហ្នឹងបាទ?

**ឆ៖** បាទ សូមទោសអាយុ ១៨ឆ្នាំ គឺអត់បានធ្វើទេ រហូតមកដល់អាយុប៉ុន្មាន មកដល់អន្លង់វែងនេះបាន បានធ្វើ។

**ស៖** ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយផ្សេងទៀត។ លោកស្រី សូ សុជាតិ លោកស្រីជាសាក្សីនៅក្នុងរឿងក្តីនេះ ដែលមេធាវីការពារក្តីស្នើសុំលោកមកបំភ្លឺ។ ២៨ខែកន្លងទៅនេះ នៅក្នុងឯកសារ E9/4/6, ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១, លោក ខៀវ សំផន -- ក្រុមមេធាវីរបស់លោក ខៀវ សំផន បានជូនដំណឹងដល់អង្គជំនុំជម្រះថាលោកស្រី បាន -- ថាបានស្នើលោកស្រីធ្វើជាសាក្សី។ តើនៅពេលណាដែលលោកស្រីបានដឹងជាលើកដំបូងថា មានសំណើសុំឲ្យលោកស្រីមកធ្វើជាសាក្សីបំភ្លឺនេះបាទ?

**ឆ៖** មិន -- សូមទោស មិនដឹងថ្ងៃខែណាទេ ដែលខាងមេធាវីប្រាប់នាងខ្ញុំ។ ខ្ញុំអត់ចាំថ្ងៃ ភ្លេចៗហើយ។

**ស៖** មុនពេលដែលលោកស្រីអញ្ជើញមកតុលាការកាលពីម្សិលមិញនេះ តើលោកស្រីបានប្រាប់មេធាវីរបស់លោក ខៀវ សំផន ពីខ្លឹមសារ ឬក៏ពីអ្វីដែលលោកស្រីនឹងត្រូវឆ្លើយនៅនេះដែរឬទេ?

[១៣:៤៣:០៧]

**ឆ៖** នាងខ្ញុំអត់មានបានប្រាប់ ឬក៏អត់ដឹងចម្លើយពីរឿងអី ឬក៏ក្នុងការឆ្លើយអីដល់មេធាវីទេ។

**ស៖** អ៊ីចឹងយើងចង់ឲ្យច្បាស់ ឲ្យប្រាកដ តើលោកស្រីចង់បញ្ជាក់ថា មុនពេលដែលមកតុលាការពីម្សិលមិញនេះ គឺថាមេធាវីការពារក្តីលោក ខៀវ សំផន មិនដែលបានរៀបចំចម្លើយ ឬកំណត់ហេតុអី

ឬក៏រៀបចំឯកសារឲ្យលោកស្រីផ្តិតមេដៃ ដើម្បីឲ្យលោកស្រីចុះហត្ថលេខាបញ្ជាក់នោះទេ។ តើអ៊ីចឹងឬក៏មិនមែនបាទ?

**ឆ៖** ទេ តាមខ្ញុំនេះ ដូចជាមិនមាន ឬក៏យ៉ាងម៉េចហើយ ខ្ញុំភ្លេចហើយ ដូចមិនចាំច្បាស់ទេ។ ដូចជាមិនមាន ឬក៏មានទេ ខ្ញុំអត់។

**ស៖** អ៊ីចឹងខ្ញុំសួរសំណួរបែបនេះវិញ។ នៅពេលដែលលោកស្រីត្រៀមរៀបចំដើម្បីមកបំភ្លឺនៅតុលាការនេះ តើលោកស្រីមានឯកសារជាលាយលក្ខណ៍អក្សរចំពោះមុខដែលសរសេរអំពីខ្លឹមសារ ឬក៏រឿងរ៉ាវអ្វីដែលលោកស្រីបានដឹងត្រូវឆ្លើយដែរឬទេ?

**ឆ៖** មុននឹងនេះ នាងខ្ញុំបាននេះខ្លួនខ្ញុំ គឺថា ហៅថា អីគេ-- ព្រាងជាប្រវត្តិរបស់ខ្លួនខ្ញុំរហូតមកខ្ញុំទន្ទេញខ្លួនខ្ញុំ។ ខ្ញុំមិនដឹងថាតុលាការនេះយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំព្រៀងជាប្រវត្តិរបស់ខ្លួនខ្ញុំ តាមជំនាន់មួយៗរហូត។ ឧទាហរណ៍ថាពី៧០ -- មុន៧៥ ក្រោយមក ៧៥, ៧៩ ក្រោយមកនេះអ៊ីចឹង។ ខ្ញុំព្រៀងជារបស់ខ្ញុំបន្តៗមក។

**ស៖** តើលោកស្រីចង់ជម្រាបថាក្នុងរយៈពេល៦ ឬ៧ឆ្នាំ ស្វាមីរបស់លោកស្រីជាប់ឃុំ ហើយលោកស្រីមិនៗធ្លាប់ជួបជាមួយតំណាងមេធាវីការពារក្តីរបស់គាត់ ហើយមិនដែលបានពិភាក្សាអំពីអ្វីដែលលោកស្រីនឹងត្រូវនិយាយ ឬក៏ត្រូវឆ្លើយពីរឿងហេតុនោះទេ។ តើបានជួបពួកគាត់ ឬក៏មិនធ្លាប់បាន?

**ឆ៖** ចាស បានជួប។

[១៣:៤៦:១៥]

**ស៖** នៅពេលដែលលោកស្រីបានជួបគាត់ តើពួកគាតបានសួរសំណួរមកលោកស្រី ហើយបានកត់ត្រូវនូវចម្លើយរបស់លោកស្រីនៅក្រដាសដែរឬទេ?

**ឆ៖** ការជួបនេះគឺខ្ញុំជួប គឺថាទី១ដោយសារថាមេធាវីប្តីខ្ញុំ ហើយសួរពីរឿងការសវនាការអីដល់ណាហើយៗ។ ទី២ មុននឹងចូលមកធ្វើសាក្សី កាលពីប្រហែលជាខែ២ ខ្ញុំបានជួបលោកមេធាវីម្តង គឺថានិយាយអំពីចរិត។ និយាយអំពីចរិតលោក ខៀវ សំផន។

**ស៖** មុនពេលដែលលោកស្រីមកតុលាការកាលពីម្សិលមិញនោះ ហើយខ្ញុំចង់ឲ្យលោកស្រីគិតបន្តិចមុននឹងឆ្លើយ។ តើក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ធ្លាប់បានរៀបចំចម្លើយ ហើយនិងកំណត់ហេតុអ្វីដើម្បីឲ្យលោកស្រីចុះហត្ថលេខា និងផ្តិតមេដៃនោះដែរឬទេ?

**ឆ៖** ដូចអត់មានទេ។

**ស៖** មុនពេលដែលលោកស្រីអញ្ជើញមកតុលាការម្សិលមិញ តើលោកស្រីធ្លាប់ក្នុងឱកាសណាមួយដែរឬទេប្រាប់មេធាវី ដែលជាមេធាវីការពារក្តីលោក ខៀវ សំផន ថា គិតថាមានការមនុស្សជាច្រើនដែលភៀសខ្លួនចេញពីក-៣ បាទ ដែលថាចេញដំណើរមុនពីលោកស្រីទៅនៅក-៣ នោះ?

[១៣:៤៨:៤៧]

**ផ៖** អត់យល់។ ចាស អត់យល់ពីសំណួរ។

**ស៖** មុនពេលដែលលោកស្រីមកតុលាការពីម្សិលមិញនេះ តើលោកស្រីធ្លាប់ -- មុនពេលហ្នឹងប្រាប់អ្នកណាម្នាក់ ឬប្រាប់មេធាវីណាម្នាក់ ឬក៏តំណាងរបស់មេធាវីហ្នឹងដែរឬទេ ដែលជាមេធាវីការពារក្តីរបស់លោក ខៀវ សំផន ថាមេដឹកនាំជាន់ខ្ពស់ទាំងអស់បានចាកចេញពីក-៣ ចោលលោកស្រីហើយនិងប្តីលោកស្រីនៅទីនោះ? តើលោកធ្លាប់ -- លោកស្រីបាននិយាយប្រាប់អ្នកណាម្នាក់ថាអ៊ីចឹងដែរឬទេ?

**ផ៖** ក្រោយពេល-- ខ្ញុំអត់យល់។ ក្រោយពេលនៅ ក-៣ ជាមួយមេធាវីខ្ញុំបានជួប ប៉ុន្តែជួបគ្រាន់តែប្រាប់ពីរឿងមកសវនាការ។ តែអារឿងដូចនិយាយ រឿងស្អី ចេញពីក-៣ស្អីដូចមិនមាន -- ខ្ញុំអត់យល់ចាស។

**ស៖** លោកស្រីបានឆ្លើយហើយ សូមអរគុណបាទ។ លោកស្រីមិនបានប្រាប់លោកមេធាវីលោក ខៀវ សំផន ថាមេដឹកនាំជាន់ខ្ពស់ចាកចេញពីក-៣ទេ។ តើលោកស្រីបានជជែកបញ្ហាហ្នឹងជាមួយអ្នកណា? ប្រសិនបើមានអ្នកណាម្នាក់ដែលបានជជែកពីបញ្ហាហ្នឹងទេ ពីរឿងដែលថាមេដឹកនាំជាក់ខ្ពស់ចេញទៅទុកតែលោកស្រី និងប្តីនៅនឹងក-៣នោះ?

[១៣:៥១:១០]

**ផ៖** ខ្ញុំទើបតែនិយាយពេលសវនាការពេលម្សិលមិញ ដូចមានលោកមេធាវី ឬក៏លោកឯណាបានសួរ។

**ស៖** នៅក្នុងរយៈពេល៦ឆ្នាំដែលលោក ខៀវ សំផន ជាប់ឃុំឃាំង។ តើលោកស្រីបានជួបគាត់រៀងរាល់សប្តាហ៍ដែរឬទេ?

**ផ៖** ខ្ញុំមកជួបគាត់ក្នុងពីមុនដែលគាត់មិនទាន់មានសវនាការជាប់ គឺខ្ញុំមកជួប១អាទិត្យពីរដងឬក៏បីដង ឬក៏ម្តង តាមជាក់ស្តែង។ ពេលខ្លះគាត់ឈឺអ៊ីចឹងទៅក៏មក១អាទិត្យអីបានបីដងអ៊ីចឹង។

**ស៖** ឥឡូវនេះយើងនិយាយថា ១អាទិត្យពីរដង គឺថា៦០០ដង។ តើក្នុងពេលជំនួបណាមួយដែល

លោកស្រីនិយាយជាមួយគាត់ថាមានមេដឹកនាំណាចាកចេញពីក-៣ទេ នៅក្នុងការជួបទាំង៦០០ដងនោះ ធ្លាប់បាននិយាយជាមួយគាត់ពីរឿងហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[១៣:៥២:៤៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះមេលេខគណនារបស់តំណាងសហព្រះរាជអាជ្ញា។ ខ្ញុំមិនដឹងថាលោកគណនាយ៉ាងម៉េចបានចេញ៦០០ដងទេ។ អំមិញហ្នឹងដែលថាប្រពន្ធលោក ខៀវ សំផន ជួបលោក ខៀវ សំផន នោះព្រោះគាត់និយាយថាជួនកាល។ អ៊ីចឹងក្នុងអាទិត្យខ្លះគាត់អាចជួបបីដង អាទិត្យខ្លះគាត់ជួបបានពីរដង អាទិត្យខ្លះជួបបានម្តង អាទិត្យខ្លះអត់បានជួបទេ។ បាទ បើអ៊ីចឹងចំនួននេះស្ថិតនៅក្នុងកម្រិតណាមួយពីចំនួនច្រើន និងចំនួនតិច លោកមិនអាចយកចំនួនច្រើនយកមកគណនា ហើយចេញជាតួលេខតែម្តងទេ។ អ៊ីចឹងសូមលោកគណនាសាថ្មី បើសិនជាលោកចង់គណនាបាទ។ សូមអរគុណ។

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំនឹងរៀបសំណួរខ្ញុំឡើងវិញ។

[១៣:៥៣:៤៤]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** នៅក្នុងរយៈពេល៦ឆ្នាំដែលលោក ខៀវ សំផន ស្ថិតនៅក្នុងការឃុំខ្លួន លោកស្រីបានទៅលេង ជួបគាត់ជាទៀងទាត់។ តើលោកធ្លាប់និយាយជាមួយគាត់អំពីមេដឹកនាំជាន់ខ្ពស់ទាំងអស់ដែលចាកចេញពីក-៣ ដែរឬទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** រឿងទាំងអស់នេះ គឺប្តីខ្ញុំក៏ដឹងដែរ។ អង្កាល់ពីមេដឹកនាំទាំងអស់ដែលមកនៅក-៣ គឺត្រូវចេញៗទាំងអស់ អាហ្នឹងមានប៉ុណ្ណឹង ហើយដល់ក្រោយមកអត់មានអី។

**ស៖** ឥឡូវនេះខ្ញុំយកពាក្យនេះថាលោកស្រីបានពឹងផ្អែកទៅលើអ្វីដែលគាត់បានប្រាប់លោកស្រី?

**ឆ៖** ប្រាប់ គាត់អត់ប្រាប់ខ្ញុំផង។ កាលនោះ ខ្ញុំសូម -- ខ្ញុំស្តាប់គេហៅថាសំណួរមិនសូវយល់ទេ ចាស ដូច្នេះខ្ញុំក៏ពិបាកឆ្លើយ។ រឿងអីដែលខ្ញុំដឹង ខ្ញុំឆ្លើយ ខ្ញុំខំឆ្លើយ ខ្ញុំអត់មាន ឆ្លើយដោយស្មោះ។ ប៉ុន្តែ រឿងអីដែលខ្ញុំអត់ដឹងមិនដឹងជាឆ្លើយយ៉ាងម៉េច។ ដូច្នេះសំណួរនេះខ្ញុំក៏អត់សូវយល់ៗដែរ លោកចង់មាន ប្រសាសន៍ថាយ៉ាងម៉េច? ចង់សួរថាយ៉ាងម៉េច? កាលពីមេដឹកនាំអីចេញពីក-៣ អី ខ្ញុំបានមាននិយាយរួច ទៅហើយ គឺនៅបានប៉ុន្មានខែគេចេញអស់ ហើយខ្ញុំក៏មិនដឹង។

**ស៖** នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១០ តើលោកស្រីបានទៅជួប តាសុត ហើយនិង ស សៀក ដែរឬទេ?

[១៣:៥៥:៥០]

**ឆ៖** ខ្ញុំមិនចាំថ្ងៃខែ អង្កាល់នោះខ្ញុំទៅការគេ។ ទៅការបងប្អូននៅសំឡូត ដែលគេហៅទៅ ពេល នោះ ទៅស៊ីការរួចហើយ ក៏មានជួបបង ជួបក្មួយម្នាក់ឈ្មោះ លីន ហើយនៅទីនោះមានអ្នកស្គាល់ច្រើន ដែលនៅ ហើយបែកគ្នាប្អូនដប់ឆ្នាំហើយ។ ដូច្នេះពេលនោះខ្ញុំក៏សួរក្មួយ លីន ហ្នឹង ហើយក្មួយ លីនក៏ ប្រាប់ដែរគឺថា "មីងអ្ហា!ពូៗនៅនេះច្រើនណាស់"។ ចាស នេះខ្ញុំសូមរៀបរាប់ឲ្យវែងបន្តិចចុះ សូម អភ័យទោសលោកប្រធាន ដើម្បីដឹងរឿង។ ហើយពេលនោះខ្ញុំថា អ៊ីចឹងចង់ទៅលេងដល់ហើយ លេង តោះទៅលេងផ្ទះពីណាមាន តួន មានសុត មានសែន មានអី មួយជន្លាសហ្នឹងទៅ ហើយខ្ញុំថា ឥឡូវហ្នឹង ណែនាំគ្នាទៅលេងផ្ទះពីណាជិតជាងគេ នៅជិតកន្លែងគេការហ្នឹង ព្រោះគេស៊ីការថ្ងៃ។ ពេលរួចពីការ ហើយក៏គាត់ក៏ឌុបខ្ញុំមកផ្ទះ សៀក, សុត ហ្នឹង។ ចាស មកផ្ទះ ស សៀក ហ្នឹង។ មកដល់ក៏ជួបគាត់នៅ ក្រោមផ្ទះ ដល់ជួបក្រោមផ្ទះ ហើយគាត់ក៏សួរសុខខ្ញុំ ខ្ញុំក៏សួរសុខទុក្ខគាត់ តែ សុត គាត់អត់នៅទេ គាត់ នៅតែគាត់ទេ នៅតែ សៀក ទេ។ ខ្ញុំថាម៉េចហើយ សុខសប្បាយអីៗ ធ្វើអី? គាត់ថាគាត់នៅបន្ទាយ។ ហើយខ្ញុំក៏ថា "អី!នៅបន្ទាយនេះដែរហ៎! ហើយថាម៉េចទៅពួកគ្នានៅនេះសុខសប្បាយទេហ៎?" "ថាមាន សុខសប្បាយទេ មានគេមកសួរអីៗអ៊ីចឹង" ខ្ញុំថា "អ្ហ៎! គេមកសួរដែរខាងនេះគេមកសួរដែរអី?" ថា "ចាស គេមកសួរដែរតើមីង"។ ខ្ញុំថាយ៉ាងម៉េចដែរ? ខ្ញុំក៏និយាយលេង យើងក៏ចេះតែធម្មតាអ្នកដែល ស្គាល់។ ឯ សៀក ហ្នឹងខ្ញុំមិនសូវស្គាល់ទេពីមុនមក មកស្គាល់ពេលដែលវៀតណាមចូលមកនេះហើយ ទេ។ ដូច្នេះរឿងហ្នឹងក៏សួរសុខទុក្ខអីហើយ គាត់ថា "ហ៊ឺម៉េចហើយ?" "ថាគេមកសួរដែរ"។ ហើយ "អ៊ីចឹងម៉េចហើយឯង?" គាត់ថា "បងប្អូនខ្លាចចង់ងាប់ហើយ"។ ខ្ញុំថា "ខ្លាចម៉េច?" "ហ៎! ពូតាន ចង់ ចងក កុំតែគេទៅជួយទាន់ទេ"។ ខ្ញុំថា "ម៉េចអ៊ីចឹង? ថា អូយ! ទៅខ្លាចធ្វើអី ម៉េចក៏មិននេះទៅ គេសួរអី

ឆ្លើយហ្នឹងទៅ ហើយនៅជាក់ស្ដែងហ្នឹង យើងឆ្លើយទាំងអស់ទៅ យើងកុំទៅខ្លាច ប្រាប់ហើយ ប្រាប់ពូសុតទៅ" ខ្ញុំថាអ៊ីចឹង។ ប្រាប់ទាំងគាត់ ហើយអ្នក -- លីន ហ្នឹងក៏នៅហ្នឹងដែរ។ ខ្ញុំថា ប្រាប់ពូសុត ទៅ ហើយខ្ញុំមកអត់បានជួប។ ដូច្នេះ សៀក ឯងប្រាប់គាត់ផងទៅ យើងនិយាយទៅ មានអីនិយាយហ្នឹងទៅ។ ហ្នឹងហើយ ហើយ--

[១៣:៥៩:០០]

**ស៖** តើលោកស្រីបានពិភាក្សាគ្នាជាមួយលោកស្រី ស សៀក ថាប្ដីរបស់លោកស្រីថាមានទំនាក់ទំនងក្រសួងឃោសនាការ ហើយនិងការផ្លាស់ប្ដូរទីតាំង ហើយជាពិសេសការទៅឈរជើងធ្វើការនៅព្រែកក្ដាមនោះដែរឬទេ?

**ឆ៖** រឿងនេះ ស សៀក គាត់និយាយពីរឿងគាត់ដើរមកពី កាលពីរំដោះភ្នំពេញហើយគាត់ដើរមកតាមព្រែកក្ដាម ខ្ញុំថាខ្ញុំអត់ដឹងទេ ព្រោះខ្ញុំមក ខ្ញុំមកក្រោយ១អាទិត្យហើយ។ ហើយគាត់និយាយថា គាត់ហ្នឹងមក គាត់ដើរមក អីអ៊ីចឹង ហើយទៅឃោសនាការ ក៏ខ្ញុំអត់ដឹងដែរ។ អាហ្នឹងគាត់អ្នកនិយាយខ្លួនគាត់ ខ្ញុំក៏អត់ដឹងទេ។ ហើយគាត់នេះ គាត់អ្នកនិយាយ គាត់នៅឃោសនាការ ស្អីៗអ៊ីចឹង។ តែខ្ញុំ ខ្ញុំអត់មានបាននិយាយពីនេះទេ។ មានតែនិយាយរឿងមួយថា "ហ៊ុះ! មកហើយ ចង់ជួប សុត ដែរហ្នឹងណា ថាអ៊ីចឹង។ មានតែ សុត ទេដឹង។ ថាបើៗ ប៉ាខ្ញុំទៅណាខ្លះ មានតែ សុត ទេដឹង" អាហ្នឹងខ្ញុំនិយាយ។ ព្រោះពេលនោះ យើងចូលមកនៅឯណាទេ ហើយពួកគេនៅខាងក្រៅ, ពួកសុត អីគេធ្វើនីរសារនៅខាងក្រៅ។ ខ្ញុំថាមានតែ សុត ទេដឹងនោះ។ ហ្នឹងខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១៤:០០:៥៨]

**ស៖** នៅក្នុងសក្ខីកម្មរបស់គាត់ឆ្លើយជូនតុលាការនៅម៉ោង ១៥:២៥:០០ លោកស្រី ស សៀក បានឆ្លើយដូចតទៅអំពីលោកស្រី។ ខ្ញុំសូមដកស្រង់សម្ដីរបស់គាត់។ ឯកសារនេះ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២។ "គាត់" (គាត់នេះសំដៅទៅលើលោកស្រី) "គាត់សួរថាតើ ខៀវ សំផន ធ្លាប់ទៅព្រែកក្ដាមដែរឬទេ? ហើយធ្លាប់ទៅកន្លែងឃោសនាការដែរឬទេ?" គេបញ្ជាក់ថា លោកស្រីអ្នកសួរគេទេ មិនមែនគេជាអ្នកសួរលោកស្រីនោះទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** រឿងនេះ គាត់ថាគាត់នៅឃោសនាការ។ ដល់អ៊ីចឹងទៅ ខ្ញុំក៏សួរគាត់បណ្ដោយទៅ ថាគាត់ធ្លាប់ទៅអត់។ ហើយដូចជាព្រែកក្ដាម ដូចអី មិនទេ មិនទាក់ទងជាមួយ សៀក ទេ។ ទាក់ទង ខ្ញុំថាចង់សួរស្អីទេ ប្ដីគាត់ទេ។ ថាគាត់មានដែលចេញទៅព្រែកក្ដាម ឬក៏ទៅណាទេ? ហើយបើសិនជា សុត នៅ

ហ្នឹងអាចដឹងហើយ ថាអ៊ីចេះ។ អាហ្នឹង ខ្ញុំមាននិយាយមែន។ មាននិយាយអ៊ីចឹង។

**ស៖** តើហេតុអ្វីបានជាចាំបាច់សួរ សុត ឲ្យទៅសួរ សុត ធ្វើអី? ហើយគាត់ធ្វើអីនៅព្រៃកក្តាម ហ្នឹង? ហើយហេតុអ្វីបានជាលោកស្រីសួរបញ្ហាហ្នឹងទៅកាន់គេដើម្បីដឹងនោះ ហេតុអ្វីទៅ?

**ផ៖** អង្កាល់ហ្នឹងគឺដូចជាមានស្អី ដែលយើងខ្ញុំក្តាប់បាន ដូចជាមានស្អីទេ -- ដូចជាមានអ្នកណា និយាយពីរឿងនៅព្រៃកក្តាមទេនេះ។ និយាយប្រាប់ខ្ញុំ ហើយខ្ញុំក៏នឹកឃើញថាទៅលេងហើយ ក៏ខ្ញុំនិយាយ អ៊ីចឹងទៅ។ ពីណាទេ។

[១៤:០៣:៤១]

**ស៖** ស សៀក បានប្រាប់តុលាការនេះថា ស សៀក ហ្នឹងថា "គាត់មិននៅព្រៃកក្តាម ឬក៏នៅ ឃោសនាការនោះទេ"។ ដូច្នេះហើយហេតុផលហ្នឹងហើយ ទើបលោកស្រីទៅសួរថាតើប្តីរបស់លោក ស្រីនៅទីនោះ ឬក៏អត់? តើ ស សៀក មានបានប្រាប់ចំណុចហ្នឹងទៅលោកស្រីដែរឬទេ?

**ផ៖** ខ្ញុំស្តាប់មិនយល់។

**ស៖** នៅក្នុងការផ្តល់ភស្តុតាងរបស់លោកស្រី ស សៀក ប្រាប់តុលាការនេះ លោកស្រី ស សៀក បានប្រាប់ជម្រាបថៅក្រមថា -- ខ្ញុំមានការដក មានឯកសារនេះ -- ដកស្រង់ពាក្យដើមតែម្តង គឺម៉ោង ១៥:២៧:០០ នៅក្នុងឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី ស សៀក ចុះថ្ងៃ១៦ ខែសីហា ២០១២។ សំណួរ សំណួរនេះសួរទៅកាន់លោកស្រី ស សៀក "តើលោកស្រី និងប្តីរបស់ លោកស្រី – គឺចង់សំដៅទៅលើលោកស្រី – ហេតុអ្វីបានជាលោកស្រីចាប់អារម្មណ៍ថា តាសុត ហ្នឹង គាត់ឃើញ ឬមិនឃើញ ខៀវ សំផន នៅព្រៃកក្តាម ឬក៏នៅក្រសួងឃោសនាការ?" ចម្លើយរបស់អ្នក ស្រី ស សៀក នៅក្នុងកំណត់ហេតុឆ្លើយដូចតទៅ៖

[១៤:០៥:២២]

"ប្រពន្ធរបស់ ខៀវ សំផន បានមក ហើយសួរសំណួរដូច្នេះ ដោយសារតែលោក ខៀវ សំផន មិនចាំថាតើគាត់ហ្នឹងបានទៅព្រៃកក្តាម ឬក៏ក្រសួងឃោសនាការឬទេ។ ដូច្នេះ តើហេតុផលដែល លោកស្រីធ្វើដំណើរទៅជួប ស សៀក ហើយសួរហ្នឹងគឺដោយសារតែលោកស្រីធ្លាប់ជួបប្តីរបស់លោក ស្រីនិយាយគ្នា ហើយគាត់បានប្រាប់លោកស្រីថា "ខ្ញុំមិនចាំទេ ថាតើខ្ញុំបានទៅក្រសួងឃោសនាការ ឬក៏បានទៅព្រៃកក្តាម"។ ដូច្នេះតើលោកស្រីនេះអាច ប្តីលោកស្រីគាត់សួរថា តើលោកស្រីអាចទៅជួប ជាមួយ ស សៀក ដើម្បីសួរពីបញ្ហាហ្នឹងដែរឬទេ? ដូច្នេះថាតើហេតុផលហ្នឹងហើយទើបលោកស្រីទៅ

សួរហ្នឹង អ៊ីចឹងដែរឬទេ?

[១៤:០៦:៤៨]

**ឆ៖** តាមការពិតទៅ គឺខ្ញុំមិនមានបំណងអីទៅសួរ ស សៀក អ៊ីចឹងទេ។ ខ្ញុំគ្រាន់តែទៅលេង ដល់ពេលនិយាយសួរសុខទុក្ខគ្នាទៅវិញ ទៅមក។ អាហ្នឹង ស សៀក គាត់ចាប់អារម្មណ៍យ៉ាងម៉េច អី យ៉ាងម៉េច ខ្ញុំអត់ដឹងទេ គ្រាន់តែសួរសុខទុក្ខគ្នាទៅវិញទៅមក ហើយម៉េចគេចោទប្រកាន់អីយ៉ាងម៉េច អី សួរចុះឡើងអ៊ីចឹងទៅ។ ខ្ញុំក៏នឹកឃើញអង្កាល់ហ្នឹង មិនដឹងជាគាត់ ឬមួយក៏អ្នកទេមានដឹងរឿងថា គាត់ធ្លាប់ទៅ ឧទាហរណ៍ថាទៅអីគេ ឃោសនាការ ទៅស្ទឹ ព្រែកក្ដាម។ ហើយខ្ញុំថា គេចេះតែឆ្លើយផ្ដេស-- គេចេះតែថាយ៉ាងផ្ដេសផ្ដាសអ៊ីចឹងទៅណា។ "ឥឡូវហ្នឹងគាត់ធ្លាប់ទៅមែនឬអី? ហើយឯងដែលឃើញទេឯងនៅឃោសនាការ" ថាអ៊ីចឹង។ ហើយរឿងនេះបើសិនជា សុត នៅហ្នឹងខ្ញុំសួរ សុត ទៀតហើយ។ ថាតើ សុត ដែលធ្លាប់ឃើញគាត់ទៅដែរអត់។

ខ្ញុំសូមជម្រាបដោយស្មោះ អាហ្នឹងគឺការនិយាយរបស់ខ្ញុំ ខ្ញុំខំនឹកឡើងវិញដើម្បីជម្រាបជូនតុលាការ ពីព្រោះអីការនិយាយនោះ ខ្ញុំមិនបានចាប់អារម្មណ៍ថាគេមានរឿងដល់មកអ៊ីចឹង ខ្ញុំអត់ចាប់អារម្មណ៍ទេ។ អ៊ីចឹងហើយបានខ្ញុំចេះតែរកនឹក តើខ្ញុំមាននេះ រឿងហ្នឹងមកពីណា។ ជួនកាលសួរសុខទុក្ខអីគេ ចេះតែសួរចុះឡើងទៅ ខ្ញុំក៏នឹកឃើញ ខ្ញុំសួរ។ ដូច្នេះសូមតុលាការអធ្យាស្រ័យ ខ្ញុំនិយាយវែងបន្តិច។

[១៤:០៨:៤៣]

**ស៖** លោកកំពុងតែជម្រាបតុលាការនេះថា លោកស្រី ស សៀក នោះ អ្វីដែលគាត់និយាយហ្នឹងមិនត្រឹមត្រូវទេ ហើយចម្លើយរបស់លោកស្រីរបស់លោកស្រីទើបត្រឹមត្រូវ?

**ឆ៖** ខ្ញុំមិនអាចសន្និដ្ឋានថាគេមិនត្រូវ ក៏ខ្ញុំត្រឹមត្រូវ ក៏ខ្ញុំមិននេះទេ ពីព្រោះអីការនិយាយលេងវាតែងតែនិយាយ ហៅថារឿងរ៉ាវដែលធ្លាប់រស់នៅជាមួយគ្នាអីៗតៗមកអ៊ីចឹង។ ហើយរឿងរ៉ាវខ្លះដែលយើងសួរគ្នាទៅវិញទៅមក ហើយនិយាយពីអ្នកនេះអ៊ីចេះ អ្នកនោះអ៊ីចុះ។ ដូច្នេះ ខ្ញុំមិនសន្និដ្ឋានថាគេនិយាយខុស ឬនិយាយត្រូវទេ ប៉ុន្តែពេលនោះខ្ញុំដូចជាចាំនិយាយអ៊ីចឹង។

**ស៖** នៅក្នុងសក្ខីកម្មរបស់លោកស្រី ស សៀក ចុះថ្ងៃ១៦ ខែសីហា ឆ្នាំ២០១២ ម៉ោង១៥:០៥:០០ លោកស្រី ស សៀក បានឆ្លើយដូចតទៅថា គាត់បានឃើញប្ដីរបស់លោកស្រីនោះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ក្រោយមកប្ដីរបស់លោកស្រីបានទៅផ្នែកឃោសនាការ ហើយគាត់នៅទីនោះប្រហែលជាពីរបីយប់ដែរ។ តើប្ដីរបស់លោកស្រីដែលធ្លាប់បានជម្រាបប្រាប់លោកស្រីថា គាត់បានចំណាយពេលបីបួន

ថ្ងៃ ឬក៏បីបួនយប់នៅឃោសនាការ ក្រោយពីជម្លៀសទីក្រុងភ្នំពេញភ្លាមៗដែរឬទេ?

[១៤:១០:៣៤]

**ឆ៖** ក្រោយពីជម្លៀសខ្ញុំអត់ដែលបានឮគាត់និយាយថាទៅណាទេ ព្រោះ១អាទិត្យក្រោយដែលខ្ញុំមកជួបគាត់នៅស្តុកតោល ក៏គាត់ថាគាត់មិនទាន់បានទៅភ្នំពេញផង។ ទើបតែចេញទៅព្រឹកហ្នឹង។ ដូច្នេះខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំចង់សួមសួរអំពីបងប្អូនប្រុសស្រីរបស់លោកស្រីដែលនៅសៀមរាប ដែលជាប់នៅគុកសៀមរាប។ លោកចៅក្រម ឡាវ៉ែន៍ កាលពីព្រឹកមិញបានដកស្រង់ចេញមកពីលិខិតមួយច្បាប់ដែលប្តីរបស់លោកស្រីបានអំពាវនាវទៅដល់ជនស្នេហាជាតិ។ ឯកសារនេះមានលេខ E3/205, លោកស្រីកាលពីព្រឹកមិញបានបញ្ជាក់រួចមកហើយថា គាត់បាននិយាយថាលោកស្រីបានធ្វើដំណើរទៅទាំងយំសស្រាក់។ ដូច្នេះខ្ញុំសូមដកស្រង់សម្តី៖

"ប្រពន្ធរបស់ខ្ញុំនេះ បាននិយាយទាំងហូរទឹកភ្នែកថាបងប្អូនរបស់គាត់ត្រូវបានគេចាប់ខ្លួន ហើយត្រូវគេចាប់ដាក់ខ្នោះដៃជើងអស់រយៈពេលជាង១ឆ្នាំ។ ដំបៅរលេះរលួយជាមួយប្រជាជនជាច្រើនទៀត"។

[១៤:១២:០៨]

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០១២ តុលាការនេះបានស្តាប់សក្ខីកម្មរបស់បុគ្គលមួយរូបឈ្មោះមាស វឿន នៅម៉ោង ១៤:០៧:៣២ គាត់បាន -- លោកសាក្សី មាស វឿន បានឆ្លើយដូចតទៅ៖ គាត់បានទទួលសារទូរលេខពីលោក ខៀវ សំផន ដែលក្នុងសារទូរលេខនោះស្នើសុំឱ្យគាត់រាយការណ៍អំពីមនុស្សដែលជាប់គុកនៅសៀមរាប រួមទាំងសមាជិកគ្រួសាររបស់លោកស្រីផងដែរ។ ចំណុចទី២ ក្រោយមកគាត់បានទៅធ្វើការស៊ើបអង្កេត។ ទី៣ គាត់ មាស វឿន បានរាយការណ៍អំពីបង ប្អូនស្រីរបស់លោកស្រីឈ្មោះ យៀត ដែលជាប់ឃុំនៅគុកសៀមរាបរបស់របបចាស់។ ចំណុចទី៤ លោក មាស វឿន បានទៅគុកហ្នឹងជាមួយនឹង តាសឿង។ ទី៥ មានអ្នកទោសប្រហែល៧០០នាក់ ជាប់នៅគុកនោះ។ ទី៦ ប្អូនស្រីរបស់លោកស្រីត្រូវបានគេដោះលែងចេញពីគុកនោះ ក៏ប៉ុន្តែអ្នកគុកផ្សេងទៀតនៅតែជាប់នៅទីនោះដដែល។

**ប្រធានអង្គជំនុំ៖**

ឈប់សិន! លោកតំណាងសហព្រះរាជអាជ្ញាមានការជំទាស់ពីមេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញលោកមេធាវី!

[១៤:១៤:១២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ការលើកបង្ហាញរបស់តំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះយើងអត់បានក្តាប់ទាន់ថាជាឯកសារអី ហើយដកស្រង់ពីចំណុចណា អ៊ីចឹងទៅយើងអត់អាចធ្វើការតាមដានទាន់ចំពោះការបង្ហាញឯកសារនេះទេ សូមឲ្យលោកជួយបង្ហាញបញ្ជាក់ដែលទាក់ទងទៅនឹងការលើកបង្ហាញអម្បាញ់មិញនេះបាទ។

**លោក ឃីត វេយ៍ន័រ៖**

លោក មាស វឿន បានរាយការណ៍អំពីការដោះលែង។ ហើយទី៨ គឺតំបន់ស្វយ័តបានរាយ-ការណ៍ផ្ទាល់តែម្តងទៅ ខៀវ សំផន។ ឯកសារ E1/130.1--

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀត។ អំមិញអត់មានការបកប្រែនៃការកំណត់អត្តសញ្ញាណឯកសារ ដែលសំអាងយកមកដេញដោលនាពេលនេះ ដែលស្នើសុំដោយមេធាវីការពារក្តី ហើយលោកបន្តទៅទៀត។ ឥឡូវហ្នឹងអ្នកបកប្រែកគេបកប្រែហើយ បកប្រែបញ្ជាសគ្នាអ៊ីចឹង។

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សហព្រះរាជអាជ្ញាគាត់លើកពីឈ្មោះឯកសារ អរគុណគាត់ហើយ ប៉ុន្តែការដាក់តែឈ្មោះឯកសារហើយ មិនប្រាប់ទីតាំងនេះក៏យើងមិនអាចធ្វើការតាមដានបានដែរ។ អ៊ីចឹងសូមលោកបញ្ជាក់ពីទីតាំងឯកសារហ្នឹងផង ERN លេខប៉ុន្មានអីប៉ុន្មានបាទ។ សូមអរគុណ។

[១៤:១៥:៥៦]

**ប្រធានអង្គជំនុំ៖**

សូម ត្រឹមត្រូវណាស់ យើងបានដេញដោលច្រើនហើយ ១ឆ្នាំជាងទៅហើយលើនីតិវិធីនៃការដេញដោលសវនាការរបៀបនេះ មិនគួរមានការឆកល្វែងដូច្នេះទេ។ សូមបញ្ជាក់ឡើងវិញថា ឯកសារទាំងអស់ដែលដាក់បង្ហាញ ដាក់ដេញដោលត្រូវតែបង្ហាញអំពីអត្តសញ្ញាណឯកសារ ព្រមទាំងលេខ ERN នៃទំព័រនៃចំណុចដែលពាក់ព័ន្ធ ដែលថាលើកយកមកដេញដោលផង។ បញ្ហាទី១។ បញ្ហាទី២ សូមជម្រាបជូនលោកតំណាងសហព្រះរាជអាជ្ញា ពេលវេលាដែលអង្គជំនុំជម្រះជូនទៅលោក គឺពេលវេលាសមស្រប

តែពេលវេលាដែលសម្រាប់ចែកជូនទៅលោកប៉ុណ្ណោះ ដោយលៃពេលវេលាដែលនៅសល់ព្រឹកមិញ គឺ ៤០នាទី ហើយបូកទាំងពេលវេលាសម្រាប់មេធាវីការពារក្តី នួន ជា ផង។ មិនមែនឲ្យលោកប្រើពេលវេលាអស់មួយរសៀលនេះនោះទេ។ សូមជ្រាប!

[១៤:១៧:០២]

**លោក ឃីត វេយ័ន្ត៖**

លោកប្រធាន ខ្ញុំសូមធ្វើសំណើដូចអ៊ីចេះតទៅ៖ ខ្ញុំសូមសន្និដ្ឋានដោយគោរពថា សាក្សីរូបនេះ គឺជាសាក្សីមួយរូបសំខាន់ក្នុងចំណោមសាក្សីទាំងប្រាំនៅក្នុងសំណុំរឿងនេះ។ ដូច្នេះខ្ញុំសូមអនុញ្ញាតស្នើសុំឲ្យអង្គជំនុំជម្រះផ្តល់ពេលវេលាពេញមួយល្ងាចនេះតែម្តង សួរទៅកាន់លោកស្រី សូ សុជាតិ។ ខ្ញុំនៅសល់បញ្ហាសំខាន់ៗមួយចំនួនទៀតដើម្បីដេញដោលសួរសំណួរទៅកាន់គាត់។ ដូច្នេះខ្ញុំស្នើសុំថា យុត្តិធម៌យើងនឹងមិនអាចរកឃើញនោះទេ ប្រសិនបើយើងខ្ញុំនេះ ពេលវេលារបស់ខ្ញុំនេះត្រូវបានកាត់បន្ថយមិនឲ្យពេញ១ថ្ងៃ ពេញមួយរសៀលនេះ។ ដូច្នេះជាសំណើសុំរបស់យើងខ្ញុំសម្រាប់ថ្ងៃនេះ លោកប្រធាន។

[១៤:១៧:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២១:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពសាជាថ្មី។ មុននឹងអង្គជំនុំជម្រះពិភាក្សាអម្បាញ់មិញនេះ អង្គជំនុំជម្រះ ជាពិសេសលោកប្រធានបានបង្គាប់ឲ្យតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារជាពិសេសទាក់ទងទីតាំងឯកសារ លេខទំព័រ ឬក៏លេខ ERN។ ក៏ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាមិនទាន់បានធ្វើតាមការណែនាំរបស់លោកប្រធាននៅឡើយទេ ហើយបានបង្កើតនូវបញ្ហាថ្មីមួយទៀតគឺស្នើសុំពេលវេលាបន្ថែម។ អ៊ីចឹងខ្ញុំសូមឲ្យលោកប្រធានមេត្តាបង្គាប់ទៅតំណាងសហព្រះរាជអាជ្ញាឲ្យបញ្ជាក់អំពីលេខ ERN ឬក៏ទីតាំងទំព័រជាក់លាក់ទៅលើឯកសារដែលលោកបានលើកឡើងអម្បាញ់មិញនេះ បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះរំឭក និងជម្រាបជូនរួចហើយ មិនមែនតែភាគីតំណាងសហព្រះរាជអាជ្ញាមួយទេ ភាគីពាក់ព័ន្ធដទៃទៀតសូមឲ្យអនុវត្តឲ្យបានទៀងទាត់នូវរបៀបរបបនៃការនីតិវិធីបង្ហាញភស្តុតាងដោយពឹងផ្អែកលើឯកសារដែលមានដូចអ្វីដែលយើងបានធ្លាប់អនុវត្តកន្លងមក ដោយបង្ហាញអំពីអត្ត-សញ្ញាណនៃឯកសារ ព្រមទាំងលេខ ERN នៃទំព័រនីមួយៗដែលពាក់ព័ន្ធនូវចំណុចដែលខ្លួនលើកមកចង់ជជីកសួរដេញដោលចំពោះសាក្សី ឬក៏អ្នកជំនាញ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណី ដូចអ្វីដែលយើងបានកំណត់រួចហើយ។

បញ្ហាទី២ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរ។ សូមសួរនូវសំណួរដែលមានសារប្រយោជន៍ក្នុងការស្វែងរកការពិត ហើយសំណួរដែលភាពពាក់ព័ន្ធ និងសំណួរសក្ដានុពល ចំណែកឯពេលវេលា អង្គជំនុំជម្រះនឹងពិចារណានានៅពេលស្ដាប់បន្តបន្ទាប់នេះ ថាតើគួរផ្ដល់ឲ្យ ឬក៏មិនផ្ដល់ឲ្យទេ។

[១៤:២៣:១២]

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមអរគុណច្រើន។ ខ្ញុំសូមបញ្ជាក់ការដកស្រង់ចេញពីកំណត់ហេតុរបស់ មាស វឿន ខ្ញុំបានបញ្ជាក់ម៉ោងរួចមកហើយ ហើយខ្ញុំនឹងគោរពតាមគោលបំណងនៃ ERN, ហើយយើងគួរតែអនុវត្តទាំងអស់ពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណនេះ។ ពេលវេលាចេញពីប្រតិចារឹក គឺខ្ញុំនឹងបញ្ជាក់ឲ្យបានច្បាស់លាស់។ ខ្ញុំគិតថាបើសិនជាខ្ញុំបញ្ជាក់ទៅលើពេលវេលាក្នុងប្រតិចារឹក គិតថាវាគ្រប់គ្រាន់ហើយ។

ខ្ញុំសូមបន្ថែមទៀតលោកប្រធាន គឺថា ស៊ីដនី-- ចំពោះសាក្សី ស៊ីដនី ស្កេនប៊ឺក នោះ គឺយើងបានអនុវត្តអ៊ីចឹងដែរ យើងបញ្ជាក់ទៅលើពេលវេលាដែលបាន-- ដែលមាននៅក្នុងកំណត់ហេតុប្រតិចារឹក។

[១៤:២៤:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ! ដល់កម្រិតនោះ កាន់តែច្បាស់ទៀត។ បើសិនជាផ្អែកលើប្រតិចារឹក ហើយបានកំណត់អំពីពេលវេលានៅក្នុងប្រតិចារឹកហ្នឹងគឺច្បាស់លាស់ ទំនងជាងការបញ្ជាក់ត្រឹមតែលេខ ERN ទៅទៀត។ ហើយភាគីពាក់ព័ន្ធនានាក៏ ទាំងអង្គជំនុំជម្រះ គឺស្ដាប់បានច្បាស់លាស់លើបញ្ហានេះរួចហើយ

ដែលយើងមានបទពិសោធន៍ក្នុងការធ្វើសវនាការជាង១ឆ្នាំកន្លងមកហើយនេះ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណច្រើនលោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** នៅពេលនេះ ខ្ញុំសូមលើកឡើងកំណត់ហេតុភស្តុតាងរបស់លោក មាស រឿន ដោយផ្អែកទៅលើពេលវេលា។ នៅពេលដែលគាត់ឆ្លើយប្រាប់អ្នកស៊ើបអង្កេតនៅព្រះវិហារ ពាក់ព័ន្ធនឹងការចាប់ខ្លួនបុគ្គលមួយចំនួន គឺនៅមុនម៉ោង ១៤:០៩:៤៥ នៅពេលនោះ គឺគាត់នោះ គឺគាត់បានលើកឡើងថា "ខ្ញុំបានរាយការណ៍ជូន ខៀវ សំផន តាមសារទូរលេខដែលក្នុងរបាយការណ៍ខ្ញុំសរសេរឈ្មោះ និងតំបន់ ១០៣ នៅក្នុងក្រដាសហ្នឹងហើយបានបញ្ជូនទៅកាន់លោក ខៀវ សំផន"។ នៅម៉ោង១៤:១៥:៤៥វិនាទីក្នុងប្រតិចារឹក នៅម៉ោងហ្នឹងដដែលគឺ មាស រឿន បានឆ្លើយថា "មានសារទូរលេខមួយផ្ញើពី ខៀវ សំផន មកខ្ញុំវិញ ដោយក្នុងនោះបង្គាប់ឲ្យខ្ញុំនេះរាយការណ៍អំពីស្ថានការណ៍មួយចំនួនទៅកាន់គាត់គឺ ខៀវ សំផន នេះវិញ។ នៅម៉ោង ១៤:១៣:៣៥ នៅក្នុងប្រចារឹក មាស រឿន បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្តី "ខ្ញុំបានរាយការណ៍ស្ថានការណ៍នៅសៀមរាបជូនលោក ខៀវ សំផន ជាពិសេសអ្នកដែលជាប់គុក ជាប់ឃុំ និងអ្នកដែលក្រោយមក តាសឿង ដោះលែង ដែលក្នុងនុំងរួមមានសាច់ថ្លៃរបស់ ខៀវ សំផន ផងដែរ"។

[១៤:២៦:២៨]

នៅម៉ោងដដែលនៅក្នុងប្រតិចារឹកនេះ គឺគាត់បានឆ្លើយថា (គាត់នេះសំដៅទៅលើ ខៀវ សំផន) "គាត់បានសួរថាតើមានឃើញសាច់ញាតិរបស់គាត់ត្រូវបានគេដោះលែងដែរឬទេ?" នៅម៉ោង១៤:១៥:១៤ ក្នុងប្រតិចារឹក មាស រឿន បានឆ្លើយថា "គាត់បានទៅធ្វើការស៊ើបអង្កេតមានអ្វីកើតឡើងចំពោះសាច់ញាតិរបស់គាត់"។ នៅម៉ោង ១៤:១៧:១៥ ក្នុងប្រតិចារឹក មាស រឿន បានឆ្លើយដូចតទៅ "ពីដើមដំបូងខ្ញុំបានរាយការណ៍អំពីបងស្រីរបស់គាត់ឈ្មោះ យៀត ដែលរស់នៅម៉ាឡៃ ហើយជាប់ឃុំនៅមន្ទីរសន្តិសុខក្នុងខេត្តសៀមរាប"។ ក្នុងម៉ោង ១៤:១៩:១៣ ក្នុងប្រតិចារឹក មាស រឿន បានឆ្លើយដូចតទៅថា យៀត -- ខ្ញុំសូមដកងស្រង់សម្តី "មន្ត្រីសន្តិសុខដែលស្ថិតនៅក្នុងគុកចាស់ គឺបានន័យថា យៀត ជាប់នៅក្នុងមន្ទីរសន្តិសុខគុកចាស់"។ នៅម៉ោងដដែលនោះគឺ មាស រឿន បានឆ្លើយថា "គឺមានអ្នកជាប់ឃុំ ៧០០នាក់"។

[១៤:២៧:៥៣]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់លោកសហព្រះរាជអាជ្ញាជួយបញ្ជាក់ម៉ោងចុងក្រោយនេះឡើងវិញ។

**លោក ឃីត រេយ៍ន័រ៖**

ម៉ោងនៅក្នុងប្រតិចារឹកគឺ ១៤:២១:១០ ក្នុងប្រតិចារឹក មាស វឿន បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្តី "តាសឿង បានធ្វើការស៊ើបអង្កេត ហើយក្រោយមកគាត់បានដឹងថា គាត់គឺ យៀត ហ៊្វឹង ចាប់ឃុំមែន។ តាសឿង ហើយបន្ទាប់គឺគេបានបញ្ជូនខ្ញុំទៅខេត្តព្រះវិហារ។ សំណួរ៖ តើលោកខ្លួនឯងទៅមន្ទីរសន្តិសុខនោះ សន្តិសុខនៅខេត្តសៀមរាបដោយខ្លួនឯង ឬយ៉ាងម៉េច ដើម្បីទៅជួយដោះលែងសាច់ថ្លៃរបស់ ខៀវ សំផន ឬក៏យ៉ាងណា? ឆ្លើយ៖ ខ្ញុំទៅដោយផ្ទាល់ ខ្ញុំទៅជាមួយនឹង តាសឿង"។

[១៤:២៨:៥២]

នៅម៉ោង ១៤:២៣:២២ ក្នុងប្រតិចារឹក មាស វឿន បានបញ្ជាក់ថា "គាត់បានបញ្ជូនសារទូរលេខមួយច្បាប់ទៅកាន់ ខៀវ សំផន ដើម្បីរាយការណ៍អំពីបញ្ហានេះ"។ នៅម៉ោង ១៤:២៦:៣០ មាស វឿន ត្រូវបានសួរថា "តើលោកដឹងថាតួនាទីរបស់ ខៀវ សំផន នៅពេលនោះមានតួនាទីអ្វីដែរ? ឆ្លើយ៖ តាមដែលខ្ញុំដឹងតំបន់១០៣ គឺស្ថិតនៅក្រោមការត្រួតត្រារបស់លោក ខៀវ សំផន។ តាមគេប្រាប់ខ្ញុំ នៅពេលនោះតំបន់នោះគេហៅថាតំបន់ស្វយ័ត ហើយតំបន់ស្វយ័តនេះត្រូវរាយការណ៍ដោយផ្ទាល់ទៅកាន់លោក ខៀវ សំផន"។

មុនម៉ោង ១៤:៣១:២១ បន្តិចនៅក្នុងប្រតិចារឹក មាស វឿន ត្រូវបានសួរថា "ក៏ប៉ុន្តែនៅថ្ងៃដែរលោកទៅមន្ទីរសន្តិសុខនៅសៀមរាបនោះ អ្នកទោសម្នាក់ដែលលោកយកចេញពីមន្ទីរសន្តិសុខនោះ គឺជាប្អូនថ្លៃរបស់លោក ខៀវ សំផន ហើយអ្នកផ្សេងទៀតគឺនៅជាប់នៅក្នុងមន្ទីរសន្តិសុខនោះដដែល តើអ៊ីចឹងមែនដែរឬទេ?" ឆ្លើយ "ពិតជាត្រឹមត្រូវ វាពិតជាត្រឹមត្រូវ"។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី!

[១៤:៣០:៥៥]

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានស្តាប់ការអានយ៉ាងយកចិត្តទុកដាក់របស់សហព្រះរាជអាជ្ញា

ហើយខ្ញុំគិតផងដែរទៅដល់ការតម្រូវរបស់អង្គជំនុំជម្រះ ដូច្នេះគាត់អានទៅដូចកាន់តែវែងទៅៗ។ អ៊ីចឹងខ្ញុំមិនដឹងថាគាត់ចង់បានអីទេនៅពេលនោះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមខ្ញុំស្តាប់ជាភាសាខ្មែរតាមរយៈការបកប្រែឯកសារដែលលោកតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ថា ជាឯកសារ E1/130។ បាទ ក៏ប៉ុន្តែនៅពេលដែលខ្ញុំពិនិត្យជាក់ស្តែងគឺខ្ញុំរកលេខ E1/130 នោះវាអត់ឃើញ ហើយឃើញឯកសារ E1/132.1។ អានេះជាឯកសារដែលលោកតំណាងសហព្រះរាជអាជ្ញាបានលើក។ អ៊ីចឹងវាអាចធ្វើឲ្យខ្ញុំខាតពេលអស់មួយសន្ទុះដែរដើម្បីរកឃើញនោះ។ បាទ សូមអរគុណ។

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់តែម្តងសម្រាប់លោកមេធាវីការពារក្តី។ ឯកសារនេះគឺឯកសារមានលេខ E1/130.1 គឺ E1/130.1 ដើម្បីឲ្យមេធាវីការពារក្តីខាងជាតិនោះយល់ច្បាស់។ សូមឲ្យខាងមេធាវីការពារក្តីអន្តរជាតិខាងលោក ខៀវ សំផន មានការអធ្យាស្រ័យ កុំកាត់អ្វីដែលខ្ញុំសួរ ជាពិសេសការដែលលើកឡើងថា អ្វីដែលខ្ញុំធ្វើឡើងនេះជាការសន្និដ្ឋានបិទការដេញដោល។ សូមអធ្យាស្រ័យគឺមិនមែនដូច្នេះទេ។ ខ្ញុំសូមបន្តទៅមុខទៀត។

[១៤:៣២:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ ខ្ញុំបានអានការដកស្រង់សម្តីអម្បាញ់មិញចេញពីការផ្តល់សក្ខីកម្មរបស់លោកសាក្សី មាស វឿន។ តើលោកស្រីបានដឹងដែរឬទេ មិនថាច្រើន ឬក៏តិចនោះទេអំពីបញ្ហាហ្នឹង។ គឺបញ្ហាដែលលោក មាស វឿន នេះទៅដោះលែង ជួយដោះលែងបងស្រីរបស់លោកស្រី?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស រឿងទាំងអស់នេះ ខ្ញុំអត់បានដឹងទាំងអស់ សូម្បីតែបន្តិចក៏អត់ដឹងដែរ។ ហើយការដោះលែង ដូចលោកសាក្សីលោក មាស វឿន នេះក៏ខ្ញុំអត់ដឹងទេ។ ហើយលោកបានអានជាចម្លើយរបស់សាក្សី មាស វឿន ទាំងអស់នេះ ហើយខ្ញុំសូមបញ្ជាក់ គឺថាខ្ញុំអត់ដឹងទាំងអស់។ ហើយប្តី មកប្តីខ្ញុំអីក៏

ខ្ញុំអត់ដឹង ទាំងអស់នេះគឺខ្ញុំអត់ដឹងតែម្តង សូម្បីតែបន្តិចក៏មិនដឹងដែរ។ ហើយប្តីខ្ញុំទទួលខុសដូចតំបន់ ១០៣ ក៏អត់ដឹងទាំងអស់ៗតែម្តង អត់មានទេ មិនដែលឮទៀត អត់ដែលឮ។

**ស៖** ប្តីរបស់លោកស្រីបានជម្រាបជូនទៅក្រុមស៊ើបអង្កេតនៅក្នុងរឿងក្តីនេះថា គឺពីឆ្នាំ៧០ ដល់ ៧៥ គឺគាត់បានស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងនាម ជាមួយនឹងមេដឹកនាំ។ ឯកសារនេះគឺមានឯកសារ E3/27, អង់គ្លេស 00156745, ខ្មែរ ERN 00156615, បារាំងមានលេខ ERN 00156668។ ឯកសារ E3/27 ចាប់តាំងពីពេលដែលលោកស្រីស្គាល់គាត់ រហូតមកដល់ឆ្នាំ៧៥នោះ តើលោក ខៀវ សំផន ហ្នឹង ជាអចិន្ត្រៃយ៍ជាមួយនឹងមេដឹកនាំផ្សេងទៀតដែរ?

[១៤:៣៥:៥៥]

**ឆ៖** ចាស ពេលហ្នឹង ខ្ញុំជួបគាត់គឺនៅកន្លែងជាប់ជាមួយនឹងមេដឹកនាំ។

**ស៖** ចាប់ពីពេលដែលលោកស្រីជួបគាត់ រហូតមកដល់ឆ្នាំ១៩៧៥ តើស្វាមីរបស់លោកស្រី និយាយត្រូវទេនៅពេលដែលគាត់និយាយថា “គាត់នៅជានិច្ចកាលជាមួយមេដឹកនាំកាលនោះ” តាមការ លោកស្រីដឹង ហើយនិងការសង្កេតរបស់លោកស្រី តើសម្តីរបស់គាត់នោះពិតឬទេ?

**ឆ៖** ចាស ពេលហ្នឹង នៅសង្គ្រាមគឺឃើញនៅជិតៗគ្នាជាប់រហូតដល់ដែរ។

**ស៖** នៅឆ្នាំ១៩៧២ រហូតមកដល់ដែលពេលរៀបការនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧២។ តើលោក ស្រីបានស្នាក់នៅត្រពាំងធំដែរឬទេ?

**ឆ៖** អត់ដែរឮផង ត្រពាំងធំ។ អត់ដែលនៅផង។

**ស៖** បាទ ត្រពាំងទឹមៗ ដែលលោកស្រីនិយាយពីម្សិលមិញ ប្រហែលជាខ្ញុំអានមិនសូវត្រូវជា ភាសាអង់គ្លេស។

**ឆ៖** ត្រពាំងទឹម។ ត្រពាំងទឹម ខ្ញុំមកនៅប្រហែលជាប្អូនដប់ថ្ងៃ ពេលដែលខ្ញុំចេញពីភូមិ ពីភូមិ ទៅ អត់ទាន់ចូលទៅកន្លែងអ្នកដឹកនាំទេ។

[១៤:៣៨:៣០]

**ស៖** នៅពេលដែលលោកស្រីទៅនៅទីតាំងដែលមេដឹកនាំគេស្នាក់នៅ ហើយបានយកចំណី អាហារទៅជូន ប៉ុល ពត, នួន ជា ហើយនិងបងហែម។ តើលោកស្រីនៅក្នុងតំបន់ -- នៅក្នុងទីកន្លែង ជាមួយពួកគាត់រហូតដល់លោកស្រីរៀបការនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧២ ដែរឬទេ?

**ឆ៖** ខ្ញុំនៅកន្លែងហ្នឹង។

**ស៖** តើលោកស្រីធ្លាប់ឮទេ ថាប៉ុល ពត បានណែនាំលោក ខៀវ សំផន ថាឲ្យគាត់គួរតែរៀបការ តែលោកស្រីធ្លាប់ឮអ៊ីចឹងទេ?

**ផ៖** យើងខ្ញុំមិនដែលធ្លាប់ឮទេ។

**ស៖** តើប៉ុល ពត, នួន ជា, អៀង សារី, សុន សេន, វន វ៉េត តើអ្នកណាម្នាក់ក្នុងចំនួននេះ ក្នុងអ្នកទាំងនេះ បានចូលរួមក្នុងពិធីរៀបការរបស់លោកស្រីទេ?

[១៤:៣៩:៤៨]

**ផ៖** អ្នករៀបការមាន ប៉ុល ពត, នួន ជា និងប្រពន្ធរបស់អ៊ំ យ៉ឹម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

រដ្ឋមន្ត្រីបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបី រួមទាំងមេធាវីប្រឹក្សាសាក្សីផង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ បាទ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន សូមថ្លែងអំណរគុណលោកប្រធានច្រើន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក សូ សុជាតិ តើលោក ប៉ុល ពត នោះគឺជាអ្នកដែលរៀបចំពិធីធ្វើជាមេបាឲ្យ -- (សូមកែតម្រូវ) តើលោក ប៉ុល ពត នៅពេលនោះធ្វើជាអ្នកកំដរនៅពេលពិធីការនោះដែរឬទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស មិនមែនទេ។ ពេលនោះ គឺមានអ្នកនៅក្នុងមន្ទីរ គឺធ្វើពិធីការ គាត់គ្រាន់តែចូលរួម។

**ស៖** ក្រោយប៉ុន្មានឆ្នាំពេលដែលលោកស្រីរៀបការ គឺក្នុងឆ្នាំ៧៣ តើលោកស្រីបានជួបជាមួយនឹងលោកខៀវ សំផន ជារៀងរាល់ថ្ងៃដែរឬទេ?

**ឆ៖** ចាស ជួបរៀងរាល់ថ្ងៃ។

**ស៖** កាលពីម្សិលមិញលោកស្រីបានឆ្លើយថា មានកិច្ចប្រជុំដែលមានអ្នកមូលដ្ឋានមកចូលរួមផងដែរ ហើយលោកស្រីក៏បានឆ្លើយផងដែរ។ ខ្ញុំសូមដកស្រង់សម្ដីលោកស្រី "កិច្ចប្រជុំទាំងនោះបានធ្វើឡើង ក៏ប៉ុន្តែលោកខៀវ សំផន នៅផ្ទះទេ អត់មកចូលរួមឡើយ។ តើលោកស្រីកំពុងតែប្រាប់តុលាការថា នៅក្នុងឆ្នាំ១៩៧៣ ពេញ១ឆ្នាំនោះ ខៀវ សំផន មិនដែលធ្លាប់មកចូលរួមប្រជុំជាមួយនឹងអ្នកមូលដ្ឋានទេ តើអ៊ីចឹងដែរឬទេ?

**ឆ៖** តាមខ្ញុំរស់នៅជាមួយគាត់មិនសូវដែលបានទៅចូលរួមទេ។

**ស៖** ដូច្នេះបានន័យថាគាត់ទៅចូលរួមខ្លះដែរ តើមែនដែរឬទេ?

[១៥:០៥:២៤]

**ឆ៖** ខ្ញុំមិនចាំច្បាស់ពេលនោះ។ មិនដឹងជាមានពេលខ្លះចូលឬមួយយ៉ាងម៉េច? ខ្ញុំមិនចាំច្បាស់ទេ ព្រោះអីក៏វាច្រើនឆ្នាំមកហើយ។ ជារួមគឺឃើញតែគាត់នៅផ្ទះដែរ។

**ស៖** តើលោកស្រីដែលធ្លាប់បានដឹងដែរឬទេថា នៅក្នុងរយៈពេល៦ឆ្នាំដែលប្ដីលោកស្រីត្រូវបានឃុំខ្លួននៅទីនេះ កិច្ចប្រជុំអចិន្ត្រៃយ៍នៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ កិច្ចប្រជុំរបស់មជ្ឈិមនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ គឺជាកិច្ចប្រជុំមួយដែលសំខាន់។ ជាពិសេសកិច្ចប្រជុំនៅមាយ។--

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធានខ្ញុំយល់ខ្ញុំគិតថាពាក្យនេះគឺថាមានពាក្យមួយមិនបានបកប្រែដូច្នេះខ្ញុំសូមសួរសំណួរ

ឡើងវិញ។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ នៅក្នុងរយៈពេល៦ឆ្នាំក្នុងពេលដែលប្ដីរបស់លោកស្រីត្រូវបានឃុំខ្លួននៅទីនេះ តើលោកស្រីធ្លាប់បានដឹងដែរឬទេថា មានកិច្ចប្រជុំមួយនៅមាយបានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ ហើយបញ្ហាកិច្ចប្រជុំនេះគឺជាបញ្ហាមួយសំខាន់ណាស់នៅក្នុងរឿងក្ដីហ្នឹង។ តើលោកស្រីបានដឹងទេ?

**ឆ៖** សូមទោស ខ្ញុំអត់ដឹងទេ។

[១៥:០៨:១៤]

**ស៖** កាលពីម្សិលមិញ នៅម៉ោង ១៤:២០:១៤ នាទី ក្នុងប្រតិចារឹក មេធាវីការពារក្ដីអន្តរជាតិ លោក ខៀវ សំផន បានសួរសំណួរទៅកាន់លោកស្រីអំពីពេលវេលាដែលលោកស្រីបានសម្រាលកូនដំបូងរបស់លោកស្រី។ លោកស្រីបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្ដីរបស់លោកស្រី “ក្រោយពីវិលត្រឡប់មកពីប្រទេសចិនវិញ គាត់ (គាត់នេះសំដៅទៅលើខៀវ សំផន) បានចំណាយពេលប្រហែលជា១ខែ នៅជិតកៀកហ្នឹងខ្ញុំផងដែរដើម្បីជួយមើលថែទាំកូនដំបូងរបស់យើងឲ្យបានល្អ។ គាត់ស្នាក់នៅជាមួយយើងរួមជាមួយគ្នាក្នុងពេលនោះ។ នៅពេលឈប់សម្រាកពេលថ្ងៃរសៀល--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ លោកសហតំណាងសហព្រះរាជអាជ្ញាមានជំទាស់ពីមេធាវីការពារក្ដី។

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

លោកប្រធានខ្ញុំសូមជំទាស់នឹងចំណុចនេះ ពីព្រោះថាវាជាការដកស្រង់នូវសម្ដីរបស់សាក្សីខុស។ នៅពេលនោះគឺសាក្សីបានឆ្លើយបញ្ជាក់អំពីរយៈពេលមួយខែនេះគឺរយៈពេលដែលកូនមានអាយុ១ខែ មិនមែនរយៈពេល១ខែ ដែលលោក ខៀវ សំផន ទៅនៅធ្វើការជាមួយអ្នកស្រីជាប្រពន្ធរបស់គាត់នោះទេបាទ។ សូមអរគុណ។

[១៥:១០:២០]

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំដកស្រង់ចេញពីពាក្យពេចន៍ដើមដែលបានប្រើប្រាស់កាលពីព្រឹកមិញ -- ដែលបានផលិតឡើង

រៀបចំឡើងកាលពីព្រឹកមិញតែប៉ុណ្ណោះ។ នេះគឺជាពាក្យសម្ដីដើម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**លោក អាកឡូរ វែកគែន៖**

ដើម្បីបំភ្លឺបញ្ហានេះ ខ្ញុំសូមបញ្ជាក់ថា គាត់យោងទៅលើអ្វីដែលនិយាយជាភាសាខ្មែរ មិនមែនអ្វីដែលគេបកប្រែនោះទេ។ នេះគឺជាអ្វីដែលត្រូវធ្វើនោះ គួរតែយោងទៅជាភាសាខ្មែរ ព្រោះថាអាចមានបញ្ហាការបកប្រែ។ ព្រោះថា គឺថាតើលោកស្រីគាត់បាននិយាយអ្វីខ្លះជាភាសាខ្មែរមុនពេលឈប់សម្រាកនេះ គឺជាអ្វីដែលគួរតែសួរ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានជាទីគោរព យើងខ្ញុំមិនប្រតិចារឹកជាភាសាខ្មែរនោះទេ។ ដូច្នេះខ្ញុំសូមធ្វើការប្រឹក្សាយោបល់ជាមួយនឹងសហការីរបស់ខ្ញុំសិន។

*(សហព្រះរាជអាជ្ញាពិភាក្សាគ្នា)*

[១៥:១២:០៤]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានសហសេវិករបស់ខ្ញុំ – ឆវ័ន្ត គឺមានប្រតិចារឹកជាភាសាខ្មែរ។ ដូច្នេះ ខ្ញុំស្នើសុំអ៊ីចេះថាឲ្យគាត់អានជាភាសាខ្មែរទៅ គឺចំណុចដែលដកស្រង់ចេញអំពីប្រតិចារឹកជាភាសាខ្មែរ ហើយឲ្យបកប្រែផ្ទាល់តែម្ដងទៅ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញបាទ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណ។ ខ្ញុំនឹងយោងទៅលេខឯកសារ ដដែល ហើយសូមដកស្រង់ “ហើយសម្រាលហើយក៏មិនមានអ្នកណាជួយ គឺធ្វើឲ្យខ្លួនឯងទាំងអស់ ក្រោយមកបានគាត់ដូចត្រឡប់មកពីស្រុកចិនវិញគាត់នៅជួយកូនខ្ញុំបានប្រហែលជិត១ខែ ហើយគាត់--” សូមបញ្ចប់ការដកស្រង់។

[១៥:១៣:០៧]

**សួរដោយលោក ឃើត វេយ៉ន័រ៖**

លោកស្រី សូ សុជាតិ នៅពេលនេះគឺថា យើងស្តាប់ច្បាស់លាស់ហើយ យើងបញ្ជាក់ទាំងអស់គ្នាហើយ អ្វីដែលលោកស្រីបានលើកឡើងមុនពេលសម្រាក។ នៅពេលនេះ ខ្ញុំសូមឲ្យសហការី សហសេវិករបស់ខ្ញុំអានជាភាសាខ្មែរ គឺត្រង់ម៉ោង ១៥:១៤:៥០។ សូមឲ្យខាងសហការី សហសេវិករបស់ខ្ញុំអានជាភាសាខ្មែរ។ ម៉ោង ១៥:១៤:៥០ --

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទ គ្រាន់តែសុំឲ្យពិនិត្យសាឡើងវិញ ហើយជាក់ស្តែងគឺថា ដោយសារយើងមានធ្វើជាខ្សែវីដេអូថតទៀត។ ដូច្នេះមិនមានអីជាចំណោទធំដុំទេនៅបញ្ហានេះ។ ក៏ប៉ុន្តែការអានចំពោះសំណេរនេះវាអាចជាចំណោទ។ ចំណោទយ៉ាងម៉េច? ឧទាហរណ៍ថា នៅពេលដែលអានថា “គាត់ -- ខ្ញុំសូមអានចំណុចដែលតំណាងសហព្រះរាជអាជ្ញាជាតិបានអានអម្បាញ់មិញនេះត្រង់ចំណុចថា “គាត់នៅជួយកូនខ្ញុំបានប្រហែលជិត១ខែ”” អ៊ីចឹងការអាននេះវាអាចធ្វើឲ្យមានបញ្ហាច្រឡំដែរ។ គឺនៅពេលដែលលោក ខៀវ សំផន មកជួយហ្នឹង គឺអ្នកស្រីជាសាក្សីចង់បញ្ជាក់ថា កូនគាត់បានជិត១ខែ។ ដូច្នេះវាអត់មានអីជាពិបាកយល់ទេ បាទ សូមអរគុណ។

[១៥:១៥:០២]

**លោក ឃើត វេយ៉ន័រ៖**

លោកប្រធានគួរតែធ្វើការព្រមានទៅកាន់មេធាវីការពារក្តីជាតិខាងលោក ខៀវ សំផន ទៅកុំឲ្យលើកឡើងអ្វីដែលគាត់គិតថាវាមានន័យដូច្នោះទៅ អ្វីដែលដេញដោលភស្តុតាងនេះ។ វាជាការរំលោភកាតព្វកិច្ចក្រមសីលធម៌វិជ្ជាជីវៈ។ អ្វីដែលគាត់ធ្វើឡើងគឺវាមិនបានគោរពតាមក្រមសីលធម៌នោះទេ។ ដូច្នេះសូមឲ្យអង្គជំនុំជម្រះធ្វើការព្រមានជាបន្ទាន់ទៅលើចំណុចនេះ។ វាជាចំណុចមួយគួរឲ្យមានលក្ខណៈខឹងសម្បាណាស់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

[១៥:១៥:៤៥]

**លោក គង់ សំអុន៖**

ខ្ញុំសូមឆ្លើយតបចំពោះចំណុចនេះ។ ខ្ញុំគិតថាវាមិនមែនដែលតំណាងសហព្រះរាជអាជ្ញាត្រូវលើកអំពីការត្រូវព្រមាន ឬថាខ្ញុំត្រូវរំលោភនូវវិជ្ជាជីវៈនោះទេ។ បញ្ហានៅត្រង់នេះ គឺយើងនិយាយអំពីការអានហើយអម្បាញ់មិញនេះ តំណាងសហព្រះរាជអាជ្ញាជាតិក៏បានអានទៅលើចំណុចនេះដែរ។ ដូច្នេះ ការអានវាអាចជាបញ្ហា។ អ៊ីចឹងបានខ្ញុំលើកជម្រាបជូនអង្គជំនុំជម្រះអំពីបញ្ហាអាននេះ ហើយដែលខ្ញុំបានបញ្ជាក់ហើយថា នៅក្នុងខ្សែវីដេអូមានថតទៅហើយ ដូច្នេះវាមិនមានអីជាចំណោទទេ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តទៀត!

**លោក ឃីត វេយ៍ន័រ៖**

តំណាងសហព្រះរាជអាជ្ញាជាតិ គឺគាត់នឹងអានការដកស្រង់ជាភាសាខ្មែរចេញពីប្រតិចារឹកជាភាសាខ្មែរ គឺក្រោយម៉ោង ១៥:១៤:៥០ បន្តិច គឺអានចំណុចហ្នឹង។

[១៥:១៧:០១]

**កញ្ញា សុង ឆវ័ន្ត៖**

សូមដកស្រង់សួរឆ្លើយ ដកស្រង់ "តាំងពីគាត់មកពីចិនមក គាត់មកនៅជាមួយខ្ញុំរហូតមិនដឹងជាប៉ុន្មានខែទេ។ ប្រហែលជាបីបួនខែ ឬក៏ប៉ុន្មានទេ ព្រោះអីជិតរហូតទៅដល់មន្ទីរ១៧ នៅប្រហែល៣ខែនៅមន្ទីរ១៧ បានចេញពីហ្នឹងទៅប-២០។ នៅប-២០ នៅជាមួយគ្នាដែរ ដល់ចេញពីប-២០ បានទៅមាឃ"។ សូមបញ្ចប់ការដកស្រង់។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ ហេតុអ្វីបានជាមុនពេលឈប់សម្រាកនោះ លោកស្រីលើកថាតែ១ខែទេ ក៏ប៉ុន្តែក្រោយពេលឈប់សម្រាកនោះ លោកស្រីបែជាឆ្លើយថាពីរបីខែទៅវិញ។ ដូច្នេះនេះគឺជាការកែទៅលើចម្លើយដែលលោកស្រីមុនដំបូងឆ្លើយថាខុសនោះ ហើយក្រោយមកកែវាត្រឹមត្រូវវិញ ឬមួយក៏យ៉ាងម៉េចដែរ?

[១៥:១៨:២០]

**លោកស្រី សូ សុជាតិ៖**

**ឆ៖** សូមបញ្ជាក់សាជាថ្មី។ ខ្ញុំបាននិយាយដូចជាខ្ញុំចាំច្បាស់ គឺប្តីខ្ញុំត្រឡប់មកពីចិន ហើយនេះ

ខ្ញុំអត់មានកែពាក្យទេ។ ខ្ញុំខំស្ដាប់ ខ្ញុំខំនិយាយ ហើយតាមការនៅជាប់ជាមួយគ្នា។ ដូច្នេះខ្ញុំសូមបញ្ជាក់ជូនលោកប្រធាន លោកតុលាការ គឺប្ដីខ្ញុំមកពីចិន គឺកូនខ្ញុំទើបតែបានជិត១ខែ ហើយគាត់មកជួយខ្ញុំរហូតមកដល់ប្រហែលជា៣ខែនៅ១៧ ហើយនៅប-១៧ រួចទៅប-២០ នៅជាមួយគ្នា រួចទៅមាយនៅជាមួយគ្នារហូតជិតរំដោះភ្នំពេញ ទើបគាត់ចេញ។ ខ្ញុំដូចចាំមាត់ខ្ញុំច្បាស់។ តើអស់លោកមានឮ ឬមួយក៏យ៉ាងម៉េចដែលខ្ញុំនិយាយក្រឡេចក្រឡុច។ អាហ្នឹងសូមត្តាត្រួតពិនិត្យឡើងវិញទៅ។ ព្រោះខ្ញុំៗចាំច្បាស់ខ្លួនខ្ញុំណាស់។

**ស៖** តើយើងយល់ស្របគ្នាដែរឬទេត្រង់ចំណុចនេះថា លោកស្រីមិនបានឃើញ ជួបប្ដីរបស់លោកស្រីពេលដែលលោកស្រីសម្រាលកូនភ្លាមនោះ គឺមិនបានជួបរហូតដល់១ខែក្រោយ គឺក្នុងខែមិថុនាឆ្នាំ៧៤ ទើបបានជួបគ្នា។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** សូមអនុញ្ញាតលោកប្រធាន សំណួរដែលនេះខ្ញុំអត់សូវស្ដាប់បានទេ ពីព្រោះលើកពីត្រង់នេះបន្តិចត្រង់នោះបន្តិច ហើយមកបញ្ចូលគ្នាខ្ញុំពិបាកស្ដាប់ណាស់។ បើគាត់ចង់ថាសួរអី សួរគាត់អាហ្នឹងប៉ុន្នានហើយចាំឆ្លើយតបទៀត។ ចាស សូមអនុញ្ញាត។

[១៥:២០:៣០]

**ប្រធានអង្គជំនុំ៖**

សូមលោកតំណាងសហព្រះរាជអាជ្ញាយល់ហើយ សូមសម្រួលនូវសំណួររបស់លោកដើម្បីឱ្យគោលដៅដែលនឹងឆ្លើយនឹងសំណួររបស់លោកហ្នឹង គឺអាចយល់។ យើងបានជម្រាបជូនភាគីពាក់ព័ន្ធនៃរឿងនេះតាំងពីដើមដំបូងក្នុងការតាំងសំណួរដេញដោលចំពោះប្រជាពលរដ្ឋទាំងឡាយដែលនឹងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ គួរតែសួរសម្រួលនូវសំណួរអង្កន់ខ្លីៗ ដើម្បីឱ្យសមត្ថភាពនិងលទ្ធភាពរបស់គោលដៅដែលស្ដាប់នូវសំណួររបស់លោក គាត់ស្ដាប់យល់ ហើយគាត់អាចឆ្លើយតបនឹងសំណួរបាន។ ចៀសវាងសួរសំណួរស៊ីជម្រៅ ឬសំណួរវែងដែលនាំឱ្យគោលដៅដែលត្រូវឆ្លើយហ្នឹងពិបាកស្ដាប់សំណួរមិនយល់ មិនអាចឆ្លើយបានល្អទេ។

សូមរំឭកឡើងវិញ យើងបានជម្រាបតាំងពីដំបូងនៃកិច្ចដំណើរការសវនាការនៃសំណុំរឿង០០២នេះមកម្ល៉េះ ទំនងជាអាចភ្លេច។

[១៥:២១:២៦]

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ តើវាត្រឹមត្រូវដែរឬទេ ដែលលោកលើកដំបូងដែលលោកស្រីបានជួបប្ដីរបស់លោកស្រីនោះ គឺក្រោយពេលលោកស្រីបានសម្រាលកូនហើយ បានន័យថាក្រោយពីលោកស្រីបានសម្រាលកូនរួច១ខែ ទើបស្រីបានជួបប្ដីរបស់លោកស្រីនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤។ តើត្រឹមត្រូវដែរឬទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ចាស ត្រឹមត្រូវ។

[១៥:២២:១១]

**ស៖** នៅពេលនោះគឺគាត់ធ្វើទស្សនកិច្ចទៅតាមប្រទេសជាច្រើន ហើយបន្ទាប់មកនៅថ្ងៃគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃ១៣ ខែមិថុនា ឆ្នាំ១៩៧៤ តើលោកស្រីមានបានធ្វើដំណើរទៅព្រលានយន្តហោះទៅទទួលគាត់ដែរឬទេនៅថ្ងៃនោះ?

**ឆ៖** គ្មានទេ។

**ស៖** តើលោកស្រីអាចជម្រាបបានដែរឬទេ តើប្ដីរបស់លោកស្រីគាត់នៅទីណាដែរនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤? តើគាត់នៅកន្លែងណាខ្លះដែរ?

**ឆ៖** ឃើញពេលត្រឡប់មកវិញមកជួបខ្ញុំ ហើយនៅនឹងក-១៧ហ្នឹងរហូត គាត់អត់មានចេញទៅណាទៀតទេ រហូតដល់ចេញទៅប-២០ ភូមិមាឃ ហើយចេញមកមុនខ្ញុំកន្លះខែទៅភ្នំពេញ។ អ្ហេ! មិនដឹងទៅភ្នំពេញ ឬមួយក៏ទៅណាទេមុនកន្លះខែ ឬប្រហែលប៉ុណ្ណឹង។

[១៥:២៣:៤៣]

**ស៖** លោកស្រី សូ សុជាតិ លោកស្រីមិនអាចជម្រាបជូនតុលាការបាននោះទេថា លោកស្រីមិនដឹងប្ដីរបស់លោកស្រីធ្វើដំណើរទៅណាខ្លះទេ ជារៀងរាល់ថ្ងៃនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ចាស អ៊ីចឹងមែន ប៉ុន្តែគាត់អត់ឃើញទៅណា នៅជាមួយខ្ញុំ។

**ស៖** ខ្ញុំសូមសួរពេលវេលាក្រោយពេលជម្លៀស។ ប្ដីរបស់លោកបានជម្រាបជូនសហចៅក្រម

ស៊ើបអង្កេតនៅក្នុងឯកសារ E3/27។ ERN ជាភាសាអង់គ្លេសគឺ 00156745, ខ្មែរ ERN គឺ 00156615, បារាំង ERN គឺ00156668។ គេបាននាំគាត់ទៅស្ថានីយរថភ្លើងជួបជាមួយនឹង ប៉ុល ពត មួយខែមុនពេលចូលទៅជួបជុំគ្នានៅវត្ត នៅវិហារព្រះកែវមរកត។ តាមភស្តុតាង ម្លើយដែលលោកស្រីឆ្លើយកាលពីម្សិលមិញ មួយសប្តាហ៍ក្រោយភ្នំពេញបានរំដោះ លោកស្រីបានចាកចេញពីមន្ទីរក-១៧ ទៅស្តុកគោលនៅពេលយប់ ហើយបានជួបជាមួយនឹង ខៀវ សំផន នៅទីនោះមួយយប់។ ក្រោយមកបានចាកចេញទុកកូននៅជាមួយ សួរ ហុង។ លោកស្រីបានទុកកូននៅជាមួយប្រពន្ធ សួរ ហុង ហើយបន្ទាប់មកលោកស្រីធ្វើដំណើរទៅកន្លែងស្ថានីយរថភ្លើង។ តើស្ថានីយរថៅភ្លើងនោះទៅធ្វើអីដែរ? លោកស្រីទៅដាំស្ល ឬក៏ទៅធ្វើអីដែរ?

**ឆ៖** ចាស ខ្ញុំដាំស្ល។

**ស៖** យើងឃើញថាមានកន្លែងស្ថានីយរថភ្លើងហ្នឹងធំណាស់តាមផ្លូវមុនីវង្ស តាមមហាវិថីមុនីវង្សនៅក្នុងក្រុងភ្នំពេញ។ បច្ចុប្បន្ននេះគឺថា ថ្នាំខាងក្រៅនេះមានពណ៌រាងបៃតង ហើយមើលទៅស្អាតចាប់អារម្មណ៍។ តើស្ថានីយរថភ្លើងនេះហើយគឺជាស្ថានីយរថភ្លើងដែលលោកស្រីធ្លាប់ទៅកាលពីឆ្នាំនោះតើមែនទេ?

[១៥:២៦:២៣]

**ឆ៖** ស្ថានីយរថភ្លើងមានតែមួយ។ ខ្ញុំអត់ៗនេះដែរមានតែមួយ ឬមួយក៏យ៉ាងម៉េច ខ្ញុំអត់ស្គាល់កន្លែងហ្នឹង។ គឺមានតែកន្លែងហ្នឹងមួយទេដែលមាន កន្លែងហ្នឹងធំ។

**ស៖** កាលពីម្សិលមិញលោកស្រីបាននិយាយថាលោកស្រីនៅស្ថានីយរថភ្លើង ឬរ៉ាវទេះភ្លើងនោះគឺមួយសប្តាហ៍នៅទីនោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ចាស។

**ស៖** ក៏ប៉ុន្តែប្រសិនបើប្តីរបស់លោកស្រីនៅទីនោះ១ខែ ហើយលោកស្រីនៅតែមួយអាទិត្យ អ៊ីចឹងបានន័យថាលោកស្រីមិនដែលជួបជាមួយប្តីលោកស្រីសោះតែម្តងនៅទីនោះ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលជួប។

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរទៅជួបប្តីរបស់លោកស្រីនៅស្តុកគោល ហើយស្នាក់នៅមួយយប់នៅជាមួយនឹងគាត់នៅទីនោះ។ តើប្តីរបស់លោកស្រីមានបានប្រាប់លោកស្រីថា គាត់បានជួបនិយាយជាមួយនឹង ប៉ុល ពត អំពីការជម្លៀសប្រជាជនប្រជាជនទីក្រុងភ្នំពេញដែរឬទេ? ហើយប្តីលោក

ស្រីដែលបង្ហាញប្រាប់លោកស្រីថា គាត់ហ្នឹងមិនឯកភាពជាមួយនឹង ប៉ុល ពត នោះទេ។ តើលោកស្រីបានដឹងទេបញ្ហាហ្នឹង?

[១៥:២៨:៣៥]

**ផ៖** ពេលនោះខ្ញុំអត់បានដឹងទេ។

**ស៖** ចាប់តាំងពីលោកស្រីរៀបការថ្ងៃ២៥ ខែធ្នូ ឆ្នាំ១៩៧២ រហូតដល់ថ្ងៃវៀតណាមចូលនៅថ្ងៃ ០៦ ឬ ០៧ ខែមករា ឆ្នាំ១៩៧៩ តើប្ដីរបស់លោកស្រីធ្លាប់ប្រាប់លោកស្រីថា គាត់ធ្លាប់បានជំទាស់មិនយល់ព្រមជាមួយនឹង ប៉ុល ពត ដែរឬទេ?

**ផ៖** គាត់អត់ដែលនិយាយអីប្រាប់ខ្ញុំទេ។

**ស៖** តើលោកស្រីធ្លាប់ស្ដាប់សុន្ទរកថាប្ដីរបស់លោកស្រីថ្លែងឡើង អង់គ្លេស ERNគឺ0016994, បារាំងមានលេខ 00845855, ខ្មែរ 00846160, ឯកសារ E3/118១។ តើលោកស្រីធ្លាប់ស្ដាប់សុន្ទរកថាដែលថ្លែងឡើងដោយប្ដីរបស់លោកស្រី គាត់ថ្លែងនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៤ ដែលសុន្ទរកថានេះគឺថ្លែងឡើងតាមប្រព័ន្ធផ្សព្វផ្សាយនៅទីក្រុងភ្នំពេញដែលក្នុងនោះ គឺគាត់បានលើកឡើងអំពីជ័យជម្នះក្នុងការបណ្ដេញប្រជាជន បណ្ដេញខ្មាំង ហើយនិងថ្លែងអំពីខ្មាំងដែលស្លាប់នាពេលនោះ?

**ផ៖** ខ្ញុំមិនបានស្ដាប់សុន្ទរកថានេះទេ។

**ស៖** តើលោក ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើគាត់ធ្លាប់និយាយជជែកជាមួយនឹងលោកស្រីអំពីការបណ្ដេញប្រជាជនចេញដែរឬទេ? សូមកែតម្រូវ តើគាត់ធ្លាប់និយាយជាមួយលោកស្រីអំពីការពង្រឹងប្រជាជនចេញដែរឬទេ?

[១៥:៣២:៥០]

**ផ៖** គាត់ធ្លាប់បាននិយាយអំពីការជម្លៀសពង្រឹងហ្នឹងចេញដែរ ពីព្រោះវាមានពាក់ព័ន្ធនឹងបងប្អូនអីនៅឯណាៗអីចឹង។ ប៉ុន្តែគ្រាន់តែបានជានិយាយប៉ុណ្ណឹង ឯរឿងផ្សេងទៀតខ្ញុំក៏អត់មាននិយាយអីជាមួយខ្ញុំ។ មានតែនិយាយប៉ុណ្ណឹង។ មិនដឹងធ្វើម៉េច បងប្អូនខ្ញុំអីនៅឯណា ប្អូនខ្ញុំអីនៅឯណា អាហ្នឹងមាន។ ខ្ញុំសូមបញ្ជាក់អាហ្នឹងក្រោយមកហើយទេ ក្រោយមកចូលនៅក្នុងភ្នំពេញហើយ។

**ស៖** លោកស្រីបានឆ្លើយពីខាងដើម លើកដំបូងដែលលោកស្រីនិយាយជាមួយសាច់ញាតិរបស់លោក ខៀវ សំផន នោះគឺ១ឆ្នាំក្រោយពីជម្លៀស។ ដូច្នេះ ចម្លើយដែលលោកស្រីឆ្លើយពីខាងដើមហ្នឹងតើជាចម្លើយត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាចម្លើយត្រឹមត្រូវ។

**ស៖** ខ្ញុំចង់ចូលទៅដល់ប្រធានបទមួយទៀតពាក់ព័ន្ធនឹងមន្ទីរក-៣។ នៅក្នុងប្រតិចារឹកនៃខ្សែអាត់វីដេអូជាមួយនឹងប្តីលោកស្រី គឺឯកសារ D313.11.1។ ប្តីរបស់លោកស្រីបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្តីគាត់ "ប្រពន្ធរបស់ខ្ញុំតែងតែធ្វើការនៅរោងបាយរួម ធ្វើម្ហូប ដាំស្លជាមួយនឹងនារីៗពីរបីនាក់ទៀត។ ប្រពន្ធរបស់ខ្ញុំធ្វើការដាំស្លយ៉ាងទៀងទាត់ក្នុងវគ្គប្រជុំស្វ័យទិតៀន"។ សូមបញ្ចប់ការដកស្រង់សម្តី។ តើប្តីរបស់លោកស្រីឆ្លើយនោះ និយាយក្នុងហ្នឹងត្រឹមត្រូវដែរឬទេ នៅពេលដែលគាត់លើកឡើងចំណុចទាំងអស់ហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីការពារក្តី!

**លោក អាកទូរ វែកកែន៖**

លោកប្រធាន ខ្ញុំសូមឲ្យសហភាតារបស់ខ្ញុំ សួរថាឯកសារហ្នឹងនៅក្នុងបញ្ជីឯកសារព្រះរាជអាជ្ញាឬអត់? ខ្ញុំគិតថា នេះឯកសារនេះដូចមិនមានទេ គាត់មិនបានបញ្ជាក់ថាឯកសារវីដេអូហ្នឹងមាន លេខកូដណាហើយមកប្រភពពីខាងណាទេ? អ៊ីចឹងសូមឲ្យគាត់បញ្ជាក់ត្រង់ចំណុចនេះបន្តិចដើម្បីឲ្យមានតម្លាភាព។ យើងចង់ដឹងថា តើជាឯកសារដែលមាននៅក្នុងបញ្ជីឯកសារដែលគាត់បានប្រាប់មុន ថាគាត់ចង់ប្រើប្រាស់ដែរឬទេ? លោកប្រធាន សូមបញ្ជាក់ត្រង់ចំណុចនេះ។

[១៥:៣៦:២៧]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ដើម្បីឆ្លើយទៅនឹងសំណួរនេះ ឯកសារដែលខ្ញុំយោងនេះគឺប្រតិចារឹកនៅក្នុងតុលាការនេះឯង។ ហើយខ្ញុំបានឲ្យលេខ D មិនទាន់បានដាក់ទៅ -- មិនមែនត្រូវដាក់នៅក្នុងអ៊ិនធីហ្វេសទេ។ បាទ ហើយមិនតម្រូវឲ្យដាក់បង្ហាញតាមបែបនោះទេ ហើយខ្ញុំចង់ឲ្យពិនិត្យមើលវិធាន៨០ ហើយខ្ញុំសូមអនុញ្ញាតពេលខ្លីបន្តិចបាទ។ បាទគឺតាមវិធាន៨០ នោះឯង តាមបញ្ជីដោយគិតថា យើងខ្ញុំស្នើថាគឺតាមវិធាន៨០ គឺថាបញ្ជីហ្នឹងខ្ញុំរៀបរាប់តែឯកសារដែលបញ្ជាក់ថាជាប្រតិចារឹកថាមាននៅក្នុងសំណុំរឿង។ ដូច្នេះជាការសួរសំណួរដ៏ត្រឹមត្រូវទៅតាមនីតិវិធីហើយ សូមជម្រាបបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀតបាទ!

[១៥:៣៧:៣៦]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** តើលោក ខៀវ សំផន និយាយត្រឹមត្រូវទេ ក្នុងការរៀបរាប់អំពីសកម្មភាពរបស់លោកស្រី ការងាររបស់លោកស្រីនៅក-៣?

**ឆ៖** សូមទោសខ្ញុំអត់យល់អំពីលោកលើកថា នៅក្នុងផ្ទះបាយរួមហើយ នៅក្នុងការស្ដីប្រជុំស្វ័យទិតៀនអីម៉េច? ខ្ញុំអត់សូវយល់កន្លែងហ្នឹងមិនដឹងខ្ញុំចង់ឆ្លើយថាម៉េច។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរចុងក្រោយរបស់លោកម្ដងទៀត។

**លោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ ប្ដីរបស់លោកស្រីបានប្រាប់អ្នកកាសែតនូវពាក្យទាំងអស់នេះ។ ហើយខ្ញុំដកស្រង់ពាក្យគាត់ជូនលោកស្រីស្ដាប់ "ប្រពន្ធរបស់ខ្ញុំតែងតែនៅរោងបាយរួម ដាំស្ល ម្ហូបអាហារជាមួយនឹងនារីៗបីបួននាក់ទៀត។ គាត់តែងតែដាំស្លម្ហូបអាហារនៅពេលមានការប្រជុំដើម្បីធ្វើការទិតៀននៅពេលនោះ"។ សូមបញ្ចប់សេចក្ដីដកស្រង់។ សួរថាតើប្ដីរបស់លោកស្រីនិយាយត្រឹមត្រូវទេ នៅពេលដែលគាត់ប្រាប់ទៅអ្នកកាសែតដូចដែលខ្ញុំស្រង់សម្ដីគាត់អំមិញនេះ?

[១៥:៣៩:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះមានការជំទាស់។ សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ជារឿងដដែលទេ ហើយខ្ញុំសូមឲ្យតំណាងសហព្រះរាជអាជ្ញាបញ្ជាក់អំពីលេខទំព័រ ERN នៅក្នុងឯកសារនេះផងបាទ សូមអរគុណ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាននេះ គឺដូចជារុញទៅដល់ពេលមួយដែលថា គឺថាឲ្យយើងជាមេធាវីដែលមានការទទួលខុសត្រូវវិជ្ជាជីវៈ។

[១៥:៤០:០៩]

**ប្រធានអង្គជំនុំ៖**

សូមលោកអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះ ថាលោកពឹងផ្អែកឯកសារណា? ហើយទំព័រណា? ហើយនិងម៉ោងប៉ុន្មានបើសិនជាប្រតិចារឹក។ នេះយើងបានប្រាប់រួចហើយ មិនមែនជាកំហុសរបស់មេធាវីជំទាស់នោះទេ។ ជាកំហុសរបស់លោកដែលមិនស្តាប់ការណែនាំរបស់អង្គជំនុំជម្រះ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ពេលវេលាគឺ ០០:៣៨:៤៨។ លោកស្រី សូ សុជាតិ អ្វីដែលប្តីរបស់លោកស្រីប្រាប់អ្នកកាសែតនោះត្រូវដែរឬទេ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ខ្ញុំអត់យល់មិនដឹងគាត់ចង់និយាយថាម៉េច។ សូមទោស ឯការដាំបាយ តាម -- អាហ្នឹងខ្ញុំសូមលើកឡើងវិញ ដូចលោកព្រះរាជអាជ្ញាបានសួរ ការដាំបាយនៅក្នុងផ្ទះបាយជានេះជារួម ជាការត្រឹមត្រូវ។ ប៉ុន្តែនៅពេលគេធ្វើប្រជុំទិតៀន អាហ្នឹងខ្ញុំអត់យល់។ ខ្ញុំអត់យល់ដឹងគាត់ ដឹងគាត់ចង់និយាយថាម៉េច។ បើដាំបាយខ្ញុំដាំបាយមែន ប៉ុន្តែដល់ប្រជុំទិតៀន -- ប្រជុំទិតៀនហ្នឹងចង់ថាម៉េចខ្ញុំអត់យល់ៗអាត្រង់ហ្នឹង។

[១៥:៤២:០៨]

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀត។ នៅក្នុងឯកសារ E3/37, អង់គ្លេស ERN 00156755, បារាំង ERN 00156683 ហើយខ្មែរ ERN 00156676 រហូដល់ 77។

ប្តីរបស់លោកស្រី បានប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់បានរស់នៅក-៣ ជាមួយលោក នួន ជា, អៀង សារី ហើយនិង សុន សេន។ តើសម្តីគាត់នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បើតាមខ្ញុំនៅ គឺមិនត្រឹមត្រូវ។

**ស៖** បាទ សូមលោកស្រីបន្ត។

**ឆ៖** គឺហេតុអីបានខ្ញុំថាមិនត្រឹមត្រូវ? ព្រោះខ្ញុំទៅឃើញក្រៅពីនៅជាមួយគ្នា គឺមានទាំងអស់គ្នាតែដល់ពេលនេះ គេចេញទាំងអស់ ចេញអស់គ្នាអត់មាននៅជាមួយទេ នៅតែមួយរយៈខ្លីទេ។ អ៊ីចឹងបានខ្ញុំថាអត់ត្រឹមត្រូវ ថានៅពេលណាដែលនៅជាមួយគ្នា ជាមួយក-៣ហ្នឹង? ហ្នឹងខ្ញុំអត់ដឹងដែរ ដឹងនៅពេលណា? បើត្រឹមខ្ញុំនៅ គឺនៅទាំងអស់គ្នា, ទាំង ប៉ុល ពត, ទាំង នួន ជា, ទាំង អៀង សារី ទាំងប្រពន្ធទាំងសុន សេន ហើយដល់ពេលចេញ ចេញទាំងអស់គ្នា។

[១៥:៤៤:៣៩]

**ស៖** នៅក្នុងកំណត់ត្រាវីដេអូ ហើយនិងប្រតិចារឹកនៃវីដេអូ នោះគឺនៅ D3/ -- បាទ D313.11.1 បាទ នៅម៉ោង ០០:៣៨:៤៨។ ប្ដីរបស់លោកស្រីបាននិយាយអំពីពេលវេលារបស់គាត់នៅ ក-៣ ដូច ការងារដូចតទៅនេះ។ ខ្ញុំដកស្រង់សម្ដីរបស់គាត់, ERN អង់គ្លេសគឺ 00815884, បារាំង ERN 00826486, ហើយនិងខ្មែរ ERN 00807463។ នេះជាសម្ដីរបស់ប្ដីលោកស្រី "ចំពោះជីវិតប្រចាំថ្ងៃ ប៉ុល ពត និង នួន ជា បានហូបបាយជាមួយនឹងខ្ញុំ ហើយយើងហូបបាយជាមួយគ្នា។ យើងមិនធ្វើអ្វីដាច់ដោយឡែកពីគ្នាទេ"។ សូមបញ្ចប់សេចក្ដីដកស្រង់។

តើលោកស្រីយល់ស្របជាមួយប្ដីរបស់លោកស្រីទេ នៅពេលដែលគាត់នៅក-៣ គាត់មិនធ្វើអ្វីដាច់ដោយឡែកពី ប៉ុល ពត និង នួន ជា ទេ?

**ឆ៖** នៅកន្លែងហ្នឹង ពេលខ្ញុំឃើញតែពេលបាយគឺនៅជុំគ្នា។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំនឹងចូលទៅប្រធានបទថ្មីមួយទៀត។

[១៥:៤៦:៥៦]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ កាលពីដើមព្រឹកនេះ លោកស្រីបាននិយាយទៅដល់ គឺដោយបុរសម្នាក់ដែលលោកស្រីហៅឈ្មោះថា ឈ្មោះ ឡេង ជឿង។ ដែលថាគាត់ជាអ្នកបើកបរឡានឲ្យលោក ខៀវ សំផន។ ឯកសារពាក់ព័ន្ធនោះគឺថាបទសម្ភាសន៍របស់គាត់ទៅចៅក្រមស៊ើបអង្កេតនោះ គឺថា E3/385។ នៅសំណួរទី៦ គាត់បាននិយាយដូចខាងក្រោមនេះ ហើយខ្ញុំនឹងដកស្រង់៖

"នៅឆ្នាំ១៩៧៨ គេបានចាត់តាំងខ្ញុំឲ្យបើកឡានឲ្យលោក ខៀវ សំផន ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណាជាអ្នកចាត់តាំងខ្ញុំទេ។ នៅពេលដែលខ្ញុំបើកបរឡានឲ្យលោក ខៀវ សំផន នោះ ខ្ញុំរស់នៅមន្ទីរក-៣ នៅជិតផ្ទះរបស់លោក ខៀវ សំផន។ នៅពេលនោះ លោក នួន ជា ហើយនិង អៀង សារី ក៏រស់នៅ ក-៣ ទីនោះ -- នៅមន្ទីរក-៣នោះដែរ។ ផ្ទះរបស់ពួកគាត់នៅជិតៗគ្នា។ ប៉ុន្តែទល់ខ្នងគ្នា"។

សំណួរទី១របស់ខ្ញុំទៅលោកស្រីនោះគឺថា តើលោកស្រីយល់ស្របជាមួយនឹងសាក្សីនេះដែរទេ នៅពេលដែលគាត់និយាយថា គឺនៅឆ្នាំ១៩៧៨ ដែលៗគាត់ចាប់ផ្ដើមបើកឡានឲ្យលោក ខៀវ សំផន នោះ?

[១៥:៤៩:១០]

**ឆ៖** ខ្ញុំមិនចាំពិតប្រាកដដែរ បើកអាច។ យល់ស្រប។

**ស៖** នៅក្នុងប្រតិចារឹកនៃសក្ខីកម្មរបស់សាក្សីឈ្មោះ អឿន តាន គាត់ជាប្រធានសន្តិសុខនៅ ក-១។ យោងទៅប្រតិចារឹករបស់តុលាការនៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០១២ -- *អ៊ីណាំប៊ែរ* E1/86.1 នៅម៉ោង ១១:៥២:៤៤។ គាត់បាននិយាយថា “ក-៣ គឺជាកន្លែងស្នាក់នៅរបស់ នួន ជា ហើយនិង ខៀវ សំផន ហើយជាការងារ។ រីឯកន្លែងធ្វើការគឺនៅក-១។ នៅក-១ គឺជាកន្លែងធ្វើការងាររបស់មេដឹកនាំទាំងអស់ ចំពោះក-៣វិញម្នាក់ៗត្រូវតែមកចូលរួមប្រជុំនៅក-១”។ សំណួរទី១ ទៅកាន់លោកស្រី ថាតើលោកស្រីយល់ស្របជាមួយសម្តីរបស់ អឿន តាន ទេថាក-៣គឺជាកន្លែងស្នាក់នៅរបស់ នួន ជា ហើយនិង ខៀវ សំផន?

**ឆ៖** គឺ នួន ជា លោកអត់នៅហ្នឹងទេ លោកនៅក-១ មកម្តងៗមានមែន។

**ស៖** ខ្ញុំសូមឲ្យលោកស្រីបំភ្លឺចំណុចក្រោយ នៅពេលដែលឆ្លើយអំមិញ។ ហើយទៅតាមសម្តីរបស់ប្តីលោកស្រីវិញ គឺឯកសារ E3/37។ ខ្ញុំបានផ្តល់លេខERN រួចមកហើយ។ ប្តីរបស់លោកស្រីបានជម្រាបសហចៅក្រមស៊ើបអង្កេតថា គាត់បានរស់នៅក-៣ជាមួយលោក នួន ជា។ បាទ តើសម្តីរបស់លោកស្រីនិយាយអីចឹងខុស ឬក៏យ៉ាងម៉េចបាទ?

[១៥:៥២:១៥]

**ឆ៖** ខ្ញុំនៅនឹងកន្លែងជាប់ មិនឃើញគាត់នៅជាប់ មកម្តងៗមានមែន ប៉ុន្តែគាត់នៅជាមួយយ៉ាងម៉េចខ្ញុំមិនដឹងដែរ ហ្នឹងខ្ញុំសូមនិយាយស្មោះ។ គាត់នៅយ៉ាងម៉េចខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំនៅទីនោះដែលខ្ញុំដាំបាយឲ្យគាត់ គឺគាត់ម្តងៗ, លោក នួន ជា គាត់នៅហ្នឹងទេ។

**ស៖** ប្តីរបស់លោកស្រីបាននិយាយនៅក្នុងខ្លឹមសារមួយទៀត ដកស្រង់គឺថាបារាំង ERN 0015 6683, ខ្មែរ ERN 00156676 ដល់ 77 ហើយអង់គ្លេស ERN 00156755។ ប្តីរបស់លោកស្រីបាននិយាយដូចខាងក្រោមនេះ ខ្ញុំដកស្រង់ពាក្យសម្តីរបស់គាត់៖

“ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំរស់នៅក-៣ បន្ទាប់ពីបានស្នាក់នៅក-១ បាន១ ឬ២ខែបន្ទាប់ពីបានប្តូរមកពីប្រាសាទព្រះនៅបរមរាជវាំង”។ ប្រយោគបន្ទាប់ទៅទៀតខ្ញុំចង់ឲ្យលោកស្រីផ្តល់អារម្មណ៍។ “តាមពិតមេដឹកនាំភាគច្រើនស្នាក់ក-៣ ដូចជា អៀង សារី, សុន សេន, នួន ជា។ ចំណែកឯ ប៉ុល ពត វិញគាត់បានមកស្នាក់នៅក-៣ម្តងម្កាល”។ សំណួរសួរទៅលោកស្រី ថាតើប្តីរបស់លោកស្រីនិយាយការពិតដែរ

ឬទេ នៅពេលដែលគាត់បាននិយាយថា ថាគាត់បានរស់នៅក្នុងក-៣ជាមួយ នួន ជា នោះ?

**ឆ៖** ដូចខ្ញុំបាន--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[១៥:៥៤:៥៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញានេះវាច្រើនដងដដែលៗចំណុចនេះ ក៏ប៉ុន្តែយើងអាចថាទទួលយកបាន បើសិនជាតំណាងសហព្រះរាជអាជ្ញាចង់សួរច្រើនដងនៅចំណុចដដែលៗនេះ។ ប៉ុន្តែអ្វីដែលជាចំណោទនោះគឺថាតំណាងសហព្រះរាជអាជ្ញាគួរបញ្ជាក់ពីពេលវេលាឲ្យបានច្បាស់ ថាតើលោក នួន ជា រស់នៅក-៣ ជាមួយលោក ខៀវ សំផន ហ្នឹងពីពេលណាដល់ពេលណា? ឲ្យជាក់លាក់ឲ្យច្បាស់ ដើម្បីឲ្យសាក្សីអាចឆ្លើយទៅបានមានប្រយោជន៍ដល់អង្គសវនាការបាទ។ សូមអរគុណ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** គេសួរប្តីលោកស្រី នៅលើទំព័រនេះគេសួរសំណួរដូចទៅនេះ៖ "ថាតើក-១ និង ក-៣ សំដៅលើអ្វីខ្លះ?" ហើយគាត់បានឆ្លើយថា "មេដឹកនាំភាគច្រើនរស់នៅក-៣ អៀង សារី, សុន សេន និង នួន ជា ជាដើម"។ មុនពេលពីការគេចខ្លួនដែលលោកស្រីបានរៀបរាប់ពីម្សិលមិញនោះ តើលោក ខៀវ សំផន បានរស់នៅជាមួយ នួន ជា នៅក-៣ ដែរឬទេ? ខ្ញុំចង់បានចម្លើយថា ចាស ឬមិនមែន?

[១៥:៥៦:៣៥]

**លោកស្រី សូ សុជាតិ៖**

**ឆ៖** សូមលោកប្រធានអនុញ្ញាត គឺសំណួរនេះគឺគេមានពេលវេលា --

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយតាមពេលវេលាជាក់លាក់ដែលលោកស្រីបានដឹង។

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ពេលវេលានៅក-១ មួយរយៈ រួចទៅមកទាំងអស់គ្នានៅ ក-៣ តាមខ្ញុំចាំច្បាស់។ មក ក-៣

មកទាំងអស់គ្នា ដូចជា តា ប៉ុល ពត, តា នួន ជា, អៀង សារី, តា សុន សេន ហើយមកទាំងប្តីប្រពន្ធតា -- មានអ្នកផ្សេងទៀតដូចជា តាឌឿន, តា វន វ៉េត។ ចាស ទាំងអស់គ្នាមកនៅកន្លែង ក-៣ ទាំងអស់គ្នាហើយមួយរយៈក៏ចេញទៅអស់។ ដូច្នេះគាត់នៅពេលនោះ ឬមួយយ៉ាងម៉េចអាហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១៥:៥៧:៥៨]

**ស៖** លោកស្រី សូ សុជាតិ ខ្ញុំចង់ស្នើគំនិតមួយដល់លោក ហើយចង់ឲ្យលោកស្រីឆ្លើយទៅនឹងសំណើគំនិតរបស់ខ្ញុំមួយ។ សំណើរបស់ខ្ញុំជូនលោកស្រីគឺដូចខាងក្រោមនេះថា៖ លោកស្រី ហើយនិងប្តីរបស់លោកស្រីបានរួមរស់ជាមួយគ្នា ហើយរួមរស់ជាប្តីប្រពន្ធ ហើយបានដឹងអំពីការគេចខ្លួន ដកខ្លួនចេញពីក-៣ របស់មេដឹកនាំជាន់ខ្ពស់នាកាលនោះ។ នៅក្នុងភាពមិនស្មោះត្រង់ដែលយើងឃើញច្បាស់ ហើយនិងជាការប៉ុនប៉ងមិនច្បាស់ក្នុងការកុហកតុលាការនេះ ដើម្បីបំភ័ន្តថៅក្រមមួយរូបៗនៅទីនេះ។ តើលោកស្រីឆ្លើយតបទៅនឹងគំនិតដែលខ្ញុំនិយាយនេះដូចម្តេច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ អ្វីដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកអម្បាញ់មិញនេះ វាជាការសន្និដ្ឋានទម្លាក់កំហុសទាំងស្រុងទៅដល់សាក្សី ហើយខ្ញុំមិនយល់ថាហេតុអ្វីបានជាតំណាងសហព្រះរាជអាជ្ញាលើកបញ្ហានេះនៅពេលនេះទេ។ ហើយការចោទប្រកាន់ទៅលើសាក្សីនាពេលវាហាក់ដូចជាមិនមានអ្វីគោរពចំពោះសាក្សីទាល់តែសោះ ហើយសូមអង្គជំនុំជម្រះមេត្តាពិនិត្យទៅលើចំណុចនេះ។ បាទ សូមអរគុណ។

**លោក ឃីត រេយ៉ន៍រ៖**

គោលបំណង -- ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីឆ្លើយ។ នៅក្នុងគោលបំណងនៃការសួរដេញដោលនេះ ដើម្បីបង្កើតសំណុំរឿងរបស់សហព្រះរាជអាជ្ញាដើម្បីតេស្តមើលពីភាពជឿជាក់បាន ភាពស្មោះត្រង់របស់សាក្សី។ ហើយខ្ញុំស្នើគំនិតជូនសាក្សីនេះថា តើគាត់ជាមនុស្សកុហកឬទេ។ បើគាត់ជាមនុស្សកុហកមែន គាត់មានឱកាសក្នុងការឆ្លើយថា មែន ឬមិនមែន។

[១៦:០០:២៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០២:០២]

**ប្រធានអង្គជំនុំ៖**

បាទសេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក ខៀវ សំផន ធ្វើឡើងមិនមានមូលដ្ឋានសមស្របទេ។ សេចក្ដីជំទាស់មិនមានប្រសិទ្ធភាព អង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីរូបនេះទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា។ សាក្សីឆ្លើយតបប្រសិនបើសាក្សីនៅចាំសំណួរ ហើយប្រសិនជាមិនចាំទេឲ្យតំណាងសហព្រះរាជអាជ្ញាតាំងសំណួរនេះម្ដងទៀត ហើយជាសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញា។

**លោកស្រី សូ សុជាតិ៖**

សូមអនុញ្ញាតលោកប្រធាន ឲ្យលោកព្រះរាជអាជ្ញាសួរម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា សំណួរចុងក្រោយរបស់លោកអម្បាញ់មិញ គឺសាក្សីភ្លេចហើយ សូមតាំងសំណួរនេះសារជាថ្មីម្ដងទៀត។

[១៦:០២:៥៦]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកស្រី សូ សុជាតិ សំណើរយោបល់របស់ខ្ញុំជូនលោកស្រី តើលោកស្រី និងប្ដីរបស់លោកស្រីបានរៀបការរស់នៅជាមួយគ្នា រួមរស់ ហើយបានដឹងភស្ដុតាងខ្លះអំពីការអះអាងថាមានការដកខ្លួនចេញពីក-៣ របស់មេដឹកនាំខ្មែរក្រហមនៅក្នុងភាពមិនស្មោះត្រង់មួយដ៏ច្បាស់ក្រឡែត ហើយជាការប៉ុនប៉ងដ៏អាក្រក់មួយដើម្បីកុហកភូតភរតុលាការនេះ ដើម្បីបំភ័ន្តនូវចៅក្រមមួយរូបៗនៅទីនេះ។ តើលោកស្រីអាចនឹងឆ្លើយតបទៅនឹងគំនិតនេះដូចម្ដេច?

[១៦:០៤:២៤]

**លោកស្រី សូ សុជាតិ៖**

**ឆ៖** នាងខ្ញុំសូមអនុញ្ញាតលោកប្រធាន។ គឺចម្លើយនេះតាមនាងខ្ញុំដឹង និងឃើញច្បាស់ផ្ទាល់នឹងភ្នែក ហើយនៅជិតជាប់ជារៀងរាល់រហូតមក គឺខ្ញុំឃើញថាការរស់នៅរវាងប្ដីខ្ញុំជាមួយនឹងលោកទាំងប៉ុន្មាននាក់នេះ គឺមានរយៈកាល តែប្ដីខ្ញុំគាត់និយាយ ខ្ញុំ រយៈកាលមួយណាខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំចាំច្បាស់

ខ្លួនខ្ញុំ ខ្ញុំអត់មានមកបោកប្រាស់ មកនិយាយកុហក ពីព្រោះប្ដីជាប់នៅក្នុងកន្លែងឃុំឃាំងនេះអស់រយៈពេលជាង៥ឆ្នាំហើយ ៦ឆ្នាំហើយ។ ដូច្នេះខ្ញុំអត់មានភូតកុហកទេ ខ្ញុំនិយាយនេះគឺចង់ឲ្យតុលាការដឹងថាខ្ញុំគឺមិនវៀចវេរ ហើយមិនកុហក មិនភូត ពីព្រោះរយៈកាលដែលនៅជាមួយគ្នាមានមែន។ រយៈកាលប៉ុន្មានខែរួចគេចេញទៅអស់ តែភាសាគាត់និយាយខ្ញុំសូមទទួលថានៅជាមួយគ្នា ប៉ុន្តែរយៈកាលប៉ុន្មានអាហ្នឹងខ្ញុំអត់បានដឹងថាគាត់និយាយពីរយៈកាលណាទេ បើខ្ញុំដឹងគឺថាក្នុងមួយរយៈ។ រួចគេទៅអស់រហូតដល់រត់យួន នេះខ្ញុំសូមបញ្ជាក់។ ហើយបើតុលាការមិនជឿ លោកព្រះរាជអាជ្ញា លោកចៅក្រមលោកប្រធានមិនជឿ អាហ្នឹងក៏មិនបាច់ឲ្យខ្ញុំឆ្លើយអីថែមទៀតទេ ពីព្រោះដូចជាមើលងាយខ្ញុំដែរ ដល់ថាខ្ញុំមកភូតភរកុហក។ ខ្ញុំអត់មានទេ ខ្ញុំឃើញអីចឹងខ្ញុំនិយាយអីចឹង ខ្ញុំដឹងអី ខ្ញុំនិយាយអីចឹង អាណាដែលខ្ញុំមិនដឹងខ្ញុំអត់និយាយ។ អាហ្នឹងខ្ញុំសូមលោកប្រធានអធ្យាស្រ័យ។

[១៦:០៦:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកសាក្សី។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា។

**លោក ឃីត វេយ៍នរ៉ៈ**

លោកប្រធានខ្ញុំសូមមានភាពស្មោះត្រង់ ខ្ញុំបានសួរ១២ ទំព័រ ឥឡូវនេះខ្ញុំដល់ទំព័រ៩ ហើយខ្ញុំមានប្រធានបទបីផ្សេងទៀត។ ខ្ញុំសូមអនុញ្ញាតពេល ២៥នាទីយ៉ាងច្រើនបំផុតថ្ងៃស្អែកដើម្បីបញ្ចប់។ នេះជាសំណើរបស់ខ្ញុំ។ ហើយខ្ញុំជាពិសេសគឺថា អាចនឹងដកពេលនៃការជំទាស់ផងដែរដែលបានលើកឡើងនៅពេលល្ងាចនេះបាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានចំពោះយើង យើងមិនជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានោះទេ ប៉ុន្តែយើងសុំរយៈពេលពី៣០ ទៅ ៤០នាទីបន្ទាប់ពីព្រះរាជអាជ្ញាសួរហើយ។ តើយើងខ្ញុំ -- ខ្ញុំគិតថាសំណើពីខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនេះគឺជាសំណើមិនច្រើនអីទេ ៣០-៤០នាទីនេះ។

[១៦:០៨:១៦]

**លោក អាកទួរ វែកគែន៖**

បាទ សហព្រះរាជអាជ្ញាធ្វើសំណើដែរ ហើយអង្គជំនុំជម្រះនឹងសម្រេច ក៏ប៉ុន្តែខ្ញុំចាំថាថ្ងៃនេះសហព្រះរាជអាជ្ញានៅពេលសាក្សីផ្ដល់សក្ខីកម្មនេះ ចង់ចោទសំណួរដូចក្នុងលក្ខណៈជាខំមិនឡូទេ។

និយាយនាំមុខទៅសាក្សីអីជាដើម ដូចថា អូ! ឧទាហរណ៍ថាអ្នកឯងជាមនុស្សកុហកវិញនោះណា តើអ្នកឯងធ្វើយ៉ាងម៉េចហើយឆ្លើយយ៉ាងម៉េច? ហើយកាលពីដើមមកគេជំទាស់ខ្ញុំមិនឲ្យខ្ញុំនាំមុខគេរបៀបអីចឹងទេ ឧបមាណវិធីនេះ ហើយខាង -- អ៊ីចឹងភាពចាំបាច់នៃភាគីទាំងអស់នោះដែរថាឲ្យសាក្សីមកប្រឈមមុខនឹងការសន្និដ្ឋានរបស់ភាគីមួយខ្លួនគិតឃើញថាយ៉ាងម៉េចហ្នឹង ឲ្យសាក្សីថា។ ឥឡូវបើអ៊ីចឹងធ្វើយ៉ាងម៉េចទៅអ៊ីចឹង ខ្ញុំដូចជាឆ្ងល់ដែររឿងថាអម្បាញ់មិញនេះអនុញ្ញាតឲ្យគាត់ធ្វើរបៀបហ្នឹង ឲ្យសាក្សីបញ្ចេញប្រតិកម្មទៅនឹងគំនិតព្រះរាជអាជ្ញាហ្នឹង។ ហើយខ្ញុំថា បើពីដើមទីមកអនុញ្ញាតឲ្យខាងខ្ញុំធ្វើអ៊ីចឹងដែរនោះវាមិនស្អីទេ។ អ៊ីចឹងខ្ញុំគិតថារហូតឥឡូវពេលនេះ ឲ្យពេលវេលាបន្ថែមដល់ព្រះរាជអាជ្ញាទៀតហើយ ហើយឥឡូវនេះទើបនិយាយថាសល់ប៉ុន្មានទំព័រទៀតដើម្បីចោទសំណួរនេះ។ អ៊ីចឹងខ្ញុំគិតថាអង្គជំនុំជម្រះគួរតែគិតពិចារណាហើយថា អាចគិតចំពោះយើងយ៉ាងម៉េចដែរ? ព្រះរាជអាជ្ញាហ្នឹងប្រើពេលវេលារបស់ខ្លួនហ្នឹងវាអស់បាត់ហើយសម្រាប់ថ្ងៃនេះ ហើយគួរតែបញ្ឈប់បញ្ហាបែបនេះទៀតទៅ ព្រោះថាឃើញថាវាអត់ស្មើភាព។

[១៦:១០:០៦]

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីឆ្លើយតប។ ខ្ញុំមិនស្នើពេលថ្ងៃស្អែកទេ ដែលថា ស្វ សុជាតិ ជាអ្នកកុហកទេ ថ្ងៃស្អែក គឺថាយើងបាននិយាយថ្ងៃនេះរួចហើយ។ ប៉ុន្តែបញ្ហាដែលខ្ញុំចង់សួរសំណួរទៅគាត់នោះ គឺជាបញ្ហាអង្គហេតុ។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតតាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី យើងអនុញ្ញាតឲ្យមួយវគ្គនៅសវនាការនៅព្រឹកថ្ងៃស្អែកក្នុងការសួរសាក្សីរូបនេះ។

បាទ កិច្ចដំណើរការសវនការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១២ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែកនេះ នៅពេលព្រឹកអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស្វ សុជាតិ ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រុមមេធាវីនាំមុខ

តំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងក្រុមមេធាវីការពារក្តី នួន ជា ហើយនិងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-648។ សូមភាគីនៃរឿងក្តី និងបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ហើយនិងសាធារណជនជ្រាប។

[១៦:១១:២៤]

លោកស្រី សូ សុជាតិ ការស្តាប់សក្ខីកម្មរបស់លោកស្រីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកស្រីនៅព្រឹកថ្ងៃស្អែកទៀត ប្រហែលជាមួយវគ្គពីព្រឹករហូតដល់សម្រាក។ ហេតុដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀតដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី សូ សុជាតិ ទៅវិលត្រឡប់ទៅកាន់ទីលំនៅដ្ឋានគាត់វិញចុះ និងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន ហើយសូមអញ្ជើញលោកមេធាវី ម៉ម រិទ្ធា ដែលជាមេធាវីប្រឹក្សាសាក្សីអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការជាមួយនឹងសាក្សី សូ សុជាតិ ដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១២ នាទី)*